# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយជំនឿខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៨ លេខ ១១ ខែវិច្ឆិកា ព.ស. ២៤៩៩ គ.ស. ១៩៥៦

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង


| ផ្នែកសាសនា | | ទំព័រ |
|---|---|---|
| — ពុទ្ធសាសនានៅប្រទេសខ្មែរ | ព្រះភិក្ខុ ប៉ាង-ខាត់ | ១០០៣ |
| — កុរុធម៌ (តមក) | ព្រះទេពសត្ថា កិម-តូរ | ១០២០ |
| — ត្រៃវិបនកថា | លោក ឯន-ប៉ង់ | ១០៣០ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| — អក្សរសាស្ត្រខ្មែរសង្ខេប (តមក) | លោក ប៉ាយ-ប៊ុក | ១០៣៩ |
| — ពេជ្រព្រះរាជា (តមក) | លោក ស៊ុន-ហ៊ាន ... ប្រែ | ១០៥០ |
| — រឿងសាមកុក (តមក) | នាងកញ្ញា ឆ្នូ-កន | ១០៥៦ |
| — រឿងបល្ល័ង្កទិព្យ (តមក) | លោក ប៉ាយ-ប៊ុក ... ប្រែ | ១០៦៤ |
| — សាស្ត្រាចចក | លោក ចាប-ពិន | ១០៦៩ |
| — ផ្ដេសតូឡូហ្វៀន | លោក ផេង-ជ្រីវ ... ប្រែ | ១០៨២ |
| **កំណត់និងប្រវត្តិការណ៍** | | |
| — ពិធីបុណ្យព្រះសពសម្ដេចព្រះសុធម្មាធិបតី អ៊ុង-ស្រី សង្ឃនាយកគណៈធម្មយុត្តិ | លោក ឯន-ប៉ង់ | ១០៩២ |


មួយឆ្នាំមាន ១២ សៀវភៅ - ជំរៀជារ ២៣០រ,០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## TABLE DES MATIÈRES

### PARTIE RELIGIEUSE:


| | | Page |
|---|---|---|
| — Le bouddhisme au Cambodge . | *par le Vén. , PANG-KHAT* | *1003* |
| — Kurudharma (suite) . . . . . | *par le Vén. . SO-HAY . .* | *1020* |
| — Traivacanakatha . . . . . . | *par M. EN-PANG . . .* | *1030* |


### PARTIE LITTÉRAIRE:


| | | |
|---|---|---|
| — Littérature Khmère résumée (suite) . . . . . . . . . | *par M. RAY-BUC . . . . .* | *1039* |
| — Conte "Le Diamant de Raja" (suite) . . . . . . . . . . | *Traduit par M. SIN-HEAN.* | *1050* |
| — Histoire du Samkok (suite) . . | *Traduit par M. NOU-KAN.* | *1056* |
| — Les trente deux récits du Trône (suite) . . . . . . . | *Traduit par M. RAY-BUC .* | *1063* |
| — Histoire du loup . . . . . . | *par M. CHAP-PIN . . . .* | *1069* |
| — Histoire de chien blanc Tolozène | *par M. PHENG-CHRIV .* | *1082* |


### NOTES ET CHRONIQUES:


| | | |
|---|---|---|
| — Fête d'incinération de S. E. OUNG - SREY, Chef de l'ordre Dhammayut . . . . . . . . . | *par* M. EN-PANG . . . . | *1092* |


Prix d'abonnement annuel (comprenant 12 numéros) 230$00

ផ្នែកសាសនា

# ពុទ្ធសាសនានៅប្រទេសខ្មែរ

វីរិយបណ្ឌិតោ ភិក្ខុ (ប៉ាងខាត់)

---

ពុទ្ធសាសនាបានហោលពន្លឺមកលើដែនដីកម្ពុជាតាំងពីបុរាណកាល, ជនជាតិខ្មែរក៏បានទទួលយកពុទ្ធសាសនាទុកជាសរណៈដ៏ឧត្តម តាំងពីកាលនោះរៀងមក ដើម្បីបង្ក្រាបសេចក្តីភ័យតក់ស្លុត ដើម្បីសម្រេចសេចក្តីប្រាថ្នា និងសេចក្តីសង្ឃឹម ព្រមទាំងដើម្បីបញ្ជាក់នូវសេចក្តីទុកចិត្តរបស់ខ្លួនទៅក្នុងអនាគត ។ ពុទ្ធសាសនា បានអប់រំចិត្តគំនិតប្រជាជនឲ្យឈ្នះនូវជំនឿក្នុងនិយមនៃបុព្វជន ត្រាតែរសជាតិនៃព្រះធម៌ជ្រួតជ្រាបរហូតដល់ទៅជីវិតជានិច្ចរៀងរាល់ថ្ងៃទៀតផង ។ តាំងតែពីបានចូលមកប្រតិស្ឋាននៅលើដែនដីខ្មែរហើយ ពុទ្ធសាសនាតាំងនៅស៊ប់ ឥតសាបសូន្យក្នុងវេលាណាមួយឡើយ គ្រាន់តែមិនចេញឈ្មោះជាផ្លូវការ ឬមិនបានទទួលប្រោសប្រាណពីរាជសំណាក់ក្នុងកាលខ្លះប៉ុណ្ណោះ ហើយបានផ្សាយអានុភាពមកលើសិល្បៈនិងអក្សរសាស្ត្រខ្មែរទៀតផង ។ ក្នុងសម័យអាប់ឱន ព្រះពុទ្ធសាសនាអាចជ្រៀតជ្រែកនៅជាមួយសាសនាព្រាហ្មណ៍ ដែលជាសាសនាឥតមានសន្តោសដល់ជំនឿដទៃបាន ដូចប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ នឹងបង្ហាញឲ្យឃើញដោយជាក់ស្តែងដូចតទៅនេះ :

**សម័យមុនពង្សាវតារប្រទេសខ្មែរ.**–ក្រោយពុទ្ធបរិនិព្វានកាលប្រមាណ ២១៨ ឆ្នាំ ព្រះបាទអសោកទ្រង់ឡើងសោយរាជ្យក្នុងរាជធានីបាតលិបុត្តនៃមគធរដ្ឋ ។ ក្រោយធ្វើសង្គ្រាមកលិង្គរដ្ឋហើយ ទ្រង់ឃើញសង្គ្រាមថាជាមហន្តរាយដល់មនុស្សជាតិយ៉ាងក្រៃលែង ទ្រង់យល់ថាមានតែព្រះធម៌ទេ ដែលអាចញុំាងសត្វលោកឲ្យគប់ប្រសព្វសេចក្តីសុខក្សេមក្សាន្តបាន ទើបទ្រង់ប្រកាសចូលកាន់ពុទ្ធសាសនា ។ ទ្រង់បានជាព្រះរាជូបត្ថម្ភក្នុងការធ្វើតតិយសង្គាយនា ព.ស. ២៣៤ ។ ធ្វើតតិយ-សង្គាយនាហើយ ទ្រង់បានបញ្ជូនសមណទូតទៅកាន់បច្ចន្តប្រទេសនានាផុតពីដែនដីមជ្ឈិមប្រទេសមុនដំបូងបង្អស់ក្នុងប្រវត្តិពុទ្ធសាសនា ឈ្មោះថាបានបើកពុទ្ធសាសនាឲ្យសកលលោកបានស្គាល់តាំងពីកាលនោះមក ។

សមណទូតមួយអង្គ ៗ បាននាំយកព្រះបរមសារីរិកធាតុ ឬព្រះអរ-ហន្តធាតុជាប់ទៅជាមួយផង និមន្តទៅកាន់ប្រទេសណា ក៏ចាត់ការកសាងព្រះស្តូបចេតិយដំកល់ព្រះសារីរិកធាតុក្នុងប្រទេសនោះ ។ ទ្រង់បានបញ្ជូនព្រះមហិន្ទត្ថេរជាព្រះរាជបុត្រទៅកោះលង្កា ។ កោះលង្កានេះជាមជ្ឈមណ្ឌលផ្សាយពុទ្ធសាសនាមួយដ៏សំខាន់ ក្នុងប្រវត្តិពុទ្ធសាសនាថេរ-វាទ ។ ទ្រង់បានបញ្ជូនព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរទៅសុវណ្ណភូមិ ។

**សុវណ្ណភូមិនៅឯណា ?**

សុវណ្ណភូមិជាដែនដីមនសម័យទ្វារវតី ឋិតនៅក្នុងទក្ខិណទិសាភាគប្រទេសភូមា និងប្រទេសថៃសព្វថ្ងៃនេះ ឬនិងហៅរួមថា ដែនដីអាស៊ីភាគ

អាគ្នេយ៍ក៏បាន ។ នៅដែនដីសុវណ្ណភូមិដែលជាទីឋានឋិតនៅឆ្ងាយពីប្រទេសឥណ្ឌា ហើយមានបុរាណដ្ឋានបុរាណវត្ថុនិងសិលាចារឹកច្រើនកន្លែង គួរនឹងសន្និដ្ឋានថាទីនោះៗ ជាមជ្ឈមណ្ឌលផ្សាយពុទ្ធសាសនាតាំងពីសតវត្សទី ៣ ព.ស. បាន ។

ដែនដីសុវណ្ណភូមិ ឬអាស៊ីភាគអាគ្នេយ៍នេះ មានមជ្ឈមណ្ឌលផ្សាយពុទ្ធសាសនា ៣ កន្លែង គឺ ៖

១ – សុវណ្ណភូមិបច្ឆិមទិសាភាគ គឺប្រទេសភូមាសព្វថ្ងៃ ។ ទីក្រុងបុរាណឈ្មោះសុធម្មវតី(១) ឬ សុធម្មបុរៈ សព្វថ្ងៃនេះហៅថា 'ថាតុង' (THATON) សមជាទីឋានសមណទូតព្រះបាទអសោកក្នុងសតវត្សទី ៣ ព.ស. ។ ក្នុងតំបន់ព្រោម(២) (Prome) អ្នកប្រាជ្ញបុរាណវត្ថុបានរកឃើញបន្ទះមាសចារឹកគោលពុទ្ធសាសនាថា យេ ធម្មា ហេតុប្បភវា ។ ល ។ នៅម៉ោងគាន (Maurng gan) និងម៉ាហ្សា (Maza) ជាកស្តុតាងកើតឡើងក្នុងសតវត្សទី១០ ព.ស. ។

២ – សុវណ្ណភូមិមជ្ឈិមភាគ គឺប្រទេសថៃសព្វថ្ងៃ ។ នៅភាគខាងក្រោមទន្លេមេណាម មានចេតិយ(៣)និងកង់ចក្រនៅនគរបឋម មានព្រះពុទ្ធរូបបែបអមរាវតី នៅពង់ទឹក ជាកស្តុតាងកើតឡើងក្នុងសតវត្សទី ៨ ព.ស. ។

៣ – សុវណ្ណភូមិបុព្វទិសាភាគ គឺប្រទេសខ្មែរសព្វថ្ងៃ ។ លោកហ្វ៊ីណូ(៤) សរសេរទុកថា មានជនជាតិឥណ្ឌាបាននាំយកវប្បធម៌មកផ្សាយតាំងពីសតវត្សទី ៣ ព.ស. ។ មានសិលាចារឹកពុទ្ធសាសនានៅ

វ៉ូកាញ់ (៥) (Vo-canh) ជាភស្តុតាងកើតឡើងក្នុងសតវត្សទី ៨ ព. ស. នឹងពុទ្ធរូបឥណ្ឌូ(៦)ក្រិកនៅវត្តរំលោកចាស់ជាងគេ របនា មគធៈ ប្អមថុក ប្អអជន្តា ជាភស្តុតាងកើតឡើងក្នុងសតវត្សទី ១០ ព.ស ព្រមទាំងមានបុរាណដ្ឋានពុទ្ធសាសនា ២ កន្លែងទៀតនៅអង្គរបុរីមួយកន្លែង នឹងនៅវត្តត្រពាំងវែងខាងត្បូងខេត្តព្រះត្រពាំង (វៀតណាមខាងត្បូង) មួយកន្លែងៗ

ភូមិភាគទាំង ៣ កន្លែងនេះហើយ ជាទីឋានដែលព្រះថេរានុត្ថេរៈទាំងឡាយមានព្រះសោណត្ថេរ នឹងព្រះឧត្តរត្ថេរជាដើម បានសាបព្រោះពូជពុទ្ធសាសនាបណ្តុះបណ្តាលឲ្យដុះលូតលាស់ឡើង ត្រាតែក្នុងសម័យបច្ចុប្បន្នកាលនេះ មានប្រជាជនរាប់លាននាក់ចូលកាន់ពុទ្ធសាសនា ។

សម័យនគរភ្នំ .— ពីសតវត្សទី ៦ ទៅទី ១១ ព. ស. (៥៤៣-១០៤៣)។ អាស្រ័យដោយភូមិភាគនេះមានវប្បធម៌ឥណ្ឌៀចូលមកហើយប្រទេសនគរភ្នំ (Founan) ក៏បានទទួលពុទ្ធសាសនាថេរវាទ តាំងពីបឋម-កាល បានជាមានសិលាចារឹកពុទ្ធសាសនា(៥)សំស្ក្រឹតចាស់ជាងគេនៅឥណ្ឌូចិន (សិលាចារឹកវ៉ូកាញ់)កើតឡើងក្នុងសតវត្សទី ៨ ព.ស. ថ្លែងពីរាជវង្សស្រីមារៈផ្ទះថ្វាពុទ្ធសាសនា ឯព្រះរាជប្រកាសព្រះអង្គដែលឆ្លាក់ទុកក្នុងសិលាចារឹកនោះ មានទំនងដូចព្រះរាជប្រកាសព្រះបាទអសោកនៅប្រទេសឥណ្ឌៀដែរ ។ សម័យនគរភ្នំ ព្រះរាជាមន្ត្រីធំតូចរហូតដល់ប្រជាជន ភាគច្រើនកាន់សាសនាព្រាហ្មណ៍ គោរពព្រះមហេស្វរៈ(ព្រះឥស្វរ) ដល់សម័យតមក គោរពហរិហរៈ គឺព្រះឥស្វរនឹងព្រះវិស្ណុ

ចូលគ្នា; ក្រៅពីសាសនាព្រាហ្មណ៍ ព្រះរាជាអង្គខ្លះនិងប្រជាជនកាន់ពុទ្ធសាសនាថេរវាទ ។

ខាងដើមសតវត្សទី ១១ ព.ស. ពង្សាវតារចិនខាងត្បូង(៧)រាជវង្សត្រៀមានដំណាលថា ប្រទេសនគរភ្នំកាន់សាសនាព្រាហ្មណ៍ ឯពុទ្ធសាសនាក៏ចំរើនធំទូលាយណាស់ដែរ ។ ព្រះបាទកៅណ្ឌិណ្យជយវរ្ម័ន(ទីពីរ)ឡើងសោយរាជ្យក្នុង ព.ស. ១០២១, កាលដើមទ្រង់កាន់សាសនាព្រាហ្មណ៍តមកទ្រង់កាន់ពុទ្ធសាសនា ហើយទ្រង់បានបញ្ជូនភិក្ខុនាគសេន(៨) ជាតិឥណ្ឌាជាបេសកជនទៅកាន់ព្រះចៅក្រុងចិន វូ-ទី ទ្រង់បានបញ្ជូនព្រះសង្ឃបាលត្រនឹងមន្ទ្រសេនត្រទៅកាន់ព្រះរាជសំណាក់ព្រះចៅក្រុងចិនដើម្បីជួយប្រែព្រះត្រៃបិដក ។ ព្រះថេរទាំងពីរអង្គនេះមាននាមប្រាកដក្នុងព្រះត្រៃបិដកចិន ។ ទ្រង់បានបញ្ជូនភិក្ខុខ្មែរច្រើនអង្គទៀតទៅកាន់ព្រះរាជសំណាក់ព្រះចៅក្រុងចិន ។ ព្រះបាទរុទ្រវរ្ម័ន(៩)ឡើងសោយរាជ្យក្នុង ព.ស. ១០៥៧ ទ្រង់ជាមហាក្សត្រចុងក្រោយសម័យនគរភ្នំ សិលាចារឹកនៅប្រាសាទតាព្រហ្ម ទន្លេបាទី(១០) ដំណាលថាទ្រង់កាន់សាសនាព្រាហ្មណ៍ តែទ្រង់គោរពព្រះបរមសារីរិកធាតុតាមបែបពុទ្ធសាសនាថេរវាទ ។ ទ្រង់បានថ្វាយព្រះរាជសារទៅកាន់ព្រះចៅក្រុងចិន ព.ស. ១០៨២ ថា ទ្រង់មានព្រះបរមសារីរិកធាតុ(១១) គឺព្រះកេសមួយសរសៃ ។ គួរឲ្យនឹកថា ព្រះបរមសារីរិកធាតុនេះ ជាមរតកតបុស្សៈ និងភល្លិកៈទុកឲ្យជាតិខ្មែរ ។ ក្នុងរជ្ជកាលព្រះបាទកៅណ្ឌិណ្យជយវរ្ម័ន(១២) និង

ព្រះបាទសូរ្យវរ្ម័ន សតវត្សទី ១១ និងទី ១២ ព.ស. ព្រះពុទ្ធសាសនា ចំរើនរុងរឿងណាស់ ។ តមកយើងមានសិលាចារឹកនៅវិទ្យាវិសេសៈ មួយទៀតពី ព.ស. ១១៧០ ដំណាលពីពុទ្ធសាសនាសម័យនោះ ។

លោកយី-ត្សុង (Yi-Tsing) ដែលបានធ្វើដំណើរមកកាន់អាស៊ីភាគអាគ្នេយ៍កន្លងពីព.ស. ១២១៤-១២៣៨ បានសរសេរទុកថា[១៣] "នៅប្រទេសនគរភ្នំ កាលមុនព្រះពុទ្ធសាសនាថេរវាទចំរើនរុងរឿងណាស់ ហើយផ្សាយទូទៅ" តមក "មានព្រះរាជាមួយព្រះអង្គមិនសព្វព្រះទ័យ ហើយបំបាត់ព្រះពុទ្ធសាសនាចោលអស់ទៅ ហើយឥឡូវនេះ សូម្បីតែភិក្ខុមួយអង្គក៏មិនសល់ផង" ។ សេចក្តីលោកយី-ត្សុងនេះ មិនមានហេតុផលសមរម្យល្មមជឿបានទេ ព្រោះសម័យនោះមានសិលាចារឹកខ្លះនិយាយពីការកសាងវត្តអារាមដេរដាសនៅឡើយ ។

**សម័យបេនឡា.**— សតវត្សទី ១១ ទៅទី ១៤ ព.ស. (១០៩៣-១៣៤៥) ។ ពុទ្ធសាសនាមហាយាន[១៤] ចូលមកដែនដីកម្ពុជាមុនដំបូងក្នុងពង្សាវតារប្រទេសខ្មែរ គឺខាងដើមសតវត្សទី ១២ ព.ស. ។ មានសិលាចារឹកមួយនៅខេត្តសៀមរាប កើតឡើងពី ព.ស.១៣៣៤ ដំណាលពីការកសាងពោធិសត្វលោកេស្វរៈ[១៥]ដើម្បីគោរព ។ បូជនីយដ្ឋាននេះ សព្វថ្ងៃហៅថាប្រាសាទ តាកៀម ។

**សម័យមហានគរ.**— សតវត្សទី១៤ទៅទី២០ព.ស. (១៣៤៥-១៩៧៥)។ ព្រះបាទជ័យវរ្ម័នទី២ ឡើងសោយរាជ្យ ព.ស. ១៣៤៥

ទ្រង់តាំងព្រះរាជធានីលើមហេន្ទ្របវ៌ត គឺភ្នំគូលែន ។ ព្រះស្ដែងអ័ញសិវកៃវល្យក៏តាមស្ដេចទៅនៅភ្នំព្រះរាជធានីនោះដែរ ។ កាលនោះមានព្រាហ្មណ៍ម្នាក់ឈ្មោះហិរណ្យទាម មករៀបចំពិធីប្រកាសឯករាជ្យជាចក្រពត្រាធិរាជដោយប្រតិស្ឋទេវរាជឡើង ។ ព្រះរាជាអង្គនេះបានរួបរួមចេនឡាទាំងពីរឲ្យទៅជាប្រទេសតែមួយ ហើយស្ថាបនាប្រទេសឲ្យបានរុងរឿងឡើង ។ ព្រះរាជាអង្គនេះទ្រង់កាន់សាសនាព្រាហ្មណ៍ គោរពហរិហរៈ តែពុទ្ធសាសនាទាំងពីរនិកាយឋិតថេរជាមួយសាសនាព្រាហ្មណ៍រហូតមក ។ តាំងពីសតវត្សទី ១៥ ព.ស. រៀងមក ព្រះរាជា[១៦] នឹងមន្ត្រីកាន់សាសនាមិនស្របគ្នាទេ ។ ព្រះបាទឥន្ទ្រវរ្ម័នទ្រង់ឡើង[១៧] សោយរាជ្យក្នុង ព.ស. ១៤២០ តាំងព្រះរាជធានីនៅបាគង (តំបន់រលួសសព្វថ្ងៃនេះ) ។ ទ្រង់កាន់សាសនាព្រាហ្មណ៍ គោរពព្រះហរិហរៈ ប្រាសាទបាគងជាហរិហរាល័យ គឺជាឋានព្រះហរិហរៈ តែទ្រង់ប្រោសប្រាណពុទ្ធសាសនាដែរ ។ ក្រោយទ្រង់ទិវង្គតទៅ ព្រះបាទយសោវរ្ម័ន[១៨] ជាព្រះរាជបុត្រឡើងសោយរាជ្យក្នុង ព.ស ១៤៣២ ហើយស្ដេចទៅតាំងព្រះរាជធានីថ្មីឈ្មោះយសោធរបុរៈ គឺបរិវេណអង្គរធំមានភ្នំបាខែងជាមជ្ឈដ្ឋាន ។ ទ្រង់ទទួលស្គាល់ពុទ្ធសាសនាមហាយានជាផ្លូវការមុនដំបូងបង្អស់ក្នុងពង្សាវតារប្រទេសខ្មែរ ។ សាសនាព្រាហ្មណ៍និងពុទ្ធសាសនាទាំងពីរនិកាយមិនមានការបៀតបៀនគ្នាទេ មានសិទ្ធិនិងបុព្វសិទ្ធិដូចៗគ្នា ហើយនៅជាសុខក្សេមក្សាន្តតរៀងមក ។ ទ្រង់បានកសាងវត្តអារាមថ្វាយសាសនាទាំងពីរនេះ ។ តមក ព្រះបាទរាជេន្ទ្រវរ្ម័ន[១៩] ទ្រង់ឡើង

សោយរាជ្យក្នុង ព ស. ១៤៨៧ ទ្រង់កាន់សាសនាព្រាហ្មណ៍ គោរពព្រះឥសូរ តែក្នុងរាជ្យព្រះអង្គ ការកសាងវត្តអារាមពុទ្ធសាសនា ឃើញមានកាន់តែច្រើនឡើង ហើយកាន់តែសសៀរចូលមកជិតព្រះរាជធានីថែមទៀត ។ មានមន្ត្រីជាន់ខ្ពស់ម្នាក់ឈ្មោះកវីន្ទ្រារិមថនៈ កាន់ពុទ្ធ-សាសនា បានកសាងទេវាល័យ ៣ ខ្នងនៅបាតជុំ : មួយថ្វាយព្រះសម្មាសម្ពុទ្ធ, មួយថ្វាយព្រះវជ្របាណិ, មួយទៀតថ្វាយព្រះប្រាជ្ញាបារមិតា ។

តមកទៀត ព្រះបាទជយវរ្ម័នទី ៥[២០] ជាព្រះរាជបុត្រព្រះបាទរាជេន្ទ្រវរ្ម័នឡើងសោយរាជ្យក្នុង ព.ស ១៥១១ ក្នុងរាជ្យព្រះអង្គនេះ មានសិលាចារឹកមួយនៅវត្តស្រីសន្ធរឲ្យដឹងថា[២១] ទ្រង់មិនមែនជាពុទ្ធសា-សនិកទេ តែរាជគ្រូកូលនិងមន្ត្រីជាន់ខ្ពស់កាន់ពុទ្ធសាសនាមហាយានលទ្ធិយោគាចារៈ គោរពពោធិសត្វលោកេស្វរៈ មានមន្ត្រីជាន់ខ្ពស់ម្នាក់ឈ្មោះកវីន្ទ្របណ្ឌិតជាអ្នកនាំ ។ ក្នុងសិលាចារឹកនេះ ពួកអ្នកប្រាជ្ញទាំងឡាយសង្កេតឃើញលទ្ធិសាសនាព្រាហ្មណ៍ចូលលាយឡំក្នុងព្រះពុទ្ធសាសនានៅប្រទេសខ្មែរមុនដំបូង ។ ព្រះបាទសូរ្យវរ្ម័នទី១[២២]ឡើងសោយរាជ្យក្នុង ព. ស. ១៥៤៩ ទ្រង់ជាពុទ្ធសាសនិក ទ្រង់បានទទួលស្គាល់ពុទ្ធសា-សនាលទ្ធិមហាយានជាផ្លូវការ មិនមែនគ្រាន់តែប្រោសប្រាណប៉ុណ្ណោះទេ ទ្រង់បានឧបត្ថម្ភពេញបន្ទុកថែមទៀតផង ។ ក្នុងរាជ្យព្រះអង្គ ព្រះពុទ្ធសាសនារុងរឿងណាស់ មានការកសាងពុទ្ធរូបបក់នាគច្រើនអនេក

តែក្នុងព្រះបរមរាជវាំងនៅគោរព[២៣] ទេវរាជ តាមព្រះរាជប្រពៃណីដូចដើម ៗ លុះទ្រង់ទិវង្គតទៅ គេថ្វាយព្រះបច្ឆាមរណនាមថា "ព្រះនិវ៌ានបទ" ។

ដល់មកសតវត្សទី ១៨ មានព្រះរាជាមួយព្រះអង្គ មានព្រះកិត្តិនាមល្បីល្បាញក្នុងពង្សាវតារខ្មែរ ឡើងសោយរាជ្យក្នុង ព.ស ១៧២៤ ទ្រង់ព្រះនាមព្រះបាទជ័យវរ្ម័នទី ៧[២៤] ទ្រង់ជ្រះថ្លាពុទ្ធសាសនាមហាយាន គោរពលោកេស្វរៈ ព្រះប្រាជ្ញាបារមិតា ។ ក្នុងរាជ្យព្រះអង្គទ្រង់មិននិយមទេវរាជទេ ទ្រង់ប្រតិស្ឋពុទ្ធរាជវិញ, ពុទ្ធសាសនារុងរឿងអស្ចារ្យ ។ ប្រាសាទរាជស្ថានច្រើនកន្លែង ដ៏ហើយដោយកំពូលសុទ្ធសឹងលោកេស្វរៈសមន្តមុខប្រុងប្រាង ព្រះនេត្រាសំឡឹងចុះមកក្រោមព្រះភក្ត្រញញឹមពព្រាយ លើកតំកើងព្រះកិត្តិយសទុកជាដំណាតមក ។ ទ្រង់សាងព្រះរាជវិហារ[២៥]សព្វថ្ងៃហៅ តាព្រហ្ម កាល ព.ស. ១៧២៩ ដើម្បីដំកល់បដិមាករព្រះនាងជយរាជចូឌាមណី ជាព្រះវររាជមាតា ទុកជាអង្គប្រាជ្ញាបារមិតា គឺជាធម្មមាតានៃព្រះពុទ្ធ និងបដិមាករនៃព្រះរាជគ្រូមួយទៀតឈ្មោះ ជយមង្គលថ: ។ ក្រោយពីសាងព្រះរាជវិហារមក ៥ ឆ្នាំ គឺក្នុង ព.ស. ១៧៣៤ ទ្រង់សាងប្រាសាទជយស្រី[២៥] សព្វថ្ងៃហៅព្រះខាន់ ដើម្បីដំកល់បដិមាករព្រះបាទធរណីន្ទ្រវរ្ម័ន (ឥន្ទ្រវរ្ម័នទី ២) ជាព្រះវររាជ-បិតា ទុកជាអង្គពោធិសត្វលោកេស្វរៈ ហើយថ្វាយព្រះនាមថា ជយ-វរមេស្វរៈ ។ ក្នុងបច្ឆិមវ័យកាល ទ្រង់សាងប្រាសាទបាយ័ន[២៥] ដើម្បីតំកល់បដិមាករព្រះអង្គជាពុទ្ធរាជ ព្រមទាំងប្រតិស្ឋានពោធិសត្វលោកេ

ស្តូវៈសមុទ្ទមុខដែលទុកដូចជាព្រះអង្គនៅលើកំពូលទាំងឡាយនៃប្រាសាទ បាយ័ននោះផង ។ សិលាចារឹកនៅប្រាសាទតាព្រហ្ម(២៦) សរសើរព្រះរាជសាសន៍របស់ព្រះអង្គទុកថា: "មាគ៌ាដ៏ប្រសើរដែលនាំទៅកាន់សេចក្តីត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ ជាមាគ៌ាឯក ឥតមានមន្ទិលសៅហ្មង ដើម្បីឲ្យបានយល់ធម៌ពិត គឺជាធម៌ដែលអមតបុគ្គលគង់តែគត គួរគោរពបូជាទុកជាព្រះខាន់ពេជ្រ សម្រាប់កាប់បំផ្លាញនូវបណ្តាញបន្ទាគឺតណ្ហា" ។ សិលាចារឹកនៅមន្ទីរពេទ្យ(១៧) សរសើរព្រះកិត្តិយសគុណព្រះអង្គទុកថា "ទ្រង់មានព្រះទ័យខ្លោចផ្សា ចំពោះជម្ងឺប្រជាជនខ្លាំងជាងព្រះអាពាធព្រះអង្គ ព្រោះថាសេចក្តីទុក្ខនៃប្រជាជន ជាសេចក្តីទុក្ខនៃព្រះរាជាទាំងឡាយ ពុំមែនចំពោះទុក្ខផ្ទាល់ព្រះអង្គទេ" ។

មានព្រឹត្តិការណ៍មួយចំឡែក គួរកត់សំគាល់ទុកក្នុងរជ្យព្រះអង្គគឺ ទ្រង់បានបញ្ជូនព្រះរាជបុត្រទៅសិក្សាព្រះពុទ្ធសាសនា ហើយបព្វជ្ជានៅវត្តមហាវិហារនាកោះលង្កា ។ តាមពង្សាវតារភូមានិយាយថា(២៧) មានសាមណេរជាតិមនមួយអង្គឈ្មោះឆបត: អាយុ ២០ ឆ្នាំ ទៅរៀននៅកោះលង្កា ១០ ឆ្នាំ ហើយត្រឡប់មកកាន់ប្រទេសភូមាវិញពី ព.ស. ១៧៣២ ជាមួយនឹងភិក្ខុឯទៀត ៤ អង្គ មួយអង្គឈ្មោះតាមលិន្ទ: ជាព្រះរាជបុត្រមហាក្សត្រប្រទេសកម្ពុជា ។ ភិក្ខុ តាមលិន្ទ: នេះពិតប្រាកដជាព្រះរាជបុត្រព្រះបាទជ័យវរ្ម័នទី ៧ ។ សេចក្តីប៉ុណ្ណោះជាដើម ដែលនាំឲ្យអ្នកប្រាជ្ញពង្សាវតារនឹងអ្នកប្រាជ្ញបុរាណវត្ថុយល់ថា ភិក្ខុតាមលិន្ទ:ជា

ព្រះរាជបុត្រព្រះបាទជ័យវរ្ម័ននេះ ដែលនាំពុទ្ធសាសនាថេរវាទលង្កាវង្ស ចូលមកផ្សាយក្នុងប្រទេសខ្មែរមុនដំបូងក្នុងពង្សាវតារខ្មែរ ។

ក្រោយរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ទៅ ព្រះរាជាសោយរាជ្យជាតំណព្រះវង្សត្រឡប់មកកាន់សាសនាព្រាហ្មណ៍វិញ សាសនាព្រាហ្មណរុងរឿងចុងក្រោយបំផុតម្តងទៀត ។ ឯពុទ្ធសាសនាថេរវាទក៏ចំរើនខ្លាំងតាំងពីកាលនោះមកដែរ ។ លោកចៅ តាក្វន(២៩) ជារាជទូតព្រះចៅក្រុងចិនដែលបានមកកាន់មហានគរប្រទេសខ្មែរ ក្នុងព.ស. ១៨៣៩ បានធ្វើសេចក្តីរាយការណ៍ទុកមកដូច្នេះថា «ឃើញមានភិក្ខុកោរព្រះកេស ប្រដាប់ស្បៃចីវរពណ៌លឿង ក្នុងចីវរចៀងស្មាម្ខាង នៅស្មាស្តាំទំនេរ ដើរជើងទទេ វិហារប្រក់ក្បឿង ក្នុងព្រះវិហារមានព្រះពុទ្ធរូបសាក្យមុនី ហៅថាបោឡាយ 'ព្រះ' ព្រះពុទ្ធរូបនៅក្នុងប្រាសាទធ្វើពីសំរឹទ្ធ មិនមានជួងស្គរទេ ឆាន់ត្រីសាច់ មិនឆាន់សុរាទេ ឆាន់មួយថ្ងៃតែម្តង ក្នុងវត្តមិនមានផ្ទះបាយទេ ភិក្ខុសាមណេរទទួលបិណ្ឌបាត់ សូត្រធម៌ គម្ពីរដីកាបារជាក់ស្ទើរតែ ព្រះរាជាទ្រង់ពិគ្រោះកិច្ចការធំៗ នឹងភិក្ខុសង្ឃ មិនមានភិក្ខុនីទេ» ។ សេចក្តីរាយការណ៍នេះសំដែងឲ្យឃើញថា ពុទ្ធសាសនាថេរវាទលូតលាស់ដុះដាលពេញបរិបូណ៌ ហើយបានទទួលស្គាល់ពីព្រះរាជា មុខមន្ត្រី រហូតដល់ប្រជាជនទូទៅ សមដូចសិលាចារឹកបាលី(៣០) មុនដំបូងក្នុងប្រវត្តិពុទ្ធសាសនាហីនយាននៅប្រទេសខ្មែរចែងទុកថា «ព្រះបាទសិរីសិរិន្ទ្រវម្ម (គឺឥន្ទ្រវរ្ម័នទី៣) ឡើងសោយរាជ្យក្នុងមហានគរយសោធរបុរៈក្នុង ព.ស. ១៨៥០ ទ្រង់បានថ្វាយសិរីសិរិន្ទ្រគ្រាមជាព្រះ

អាគមចំពោះព្រះមហាថេរសិរីសិរិទ្ធមោលិ ក្នុង ព.ស.១៨៥១ ហើយទ្រង់មានព្រះរាជឧក្ការត្រាស់បង្គាប់ឲ្យព្រះនាងសិរីមាលិនីលក្ខីកសាងព្រះវិហារព្រមទាំងពុទ្ធរូបដំកល់ទុកក្នុងព្រះវិហារវត្តនោះក្នុងព.ស.១៨៥២” ។

បំណោរពេរកាលតមក ព្រះពុទ្ធសាសនាថេរវាទរឹតតែចំរើនរុងរឿងឡើងៗជាលំដាប់ សមតាមព្រះរាជបំណងរាជវង្សព្រះបាទស្រីមារៈសម័យនគរកុំ តែព្រះរាជពិធីខាងសមាសទឹងព្រះរាជពិធីផ្សេងៗ ក្នុងព្រះបរម.រាជវាំងបិតថេរនៅតាមប្រពៃណីដើម ដែលមានមកតាំងពីបុរាណកាល ។ តពីរជ្ជកាលព្រះបាទសិរីសិរិទ្ធវម្ម (ឥន្ទ្រវរ្ម័នទី ៣) ពាក់កណ្ដាលសតវត្សទី ១៩ (ព.ស. ១៨៥២) មក ប្រទេសខ្មែរមានគ្រោះថ្នាក់សរសៀរចុះមកកាន់សេចក្ដីអាប់ឱន ព្រោះកើតមានចម្បាំងរាំងជលមិនដាច់ សិលាចារឹកដំណាលពីព្រះរាជវង្សតៗ មកក៏មិនមាន ពង្សាវតារបុរាណក៏អន្តរធានបាត់បង់ទៅបន្តិចម្ដងៗ តាមកាលវេលា រហូតមកដល់រជ្ជកាលព្រះបាទពញាយ៉ាត ពាក់កណ្ដាលសតវត្សទី ២០ រវាង ព. ស.១៩៧៥ ។

**សម័យបច្ចុប្បន្ន** .— សតវត្សទី ២០ ទៅទី ២៥ ព.ស. (១៩៧៥-២៥១០) ។ ក្រោយសម័យមហានគរមក ព្រះពុទ្ធសាសនាថេរវាទប្រតិស្ឋានលើដែនដីខ្មែរជាប់ស៊ប់ឥតប្រែប្រួល ចាក់ឫសគល់ជាស្ថាពររឿងរហូតមកដល់បច្ចុប្បន្នកាលនេះ សមដូចពាក្យលោកវ៉ាំងតាយួន[៣១] (Wang Ta-Yuan) សរសេរសរសើរប្រទេសខ្មែរទុកពីសតវត្សទី ១៩ នៃ ព.ស. ថា ប្រទេសខ្មែរ ជាបេនឡាមានទ្រព្យសម្បត្តិ និងជាបេនឡាមួយរយវត្ត ។ ឯសាសនាព្រាហ្មណ៍និងពុទ្ធសាសនាមហាយានមិនសូវ

មានសាវ័ក កំសាបសូន្យបន្តិចម្តងៗ រហូតដល់អស់សានបាត់ឈ្មោះបោះសម្ងំសូន្យឈឹង នៅសល់តែបុរាណដ្ឋានដេរដាសពាសពេញប្រទេសៗ

ពុទ្ធសាសនាថេរវាទឡើងកាន់សេចក្តីចំរើន យកវត្តសាសនាព្រាហ្មណ៍មកធ្វើជាវត្តពុទ្ធសាសនាវិញ បាត់សិវលិង្គនៅលើស្ថានទ្រោណិទៅ លេចឃើញព្រះពុទ្ធរូបដំកល់នៅលើស្ថានទ្រោណិជំនួសវិញ ៗ មានវត្តច្រើនណាស់ដែលតាំងនៅលើកន្លែងវត្តសាសនាព្រាហ្មណ៍ ឈ្មោះនៅជាឈ្មោះវត្តសាសនាព្រាហ្មណ៍ដដែល តែតួវត្តជាពុទ្ធ-សាសនា ៗ វត្តណាមួយដែលតាំងនៅលើវត្តសាសនាព្រាហ្មណ៍ វត្តនោះមិនមែននៅសល់តែឈ្មោះទេ នៅមានសល់ស្នាមដំណែលសាសនាព្រាហ្មណ៍ដដែល ដូចជាប៉ានកៃលាសជាដើម ៗ ឯទំនៀមស្រុកឬពិធីផ្សេងៗ ដែលលាយឡំដោយលទ្ធិសាសនាព្រាហ្មណ៍នឹងពុទ្ធសាសនាមហាយាន កើតទៅជាទំនៀមទំលាប់ស្រុកទេសជាប់រហូតមកដល់សព្វថ្ងៃនេះ ៗ ក្នុងព្រះបរមរាជវាំង ព្រះរាជពិធីផ្សេងៗ ដែលជាប់ដោយលទ្ធិសាសនាព្រាហ្មណ៍ តាំងពីបុរាណសម័យមកក៏នៅធ្វើតាមប្រពៃណីដើមដដែល ៗ សព្វថ្ងៃនេះ មើលទៅឃើញតែវត្តអារាម កុដិ វិហារ សាលាធំហើយដោយកំពូលច្រងច្រាង ភិក្ខុ សាមណេរគ្រងចីវរពណ៌លឿងសព្វទីកន្លែងពាសពេញព្រះរាជអាណាចក្រ "សមនឹងពាក្យអ្នកបរទេសខ្លះសរសេរទុកថា "ប្រទេសខ្មែរជាប្រទេសភិក្ខុសង្ឃ" ៗ

**ពុទ្ធសាសនានឹងប្រជាជន**.— សម័យអាប់ទុន ប្រជាជនខ្មែរទាំងប្រទេស បានជួបប្រទះនឹងសេចក្តីទុក្ខវេទនាធំបំផុត ថមថយកម្លាំង

ទឹងកសាងសេចក្ដីចំរើនដូចសម័យព្រេងនាយពុំបាន តែទោះបីធ្លាក់ចុះខ្លាំងប៉ុណ្ណឹងក៏ដោយ ប្រជាជនខ្មែរដែលបានស្គាល់សេជាតិព្រះធម៌ថ្លៃវិសេសហើយ ឧបាសកនានេះជាប់ទឹងខ្លួនទុកតមក ស៊ូស្លាប់មិនព្រមលះបង់ចោល ។ បុណ្យទទួលព្រះបរមសារីរិកធាតុនិងព្រះអរហន្តធាតុព្រះសារីបុត្រនិងព្រះមហាមោគ្គល្លានពីខែតុលា ព.ស. ២៤៩៤ ជាកស្តុតាងឲ្យឃើញច្បាស់ថា ប្រជាជនខ្មែរទាំងប្រទេសមានចិត្តកក្តីចំពោះព្រះពុទ្ធសាសនាស្រាប់ហើយ ។ ពុទ្ធសាសនាថេរវាទដែលធ្លាប់មានមកពីសម័យព្រេងនាយហើយស្រាប់ ក៏ដែតជាបរហ័សហើយឆ្ងាយខ្លួលាយចូលទៅដល់ចិត្តថ្មើមប្រជាជនគ្រប់ជាន់គ្រប់ថ្នាក់ ។ អស់លោកអ្នកនាំប្រទេសខ្មែរ ព្រះមហាក្សត្រមន្ត្រីតូចធំ ដែលបានយល់តម្លៃពុទ្ធសាសនាថាមានហេតុផលគ្រប់គ្រាន់ល្មមនាំខ្លួនទៅកាន់សេចក្ដីសុខក្សេមក្សាន្តបានក៏ព្រមលះបង់សាសនាដទៃចោលទៅ ជ្រើសសម្រាំងយកតែពុទ្ធសាសនាថេរវាទមួយប៉ុណ្ណោះ ទុកជាសម្បត្តិវប្បធម៌ប្រចាំប្រទេសខ្មែររហូតដល់មកបច្ចុប្បន្នកាលនេះ ។ ក្នុងសម័យអាប់ឱន ប្រជាជនខ្មែរបានពុទ្ធ-សាសនានេះហើយជាសរណៈដ៏ខ្ពង់ខ្ពស់ ជួយកម្រាបភ័យ ជួយសម្រាលលំហែទុក្ខ ដោយជឿកម្មផលច្បាស់ថា ធ្វើល្អ បានល្អ, ធ្វើអាក្រក់ បានអាក្រក់, ហើយខ្ញុំនាំកូនចៅនៅឯក្រោយឲ្យខំកសាងល្អ ដើម្បីកសាងអនាគតឲ្យបានរុងរឿងដូចសម័យព្រេងនាយវិញ ទោះជាលំបាកយ៉ាងណា ក៏ពេញចិត្តរួមសុខទុក្ខជាមួយពុទ្ធសាសនា ទាល់តែកើតទៅជាសុភាសិតប្រចាំជាតិថា "ស៊ូស្លាប់ទៅជា រសធម៌កុំបីបង់" ។

វត្តអារាម ៖– ប្រជុំភូមិខ្មែរនីមួយៗ តែងមានវត្តមួយជាដំរាប សម្រាប់ភិក្ខុសាមណេរអាស្រ័យនៅ ៗ ក្នុងព្រះរាជាណាចក្រទាំងមូល មានប្រជាជនចំនួន៥លាននាក់ មានវត្តចំនួន២៨១៨វត្ត មានភិក្ខុសាមណេរ ៦៨.១៤៥ អង្គ ៗ ប្រជាជនខ្មែរមិនមានទ្រព្យសម្បត្តិស្តុកស្តម្ភទេ អ្នកដែលក្រីក្រ ធ្វើផ្ទះនៅពីឫស្សីប្រក់ស្លឹក តែមានសទ្ធាខ្លាំងក្លាណាស់ ព្រមគ្នាធ្វើបុណ្យផ្កា កឋិនបច្ច័យគ្នាកសាងវត្តអារាម ធ្វើកុដិសាលាដោយគ្រឿងឈើឬឥដ្ឋប្រក់ក្បឿង ធ្វើវិហារដោយឥដ្ឋដែកស៊ីម៉ង់ត៍ដោយច្រើន ៗ សំណង់ទាំងនេះមានការរចនាវិសេសកើតឆាយជាលក្ខណៈការរចនាខ្មែរ ៗ វត្តនីមួយៗតែងមានកុដិបួនយ៉ាងតិច មានសាលាបុណ្យ សាលារៀនសម្រាប់ភិក្ខុសាមណេរ សាលារៀនសម្រាប់កុមារកុមារី មានវិហារដំកល់ព្រះពុទ្ធរូបអង្គធំ ៗ វិហារនេះធំខ្ពស់ជាងសំណង់ឯទៀត កំពូលខ្ពស់ មើលពីចម្ងាយឃើញច្បាស់ នាំឲ្យអ្នកផងស្គាល់ភ្លាមថា នេះជាវត្តអារាមនៃព្រះភិក្ខុសង្ឃព្រះពុទ្ធសាសនា ៗ ការកសាងវត្តអារាមក្តី ការផ្គត់ផ្គង់អាហារគោជនក្តី ជាភារៈនៃទាយកទាយិកាជើងវត្ត ទោះបីអត់ឃ្លានមានក្រ ទោះបីស្រុកទេសកើតចលាចលឬកើតទុរ្ភិក្ស ក៏ភិក្ខុសាមណេរមិនខ្វះខាតអាហារគោជនទេ ៗ

សូម្បីប្រជាជនសាមញ្ញជាអ្នកដំណើរ ជួនជាខ្វះខាតអាហារ អាចសុំអាហារផ្ទះណាមួយតាមផ្លូវបានបរិភោគឆ្អែតស្កប់ស្កល់ ៗ តាមផ្លូវធំៗ មានទំនៀមកសាងសាលាដកមួយ ឬដាំដើមពោធិ៍ដកមួយដើមហែ ៗ តាមផ្លូវ មានពាងទឹក មានអណ្តូងឬស្រះសម្រាប់អ្នកដំណើរ ៗ ទំនៀម

នេះ កើតមានតាំងពីសម័យព្រះបាទជ័យវរ្ម័នទី ៧ ម្ល៉េះ ។ ប្រពៃណីជាកុសលនេះសំដែងឲ្យឃើញថា ប្រជាជនខ្មែរមានចិត្តទូលាយណាស់ ជាចិត្តអ្នកកាន់ព្រះពុទ្ធសាសនា ប្រព្រឹត្តប្រយោជន៍ខ្លួននិងសព្វសត្វទូទៅ មានចាគចេតនាបរិច្ចាគទាន មានមេត្តាករុណាផ្សាយដល់មនុស្សសត្វមិនរើសមុខ ប្រាថ្នាឲ្យមនុស្សសត្វដែលកើតមកក្នុងលោកនេះបានសេចក្តីសុខ ហើយនៅរួមទុក្ខរួមសុខជាមួយគ្នាជាអង្វែងតទៅ ។

ព្រះសង្ឃ.— ភិក្ខុសាមណេរជាបុគ្គលគួរគោរព នរជនណាមួយនឹងប្រមាថមើលងាយពុំបាន មានការគប់គ្រងដោយឡែកពីប្រជាជនសាមញ្ញ ។ ព្រះសង្ឃនៅប្រទេសខ្មែរមានពីរនិកាយគឺ គណៈមហានិកាយ ១ គណៈធម្មយុត្តិកនិកាយ ១ ។ ពេលព្រឹក ភិក្ខុសាមណេរតើនពីព្រលឹម ចូលទៅក្នុងព្រះវិហារ នមស្ការគុណព្រះរតនត្រ័យ បកសកពជពុទ្ធសាសនា សូត្ររំលឹកបឋមពុទ្ធវចនៈ ហើយផ្សាយមេត្តា នេះហៅថាវត្តព្រឹក, តមក បោសសំអាតថែរក្សាវត្តអារាម បិណ្ឌបាត ធ្វើភត្តកិច្ចពេលព្រឹក ហើយចូលទៅសាលារៀន, ថ្ងៃត្រង់ធ្វើភត្តកិច្ច ថ្ងៃរសៀលចូលសាលារៀន ពេលយប់ចូលវិហារទៀត នមស្ការគុណព្រះរតនត្រ័យ បំរើនព្រះបរិត្តនិងព្រះសូត្រផ្សេងៗ មានធម្មចក្កប្បវត្តនសូត្រជាដើម តាមកាលគួរ ហើយផ្សាយមេត្តានេះហៅថាវត្តល្ងាច ។ មានភិក្ខុគាមវាសីច្រើនអង្គ លះបង់បលិពោធក្នុងវត្ត ឆាន់តែមួយថ្ងៃម្ដង ចេញទៅធ្វើជាអរញ្ញវាសី រកទីស្ងាត់ក្នុងព្រៃស្មសានឬព្រៃភ្នំក្រំថ្ម ធ្វើជាអាស្រមដែលគេបំពេញសមណធម៌ ។ អាស្រមសម្រាប់ភិក្ខុធ្វើសមណ-

ធម៌នេះមានច្រើន មានគ្រប់ខេត្តក្នុងព្រះរាជអាណាចក្រ ដទៃពីនេះ ភិក្ខុសាមណេរមានភារៈបង្រៀនកុមារកុមារីអ្នកស្រុកដើងវត្តទៅសាលាក្នុងវត្ត និងមានកិច្ចខ្នាទេសន្ទេសប្រដៅពុទ្ធសាសនិកជន ឲ្យតាំងនៅក្នុងធម៌កុំឲ្យធ្វើបាប ឲ្យបំពេញកុសល ឲ្យធ្វើចិត្តបរិសុទ្ធដែលជាគោលពុទ្ធ-សាសនា ។ ហេតុដូច្នេះហើយ បានជាប្រជាជនខ្មែរគោរពព្រះសង្ឃណាស់ ជីវិតព្រះសង្ឃនិងអ្នកស្រុករួមសុខទុក្ខជាមួយគ្នា ។

**ការគ្រប់គ្រងព្រះសង្ឃ.—** និកាយទាំងពីរខាងលើនេះ មានព្រះមហាក្សត្រទ្រង់ជាព្រះរាជសាសនូបត្ថម្ភក៍ ។ និកាយមួយៗ មានក្បួនការគ្រប់គ្រងដោយឡែកពីគ្នា មានសង្ឃនាយក មេគណ អនុគណ ចៅអធិការ សម្រាប់ត្រួតត្រាភិក្ខុសាមណេរឲ្យប្រព្រឹត្តទៅ តាមវិន័យបញ្ញត្តិព្រះពុទ្ធសាសនា ឡើងទៅក្រសួងធម្មការ ។ មានព្រះរាជក្រមមួយស្តីពីការគ្រប់គ្រងព្រះសង្ឃ ។

គណៈមហានិកាយ មានព្រះមហាថេរមួយអង្គខ្ពស់ផុត ជាសង្ឃ-នាយក មានសមណស័ក្តិជាសម្តេចព្រះមហាសុមេធាធិបតីជាក្បួនការទីស្តីការនៅវត្តឧណ្ណាលោម ព្រះរាជធានីក្រុងភ្នំពេញ មានព្រះមហាថេរមួយអង្គ នាទីជាសម្តេចឧត្តមប្រឹក្សា មានថេរសភាមួយនៅអមស្តីការត្រួតត្រាព្រះសង្ឃគណៈមហានិកាយទូទៅពេញព្រះរាជអាណាចក្រទាំងមូល ។

កុរុធម៌

ក្នុងកុរុធម្មជាតក តិកនិបាត

ព្រះទេពសត្ថា ហ៊ឹម - ស៊ូវ ចន្ទមង្គលោ

ក្រុមជំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ ប្រែរៀបរៀង

(តមក)

---

## ១ — រឿងព្រះពោធិសត្វ

ព្រោះហេតុអ្វីបានជាព្រះបាទធនញ្ជយកោរព្យ: មានព្រះទ័យរង្កៀសក្នុងកុរុធម៌របស់ព្រះអង្គ ?

តាមសេចក្ដីដំណាលថា: កាលនោះ ស្ដេចទាំងឡាយតែងក្រសាលមហោស្រពនៅខែកត្តិក ក្នុងរវាង ៣ ឆ្នាំ ទ្រង់ក្រសាលម្ដង រវាង ៣ ឆ្នាំ ទ្រង់ក្រសាលម្ដង ៗ ព្រះរាជាទាំងឡាយ កាលដែលទ្រង់ក្រសាលមហោស្រពនោះ ទ្រង់ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង, ទ្រង់កាន់យកនូវភេទជាទេវតាឋិតនៅក្នុងសំណាក់នៃយក្សឈ្មោះចិត្តរាជ, ទ្រង់បាញ់សរដែលវិចិត្រប្រដាប់ដោយផ្កាទៅក្នុងទិសទាំង ៤ ៗ ឯព្រះបាទធនញ្ជយកោរព្យ: កាលដែលទ្រង់ក្រសាលមហោស្រពនោះ ក៏ទ្រង់ឋិតនៅក្នុងសំណាក់នៃយក្សឈ្មោះចិត្តរាជ ហើយបាញ់សរដែលប្រដាប់ដោយផ្កាទៅក្នុងទិសទាំង ៤ ៗ សរដែលបាញ់ទៅក្នុងទិសទាំង ៤ នោះ ធ្លាក់ចុះទៅក្នុងទិសទាំង ៤ នោះ ព្រះរាជាទ្រង់រកឃើញតែសរ ៣ ដែលធ្លាក់ចុះទៅក្នុងទិសដទៃ ឯសរដែលបាញ់ធ្លាក់ចុះទៅក្នុងទឹក ទ្រង់រកពុំឃើញ ៗ ព្រះរាជាទ្រង់រង្កៀសក្នុងព្រះទ័យថា "សរមួយដែលអាត្មាអញ

បាញ់ទៅហើយធ្លាក់ចុះទៅក្នុងទឹក ប្រហែលត្រូវសរីរៈនៃត្រីទេដឹង” ។ ព្រះរាជាទ្រង់រំពឹងប្រាថ្នានូវការបែកធ្លាយនៃសីលរបស់ព្រះអង្គ ដោយអំ-ពើបាណាតិបាតយ៉ាងនេះ ព្រោះហេតុនោះបានជាទ្រង់ត្រាស់ថា “ម្នាលអ្នកទាំងឡាយ, យើងមានសេចក្តីរង្កៀសក្នុងកុរុធម៌ដោយហេតុនេះឯង, ឯព្រះមាតារបស់យើងទ្រង់រក្សាកុរុធម៌នោះបរិសុទ្ធល្អ, ចូរអ្នកទាំងឡាយទៅសុំចម្លងកុរុធម៌នោះ អំពីសំណាក់នៃព្រះមាតារបស់យើងចុះ” ។ ពួកព្រាហ្មណ៍និងអមាត្យទាំងនោះក្រាបទូលថា “បពិត្រមហារាជ, ចេតនារបស់ព្រះអង្គឥតមានបំណងថានឹងសម្លាប់សត្វទេ បើដូច្នេះនឹងឲ្យឈ្មោះថាព្រះអង្គធ្វើអំពើបាណាតិបាតពុំបានឡើយ សូមព្រះអង្គប្រទានកុរុធម៌នោះដល់យើងទាំងឡាយចុះ” ។ ព្រះបាទធនញ្ជយកោរព្យៈត្រាស់ថា “បើដូច្នោះ ចូរអ្នកទាំងឡាយកត់ចុះ” ហើយទ្រង់ញុំាងពួកព្រាហ្មណ៍និងអមាត្យទាំងនោះ ឲ្យសរសេរកុរុធម៌នោះក្នុងបន្ទះមាសថា បាណោ ន ហន្តព្វោ (គេមិនត្រូវសម្លាប់សត្វ), អទិន្នំ នាទាតព្វំ (គេមិនត្រូវកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ), កាមេសុ មិច្ឆាចារោ ន ចរិតព្វោ (គេមិនត្រូវប្រព្រឹត្តកាមេសុមិច្ឆាចារៈ), មុសាវាទោ ន ភាសិតព្វោ (គេមិនត្រូវពោលមុសាវាទ), មជ្ជបានំ ន បាតព្វំ (គេមិនត្រូវផឹកនូវទឹកស្រវឹង)” លុះទ្រង់បង្គាប់ឲ្យកត់រួចហើយ ទើបត្រាស់បន្ថែមទៀតថា “បើទុកជាយ៉ាងនេះក៏ដោយ សីលរបស់យើងហាក់ដូចជាពុំសូវស្អាតល្អ

ពុំសូវពេញចិត្តយើងប៉ុន្មានទេ, ចូរអ្នកទាំងឡាយ ទៅសុំចម្ងងក្បួនធម៌នោះក្នុងសំណាក់ព្រះមាតារបស់យើងទៀតចុះ" ។

ពួកទូតទាំងនោះក្រាបបង្គំលាព្រះរាជាហើយ ទៅកាន់សំណាក់ព្រះមាតានៃព្រះពោធិសត្វក្រាបទូលថា "បពិត្រព្រះរាជទេវី, ឮថា ព្រះអង្គទ្រង់រក្សាក្បួនធម៌, សូមទ្រង់ព្រះមេត្តាប្រោសប្រទានក្បួនធម៌នោះដល់ទូលព្រះបង្គំជាខ្ញុំទាំងឡាយ" ។ ព្រះរាជទេវី ទ្រង់ត្រាស់ថា "ម្នាលអ្នកទាំងឡាយ, យើងរក្សាក្បួនធម៌ពិតមែន ប៉ុន្តែឥឡូវនេះ យើងកើតសេចក្ដីរង្កៀសក្នុងក្បួនធម៌, ក្បួនធម៌របស់យើងនោះហាក់ដូចជាពុំសូវហាត់ចត់ប៉ុន្មាន ព្រោះហេតុនោះ យើងពុំហ៊ានឲ្យដល់អ្នកទាំងឡាយឡើយ" ។

## ២ – រឿងព្រះមាតានៃពោធិសត្វ

តាមសេចក្ដីដំណាលថា: បណ្ដាព្រះរាជបុត្តទាំងពីរព្រះអង្គរបស់ព្រះរាជទេវីនោះ, ព្រះរាជបុត្តបងសោយរាជ្យជាស្ដេច, ព្រះរាជបុត្តប្អូនជាឧបរាជ ។ គ្រានោះ មានព្រះរាជាមួយព្រះអង្គផ្ញើខ្លឹមចន្ទន៍តម្លៃមួយសែនកហាបណៈ ទឹងកម្រងផ្កាមាសតម្លៃមួយសែនកហាបណៈដែរមកថ្វាយព្រះពោធិសត្វ។ ក៏យកទៅថ្វាយព្រះមាតាទាំងអស់ទៅ ។ ព្រះមាតានោះទ្រង់គិតថា "អាត្មាអញមិនសមនឹងលុបលាបខ្លឹមចន្ទន៍ប្រដាប់តាក់តែងដោយកម្រងផ្កាមាសនេះទេ គួរតែឲ្យទៅកូនប្រសាទាំងឡាយ" ។ មុននឹងប្រទានព្រះនាងទ្រង់គិតទៀតថា "នាងកូនប្រសាបង គេបានជាធំតាំងនៅក្នុងឋានៈជាអគ្គមហេសី អាត្មាអញគួរឲ្យកម្រងផ្កាមាសដល់នាងកូនប្រសាបង, ឯនាងកូនប្រសាប្អូន មិនសូវមានបុណ្យទ័លក្រជាង គួរ

ឲ្យខ្ញុំមបន្ទំដល់នាងកូនប្រសាប្អូនចុះ" លុះគិតយ៉ាងនេះហើយ ក៏ប្រទានកម្រងផ្កាមាសទៅនាងកូនប្រសាបង, ប្រទានខ្ញុំមបន្ទំទៅនាងកូនប្រសាប្អូន ៗ វេលាដែលប្រទានរួចហើយ ព្រះនាងកើតសេចក្ដីរង្កៀសក្នុងចិត្តថា "អាត្មាអញរក្សាកុរុធម៌ មិនសមបើទៅគិតយកទុគ្គតភាព(១)នឹងអទុគ្គតភាព(២)របស់កូនប្រសាទាំងពីរនោះមកជាប្រមាណសោះ បើធ្វើផលលកទៅតាមជេដ្ឋាបចាយិកកម្មវិញ ទើបជាការដ៏សមគួរដល់អាត្មាអញ, កាលបើដូច្នោះសីលរបស់អាត្មាអញ ប្រហែលជាបែកធ្លាយដោយគំនិតនេះទៅហើយទេដឹង" ៗ ព្រះរាជទេវីទ្រង់ដំណាលរឿងនោះប្រាប់ដល់ទូតទាំងឡាយនោះយ៉ាងនេះឯង ៗ ទូតទាំងឡាយបានស្ដាប់ហើយ ក៏ក្រាបទូលថា "បពិត្រព្រះរាជទេវី, ធម្មតាទ្រព្យរបស់ព្រះអង្គ ទ្រង់នឹងអាចប្រទានដល់អ្នកណា ៗ បានតាមព្រះទ័យ, ទ្រង់មិនគួរធ្វើសេចក្ដីរង្កៀសដោយសព្វបើហេតុប៉ុណ្ណោះទេ ព្រះអង្គនឹងឲ្យឈ្មោះថាទ្រង់ធ្វើបាបកម្មដូចម្ដេចបាន ឯសីលរបស់ព្រះអង្គមិនមែនបែកធ្លាយដោយសារហេតុមានសភាពដូច្នេះឡើយ, សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោស ប្រទានកុរុធម៌ដល់ទូលព្រះបង្គំទាំងឡាយចុះ" លុះក្រាបទូលយ៉ាងនេះហើយ ក៏សូមកត់កុរុធម៌ក្នុងសំណាក់ព្រះរាជទេវី ដាក់ក្នុងដំបាមាសរបស់ខ្លួន ៗ ព្រះរាជទេវីទ្រង់ត្រាស់ថែមទៀតថា "បើទុកជាយ៉ាងនេះក៏ដោយ កុរុធម៌របស់យើងមិនសូវជាហ្មត់ចត់ប៉ុន្មានទេ, ក្រែងតែកូនប្រសាបងរបស់យើងទើបរក្សាកុរុធម៌នោះបរិសុទ្ធល្អ ចូរអ្នកទាំងឡាយទៅសុំចម្លងយកកុរុធម៌ក្នុង

---

១ ភាពជាអ្នកទ័លក្រ ។ ២ ភាពជាអ្នកមិនទ័លក្រ ។

សំណាក់នៃកូនប្រសាច្បងនោះទៀតចុះ" ។ ពួកទូតទាំងនោះចូលទៅគាល់ព្រះអគ្គមហេសីជាកូនប្រសាច្បង ហើយទូលសុំកុរុធម៌តាមន័យដូចមុនដែរ ។ ព្រះអគ្គមហេសីទ្រង់មានព្រះសវនីយ៍ត្អូញត្អែរថា "យើងរក្សាកុរុធម៌ពិតមែន តែឥឡូវនេះ សីលរបស់យើងមិនសូវជាពេញចិត្តយើងប៉ុន្មានទេ ព្រោះហេតុនោះ យើងពុំអាចឲ្យដល់អ្នកទាំងឡាយបានឡើយ" ។

## ៣– រឿងព្រះអគ្គមហេសីនៃពោធិសត្វ

តាមសេចក្ដីដំណាលថា: ថ្ងៃមួយ ព្រះអគ្គមហេសីនោះទ្រង់ឋិតនៅត្រង់សីហបញ្ជរ ទតទៅឃើញព្រះឧបរាជគង់លើខ្នងដំរី ជាខាងក្រោយនៃព្រះរាជាជាព្រះស្វាមីរបស់ព្រះនាង ដែលកំពុងយាងហែប្រទក្សិណព្រះនគរ លុះទតទៅឃើញហើយក៏កើតសេចក្ដីលោភគិតថា "ប្រសិនបើអញផ្ដើមសន្ថវៈជាមួយនឹងព្រះឧបរាជជាប្អូននេះ កាលបើអំណើះតពីស្ដេចបងទៅ, ព្រះឧបរាជបានសោយរាជ្យឡើង ទ្រង់នឹងសង្គ្រោះអញទៀតពុំខាន" ។ បន្ទាប់មក ព្រះនាងកើតសេចក្ដីរង្កៀសក្នុងចិត្តថា "អញរក្សាកុរុធម៌ទាំងមានស្វាមីផង ទៅក្រឡេកមើលបុរសដទៃដោយអំណាចកិលេសដូច្នេះ សីលរបស់អញប្រហែលជាបែកធ្លាយទៅហើយទេដឹង" ។ ព្រះអគ្គមហេសីទ្រង់ដំណាលសេចក្ដីនោះប្រាប់ទូតទាំងឡាយនោះ យ៉ាងនេះឯង ។ ទូតទាំងឡាយក្រាបបង្គំទូលថា "បពិត្រព្រះនាង ការប្រព្រឹត្តិក្បត់ មិនមែនដោយហេតុត្រាន់តែចិត្តកើតឡើងប៉ុណ្ណោះទេ ព្រះនាងធ្វើសេចក្ដីរង្កៀសដោយសព្វបើហេតុប៉ុណ្ណោះ នឹងឲ្យឈ្មោះថាទ្រង់

ធ្វើនូវការប្រព្រឹត្តិកនូវសីលដូចម្តេចបាន, សីលរបស់ព្រះនាងមិនបែក ធ្លាយដោយសារហេតុប៉ុណ្ណោះទេ, សូមទ្រង់ព្រះមេត្តាប្រោសប្រទាន កុរុធម៌ដល់ទូលព្រះបង្គំទាំងឡាយចុះ" ។ ពួកទូតទាំងនោះ លុះក្រាប ទូលយ៉ាងនេះហើយ ក៏សូមកត់កុរុធម៌ក្នុងសំណាក់នៃព្រះអគ្គមហេសីដាក់ ក្នុងដំបាមាស ប៉ុន្តែព្រះអគ្គមហេសីនោះ ទ្រង់ត្រាស់ទៀតថា "បើទុក ជាយ៉ាងនេះក៏ដោយ សីលរបស់យើងមិនសូវបរិសុទ្ធពេញចិត្តយើងប៉ុន្មាន ទេ ឯព្រះឧបរាជទ្រង់រក្សាកុរុធម៌បរិសុទ្ធល្អ សូមអ្នកទាំងឡាយទៅសុំ កត់ក្នុងសំណាក់ព្រះឧបរាជនោះទៀតចុះ" ។ ទូតទាំងឡាយនោះចូល ទៅគាល់ព្រះឧបរាជ ទូលសុំកុរុធម៌តាមន័យដូចមុន ។

## ៤ — រឿងព្រះឧបរាជ

សេចក្តីដំណាលថា: ព្រះឧបរាជនោះយាងទៅគាល់ព្រះរាជាក្នុង វេលាល្ងាច តែងទ្រង់យាងទៅដោយរាជរថ លុះដល់លានព្រះរាជវាំង ហើយ បើមានព្រះរាជបំណងនឹងសោយព្រះក្រយាស្ងោយហើយផ្ទុំក្នុង ព្រះរាជដំណាក់នៃព្រះរាជានោះ ទ្រង់តែងដាក់ខ្សែរនឹងជន្ទញបោល ត្រង់បង្ខោះទូកព្រះរាជរថ ។ ពួកមហាជនជាបរិវារដឹងដោយសញ្ញានោះ ហើយក៏នាំគ្នាថយចេញទៅ លុះដល់ថ្ងៃស្អែកឡើងពេលព្រឹក ទើបនាំគ្នា ទៅនៅរង់ចាំមើលព្រះរាជដំណើរនៃព្រះឧបរាជនោះដែលទ្រង់នឹងយាង ចេញមកវិញ ឯនាយសារថីក៏ដូច្នោះដែរ ។ តែបើព្រះឧបរាជមានព្រះ បំណងនឹងយាងចេញមកក្នុងខណៈនោះវិញ ទ្រង់ដាក់ខ្សែរនឹងជន្ទញ លើបង្ខោះត្លុករាជរថហើយ ទើបយាងចូលទៅគាល់ព្រះរាជា ។ ពួកមហាជន

បានដឹងដោយសញ្ញានោះហើយ ក៏នាំគ្នាទៅរង់ចាំត្រង់ព្រះរាជទ្វារដោយគិតថា ព្រះឧបរាជនឹងយាងចេញមកឥឡូវនេះវិញ ៗ ថ្ងៃមួយ, ព្រះឧបរាជទ្រង់ធ្វើយ៉ាងនេះហើយ ក៏យាងចូលទៅកាន់ព្រះរាជនិវេសន៍, ក្នុងវេលាដែលទ្រង់យាងចូលផុតទៅ ភ្លៀងក៏បង្អុរចុះមក ៗ ព្រះរាជាទ្រង់យល់ថា នៅកំពុងភ្លៀង មិនបើកឱកាសឲ្យព្រះឧបរាជនោះចេញមកវិញ, ព្រះឧបរាជទ្រង់សោយក្រយាស្ងោយរួចហើយ ក៏ផ្ទុំក្នុងព្រះរាជនិវេសន៍នោះទៅ ៗ ឯពួកមហាជន នៅឈរត្រៀមចាំហាលភ្លៀងអស់មួយយប់ដោយគិតថា ព្រះឧបរាជនឹងយាងចេញមកឥឡូវនេះ ៗ លុះដល់ថ្ងៃទីពីរព្រលឹមឡើង, ព្រះឧបរាជ ទ្រង់យាងចេញមក ឃើញមហាជននៅត្រៀមចាំទទឹកសើមដោយទឹកភ្លៀង ក៏កើតសេចក្ដីរង្កៀសថា "ឱ, អញរក្សាកុរុធម៌ធ្វើឲ្យគេបានសេចក្ដីលំបាកដោយសារខ្លួនយ៉ាងនេះ សីលរបស់អញប្រហែលបែកធ្លាយទៅហើយដឹង" ៗ ព្រះឧបរាជលុះដំណាលរឿងនោះប្រាប់ទូតទាំងឡាយទើបត្រាស់ថា "យើងរក្សាកុរុធម៌ពិតមែន ប៉ុន្តែឥឡូវនេះយើងមានសេចក្ដីរង្កៀសចិត្តក្នុងកុរុធម៌ដោយហេតុនេះឯង យើងពុំអាចឲ្យដល់អ្នកទាំងឡាយបានឡើយ" ៗ ខណៈនោះ ទូតទាំងឡាយក្រាបទូលថា "សូមទ្រង់ព្រះមេត្តាប្រោស, បើព្រះទ័យរបស់ព្រះអង្គមិនមានបំណងចង់ឲ្យគេលំបាកសោះទេ តើនឹងឲ្យឈ្មោះថាព្រះអង្គទ្រង់ប្រព្រឹត្តល្មើសក្នុងសីលដូចម្ដេចបាន", លុះក្រាបទូលដូច្នេះហើយក៏សូមកត់កុរុធម៌ក្នុងសំណាក់ព្រះឧបរាជនោះទុកក្នុងផ្ទាំងមាស ៗ ព្រះឧបរាជទ្រង់ត្រាស់ថែមទៀតថា "បើទុកជាយ៉ាងនេះក៏ដោយ សីលរបស់យើង

មើលទៅមិនសូវជាពេញលេញប៉ុន្មានទេ, បំណែកខាងព្រាហ្មណ៍ឯណោះ ទើបរក្សាក្រុធម៌បរិសុទ្ធល្អ ចូរអ្នកទាំងឡាយទៅកត់យកអំពីព្រាហ្មណ៍នោះចុះ" ។ ពួកទូតទាំងនោះចូលទៅរកព្រាហ្មណ៍ សូមក្រុធម៌តាមន័យដូចមុន ។

## ៥– រឿងបុរោហិត

តាមសេចក្ដីដំណាលថា: ថ្ងៃមួយ បុរោហិតនោះទៅគាល់ព្រះរាជា លុះទៅដល់ពាក់កណ្ដាលផ្លូវ បានឃើញរថមានពណ៌ក្រហមស្រស់ដែលស្ដេចមួយព្រះអង្គបានផ្ញើមកថ្វាយព្រះរាជារបស់ខ្លួននោះ ហើយសួរគេថា រថនេះជារបស់អ្នកណា? គេក៏ប្រាប់ថា រថនេះគឺព្រះរាជារបស់យើងឲ្យនាំមកថ្វាយព្រះរាជារបស់លោក ។ បុរោហិតនោះបានស្ដាប់ហើយក៏គិតថា "អញចាស់, ប្រសិនបើព្រះរាជាទ្រង់ប្រទានរថនេះមកអញ ៗ ជិះរថនេះធ្វើដំណើរទៅមក ប្រហែលជាបានសុខស្រួលណាស់", លុះគិតយ៉ាងនេះហើយ ក៏ហួសទៅគាល់ព្រះរាជាទៅ ។ ក្នុងខណៈដែលបុរោហិតកំពុងអង្គុយគាល់, ជនទាំងឡាយនាំយករថទៅថ្វាយព្រះរាជា ។ ទ្រង់ទតឃើញក៏ត្រាស់ថា "រថនេះល្អណាស់, ចូរអ្នកទាំងឡាយឲ្យរថនេះទៅបុរោហិតជាអាចារ្យរបស់យើងចុះ" ។ បុរោហិតប្រកែកមិនព្រមទទួលយក ទោះបីព្រះរាជាទ្រង់ត្រាស់ជាញឹកញយយ៉ាងណា ក៏នៅតែមិនព្រមទទួលយកដោយដាច់ខាត ព្រោះបុរោហិតនោះគិតយ៉ាងនេះថា "អាត្មាអញកំពុងរក្សាក្រុធម៌ កើតសេចក្ដីលោភក្នុងទ្រព្យជារបស់អ្នកដទៃ, សីលរបស់អាត្មាអញបែកធ្លាយទៅហើយទេដឹង" ។ បុរោហិតប្រាប់សេចក្ដីនោះដល់ទូតទាំងឡាយយ៉ាងនេះហើយទើបនិយាយថា "ខ្ញុំមានសេចក្ដីរង្កៀសក្នុង

កុរុធម៌ ៗ របស់ខ្ញុំប្រហែលជាមិនសូវហ្មត់ចត់ប៉ុន្មានទេ ព្រោះហេតុនោះ ខ្ញុំពុំអាចឲ្យដល់អ្នកទាំងឡាយបានឡើយ" ៗ ទូតទាំងឡាយពោលនឹងបុរោហិតនោះថា "សីលរបស់លោកមិនបែកធ្លាយដោយគ្រាន់តែកើតលោកចិត្តប៉ុណ្ណោះទេ លោកមានសេចក្ដីរង្កៀសដោយសព្វបើហេតុប៉ុណ្ណោះនឹងឲ្យឈ្មោះថា ប្រព្រឹត្តកន្ទង់សីលដូចម្ដេចបាន", លុះពោលយ៉ាងនេះហើយ ក៏សុំកត់កុរុធម៌ក្នុងសំណាក់នៃបុរោហិតនោះទុកក្នុងដំបាមាស ៗ បើទុកជាយ៉ាងនេះក៏ដោយបុរោហិតក៏នៅតែត្អូញត្អែរថា "សីលរបស់ខ្ញុំមិនសូវជាហ្មត់ចត់ណាស់ណាទេ ឯរជ្ជុគ្គាហៈអមាត្យ (អមាត្យកាន់ក្រសួងវាស់ដី) ទើបរក្សាកុរុធម៌បរិសុទ្ធល្អ, ចូរអ្នកទាំងឡាយ ទៅសុំយកកុរុធម៌ក្នុងសំណាក់នៃរជ្ជុគ្គាហៈអមាត្យនោះចុះ" ៗ ពួកទូតទាំងនោះចូលទៅរករជ្ជុគ្គាហៈអមាត្យសូមកុរុធម៌តាមន័យដូចមុនដែរ ៗ

## ៦ – រឿងរជ្ជុគ្គាហៈអមាត្យ

សេចក្ដីដំណាលថាថ្ងៃមួយ, រជ្ជុគ្គាហៈអមាត្យចេញទៅវាស់ដីស្រែក្នុងជនបទ ចងខ្សែនឹងបង្គោល ឲ្យអ្នកម្ចាស់ស្រែកាន់ចុងខ្សែម្ខាង ខ្លួនឯងកាន់ចុងខ្សែម្ខាង, បង្គោលដែលចងដោយចុងខ្សែម្ខាងដែលរជ្ជុគ្គាហៈអមាត្យកាន់បោះចុះទៅនោះ ត្រូវចំពាក់កណ្ដាលរូងក្ដាមមួយ ៗ រជ្ជុគ្គាហៈអមាត្យគិតថា "បើអញនឹងបោះបង្គោលលើរូងក្ដាមនេះ, ក្ដាមដែលនៅខាងក្នុងរូងមុខជានឹងវិនាស, តែបើនឹងបោះហួសទៅខាងមុខ, ប្រយោជន៍របស់ស្ដេចនឹងខូចខាត, បើនឹងបោះថយមកខាងអាយ, ប្រយោជន៍របស់អ្នកម្ចាស់ស្រែនឹងខូចខាត; កាលបើដូច្នេះ តើអញគួរលៃលក

យ៉ាងណា" ។ វដ្ដគាហៈអមាត្យគិតទៀតថា "បើក្ដាមមាននៅក្នុងរូងមែន មុខជាឲ្យដឹងដោយហេតុណាមួយ", លុះគិតហើយក៏បោះបង្គោលនោះចំទៅលើរូងក្ដាមៗ ក៏ធ្វើសំឡេងក្រិៗ ។ វដ្ដគាហៈអមាត្យលុះឮហើយក៏គិតថា បើបង្គោលនេះលិចចុះទៅលើខ្នងក្ដាមៗ មុខជានឹងស្លាប់ ឯអញក៏ពុំរក្សាកុរុធម៌ កាលបើដូច្នេះសីលរបស់អញប្រហែលជាបែកធ្លាយហើយ" ទើបប្រាប់សេចក្ដីនេះដល់ទូតទាំងនោះថា "ខ្ញុំមានសេចក្ដីរង្កៀសក្នុងកុរុធម៌ដោយហេតុនេះឯង, ដូច្នេះខ្ញុំពុំឲ្យកុរុធម៌ដល់អ្នកទាំងឡាយឡើយ" ។ ទូតទាំងឡាយពោលថា "បើចិត្តរបស់លោកគ្មានបំណងនឹងឲ្យក្ដាមនោះស្លាប់ទេ, អំពើដែលធ្វើដោយឥតចេតនាដូច្នេះមិនមែនឈ្មោះថាបាណាតិបាត-កម្មទេ, លោកគ្រាន់តែមានសេចក្ដីរង្កៀសចិត្តដោយហេតុប៉ុណ្ណោះ នឹងឲ្យឈ្មោះថាប្រព្រឹត្តកន្លងសីលដូចម្ដេចបាន" លុះពោលដូច្នេះហើយក៏សុំកត់កុរុធម៌ក្នុងសំណាក់នៃវដ្ដគាហៈអមាត្យនោះទុកក្នុងបន្ទះមាស ។ វដ្ដ-គាហៈអមាត្យក៏ពោលថែមទៀតថា "បើទុកជាយ៉ាងនេះក៏ដោយ សីលរបស់ខ្ញុំមិនសូវជាហ្មត់ចត់ប៉ុន្មានទេ, ឯនាយសារថីទើបរក្សាកុរុធម៌បរិសុទ្ធល្អ, ចូរអ្នកទាំងឡាយទៅចំឡងយកក្នុងសំណាក់នៃនាយសារថីនោះទៀតចុះ" ។ ពួកទូតទាំងនោះក៏ចូលទៅរកនាយសារថីសូមកុរុធម៌តាមន័យដូចមុនដែរ ៗ

(មានត)

# ត្រៃវចនកថា

## លោក ឯង-ប៉ង់ នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

---

បាបគឺអ្វី? កុសលគឺអ្វី? ចិត្តគឺអ្វី?

អំពើអាក្រក់ដែលកើតអំពីកាយ វាចា ចិត្ត ហៅថា បាប ។

ធម៌ដែលជាគ្រឿងកំចាត់បង់អំពើអាក្រក់ ហើយញុំាងសេចក្ដីល្អខាងផ្លូវកាយ វាចា ចិត្ត ឲ្យកើតមានឡើង ហៅថា កុសល ។

ធម្មជាតសម្រាប់សន្សំនូវអារម្មណ៍ ឬ សម្រាប់គិត ហៅថា ចិត្ត ។

ខ្ញុំសូមអធិប្បាយអំពីធម៌ទាំង ៣ នេះ ដូចតទៅនេះ ៖

ឱវាទរបស់អ្នកប្រាជ្ញទាំងឡាយតាំងពីអតីតកាលរហូតមកក្នុងបច្ចុប្បន្ននេះ សឹងរួបរួមក្នុងពាក្យថា “**បាប**, កុសល, ចិត្ត” នេះឯង; ដែលមានប្លែកគ្នាតែត្រង់ឱវាទខ្លះសង្ខេប, ខ្លះពិស្ដារ, ខ្លះរាក់, ខ្លះល្អិតជ្រាលជ្រៅប៉ុណ្ណោះ; បើសង្ខេបមកនៅត្រង់មិនឲ្យធ្វើបាប ឲ្យសន្សំតែបុណ្យកុសល ឲ្យអប់រំចិត្តឲ្យល្អ សមដូចនិពន្ធគាថា ក្នុងឱវាទ**បាតិមោក្ខ**ថា:

សព្វបាបស្ស អករណំ   កុសលស្សូបសម្បទា
សចិត្តបរិយោទបនំ   ឯតំ ពុទ្ធាន សាសនំ

“ការមិនធ្វើបាបទាំងពួង ១ ការបំពេញកុសល ១ ការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ ១ ទាំង ៣ នេះជាពុទ្ធសាសនៈ” ។

អធិប្បាយៈ ១- បាប គឺធម៌ដ៏លាមក ដែលជាហេតុញ៉ាំងអ្នកប្រព្រឹត្តឲ្យទៅកាន់អបាយ ទុគ្គតិ ហៅថា បាប ។ បាបនោះ បើសំដែងតាមឫសគល់បានខាងលោភៈ (សេចក្ដីជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ), ទោសៈ (សេចក្ដីក្រោធខឹងប្រទុស្ដដល់សត្វនិងសង្ខារ). មោហៈ (សេចក្ដីវង្វេងកាន់ប្រឡំមិនដឹងសេចក្ដីពិត) ។ ទាំង៣នេះ ជាមូលហេតុគឺជាឫសគល់នៃបាប ឧទាហរណ៍ ដូចបុគ្គលធ្វើទុច្ចរិតទាំង៥ គឺសម្លាប់សត្វ, លួចទ្រព្យគេ, ប្រព្រឹត្តខុសក្នុងកាម, និយាយកុហក, ផឹកសុរានិងមេរ័យក៏ព្រោះតែលោភៈទោសៈនិងមោហៈ ។

បើសំដែងតាមកម្មមាន ៣ គឺកាយកម្ម (អំពើដែលកើតឡើងដោយកាយ), វចីកម្ម (អំពើដែលកើតឡើងដោយវាចា), មនោកម្ម (អំពើដែលកើតឡើងដោយចិត្ត) ។ កម្មទាំង ៣ នេះចែកជា ២ គឺជាកុសលនិងអកុសល, ចំណែកកម្មជាអកុសលគឺអំពើអាក្រក់អាចឲ្យទោសក្នុងអនាគតក៏មាន, ឲ្យទោសឃើញច្បាស់ទាន់ភ្នែកក្នុងជាតិនេះក៏មាន ដូចសម្លាប់មនុស្សឬសត្វតិរច្ឆាន, បើសម្លាប់យូរខែយូរឆ្នាំទៅ ក៏អាចឲ្យផលអាក្រក់ក្នុងជាតិនេះ ដូចបុរសម្នាក់ឈ្មោះចុន្ទសូករិកៈ ដែលមានជីវភាពដោយការសម្លាប់ជ្រូកលក់, សូមនាំរឿងនោះមកសំដែងដោយសេចក្ដីសង្ខេប ជាសំអាងដូចតទៅនេះ ៖

សម័យមួយក្នុងនគររាជគ្រឹះ មានបុរសម្នាក់ឈ្មោះចុន្ទសូករិកៈជាអ្នកសម្លាប់ជ្រូកយកសាច់លក់ ចិញ្ចឹមជីវិតពេញ ៥៥ ឆ្នាំ ។ កាលដែលសម្លាប់ម្ដងៗ គាត់យកទឹកក្ដៅពុះទៅចាក់បន្សុកក្នុងមាត់ជ្រូក ។ លុះជ្រូក

នោះស្លាប់ហើយ   គាត់យកដំបង ៤ ជ្រុងទៅវាយសំពន់ដុំសាច់ឲ្យណែន ដើម្បីថ្លឹងឲ្យមានទម្ងន់លក់បានថ្លៃ ៗ ដល់សម័យគាត់មានជម្ងឺ អំពើនោះ ក៏បណ្ដាលឲ្យភ្លើងអំពីអវិចិមហានរកឆេះឡើងមក   ដុតពេលគាត់ឲ្យក្ដៅ អន្ទះអន្ទែងស្ទុះបម្រះនទៀលឆ្វេងឆ្វាក់ទៅមកដោយក្បាលជង្គង់ ស្រែកយំ មានសំឡេងដូចជ្រូក   រងទុក្ខវេទនាអស់ ៧ ថ្ងៃ   ទើបស្លាប់ទៅកើតក្នុង នរកមហាអវិចី   នេះមកអំពីធ្វើអំពើអាក្រក់ ៗ

២ - កុសល   បានដល់ធម៌ជាគ្រឿងកំចាត់បង់សេចក្ដីអាក្រក់, ការព្យាយាមធ្វើសេចក្ដីល្អនោះឲ្យកើតមានឡើង ហៅថា បំពេញកុសល ឲ្យបរិបូណ៌ ៗ បើសំដែងដោយសង្ខេប កុសលនោះមានលក្ខណៈឬវត្ថុជា ទីតាំងឲ្យកើតឡើង មាន ៣ គឺ ទាន: ការបរិច្ចាគវត្ថុឲ្យដល់បុគ្គលដទៃ ដែលគួរឲ្យ ១, សីល: ការរក្សាកាយវាចាឲ្យរៀបរយ ១, ភាវនា ការចំរើនឬទឹកចំពោះត្រង់អារម្មណ៍ដ៏ល្អ១ ៗ

បើនិយាយដោយពិស្ដារបានដល់   បុញ្ញកិរិយាវត្ថុ ១០ យ៉ាង គឺ ១ – បុណ្យកើតមានព្រោះការឲ្យទាន, ២ – ព្រោះការរក្សាសីល, ៣ – ព្រោះការចំរើនធម៌ដែលគួរចំរើនឲ្យកើតមានក្នុងចិត្ត,   ៤ – ព្រោះការ គោរពកោតក្រែងនូនលំទោន ជឿស្ដាប់បុគ្គលដែលគួរគោរព, ៥ – ព្រោះ ការខ្នះខ្នែងខ្វល់ខ្វាយចាត់កិច្ចការបុណ្យ ឬ បំរើក្នុងការធ្វើបុណ្យ, ៦ - ព្រោះ ការសំដែង ឬពន្យល់ធម៌ឲ្យគេស្ដាប់   ឬបង្រៀនឲ្យគេបានចេះដឹងធម៌ផង, ៧ – ព្រោះការស្ដាប់ធម៌ដោយគោរព,   ៨ – ព្រោះការឲ្យចំណែក បុណ្យគឺជូន   ឬឧទ្ទិសចំណែកបុណ្យដែលខ្លួនបានហើយ   ឲ្យទៅអ្នក

ដទៃ, ៩ – ព្រោះការត្រេកអរទទួលយកចំណែកបុណ្យដែលគេឲ្យមកខ្លួន, ១០ – ព្រោះការធ្វើសេចក្ដីយល់ឃើញរបស់ខ្លួនឲ្យត្រូវត្រង់តាមផ្លូវពិត គឺធ្វើប្រាជ្ញាជាសម្មាទិដ្ឋិឲ្យកើតមានក្នុងសន្ដាន ។

កុសលនេះ អាចឲ្យសម្រេចនូវលទ្ធផលដ៏ល្អក្នុងបច្ចុប្បន្ននេះក៏មាន, ក្នុងអនាគតក៏មាន ដូចឧបាសិកាម្នាក់ឈ្មោះខុជ្ជុត្តរា បានជាអាចារ្យធំក្នុងព្រះរាជវាំងនៃព្រះបាទឧទេនក្នុងនគរកោសម្ពី. សូមនាំរឿងនោះមកសំដែងដោយសង្ខេបជាឧទាហរណ៍ដូចតទៅនេះ ៖

ក្នុងកាលដ៏យូរទៅហើយ មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី, មានព្រះបច្ចេកពុទ្ធជាច្រើនអង្គនៅក្នុងនគរនោះ, ក្នុងចំណោមព្រះបច្ចេកពុទ្ធទាំងនោះមានព្រះបច្ចេកពុទ្ធមួយព្រះអង្គព្រះបិដ្ឋគម (ខ្នងគម) ។

ថ្ងៃមួយ គេនិមន្តព្រះបច្ចេកពុទ្ធទាំងនោះ ឲ្យគង់ក្នុងព្រះរាជដំណាក់, មុនដំបូងគេដាក់បាយាសពេញ ១ បាត្រ ហើយប្រគេនថ្វាយព្រះហស្ត ឥតមានវត្ថុអ្វីជាទ្រនាប់សោះ ។ ដោយបាយាសក្ដៅ ៗ ពេញបាត្រពេក ព្រះបច្ចេកពុទ្ធទាំងនោះក៏ប្រែបង្វិលបាត្រញយ ៗ, ស្រីម្នាក់ជាអ្នកបំរើព្រះបច្ចេកពុទ្ធទាំងនោះបានឃើញដូច្នោះ ក៏ប្រគេនវង្វេលភ្លុក ៨ របស់ខ្លួនចំពោះព្រះបច្ចេកពុទ្ធទាំងនោះ ឲ្យលោកដាក់បាត្រលើវង្វេលនោះ ហើយកាន់និមន្តទៅឯញកក្នំនទទួល ។ លុះនាងរំលាងខន្ធទៅ, ដោយផលនៃកុសលគឺការប្រគេនវង្វេលភ្លុកឲ្យជាទ្រនាប់បាត្រដល់ព្រះបច្ចេកពុទ្ធ

ទាំងនោះ បណ្ដាលឲ្យនាងបានទៅកើតក្នុងក្រុមនៃព្រះនាងសាមាវតី[១] ជាធីតានៃឃោសកសេដ្ឋី ជាអគ្គមហេសីនៃព្រះបាទឧទេនក្នុងនគរកោសម្ពី ។ គ្រាន់តែបានស្ដាប់ធម្មទេសនានៃព្រះសាស្ដាប៉ុណ្ណោះ នាងក៏បានសម្រេចសោតាបត្តិផលព្រមទាំងបដិសម្ភិទា ចេះចាំព្រះត្រៃបិដកទាំងមូល ហើយបានជាអាចារ្យសំដែងធម៌ឲ្យពួកស្រីក្នុងព្រះរាជវាំងស្ដាប់ ជាឯតទគ្គៈខាងពហុស្សូត្រ, នេះជាគុណនៃកុសលធម៌ដែលសំដែងមកហើយខាងដើមនេះឯង ។

៣ – ចិត្ត គឺធម្មជាតដែលគិតនូវអារម្មណ៍ផ្សេងៗ; ការដែលធ្វើចិត្តរបស់ខ្លួនឲ្យល្អបរិសុទ្ធដោយសព្វគ្រប់ ដរាបដល់បានសម្រេចមគ្គផលមានអរហត្តជាទីបំផុត ហៅថា ការធ្វើចិត្តឲ្យផូរផង់ ។ ចិត្តជាធម្មជាតដ៏ល្អិតមិនមានរូបរាងសណ្ឋានទ្រង់ទ្រាយពណ៌យ៉ាងណាទេ គ្រាន់តែជានាមម្យ៉ាង ។ ចិត្តជារបស់ប្រែប្រួលឃ្លេងឃ្លោងរហ័សណាស់ ដូនកាលជាយ៉ាងនោះ ដូនកាលជាយ៉ាងនេះ ។ ព្រោះហេតុនោះបានជាព្រះមានព្រះភាគទ្រង់ត្រាស់ថា ចិត្តំ ភិក្ខវេ អទន្តំ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានទូន្មាន មិនបានគ្រប់គ្រងជាដើម រមែងប្រព្រឹត្តទៅដើម្បីវិនាសយ៉ាងធំ ចិត្តំ ភិក្ខវេ ទន្តំ ម្នាលភិក្ខុទាំងឡាយ ចិត្តនេះ បើបុគ្គលបានទូន្មានបានគ្រប់គ្រងជាដើម តែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ធំ ។

---

១ នាងសាមាវតីនេះ បិតាបង្កើតរបស់នាងគឺភទ្ទវតិយសេដ្ឋី នៅក្នុងភទ្ទវតិយនគរ, វេលាស្រុកកើតអហិវាតរោគ បិតាមាតានឹងនាងរត់ចេញពីនគរនោះមកសំណាក់នូវទីជិតផ្ទះឃោសកសេដ្ឋី ។ លុះបិតាមាតាធ្វើមរណកាលហើយ ឃោសកសេដ្ឋីក៏យកនាងទៅចិញ្ចឹម ទុកដូចជាធីតាបង្កើតរបស់ខ្លួន ។

ទុក្ខនិងសុខដែលកើតឡើងក៏ព្រោះចិត្តដែរ, បុគ្គលធ្វើកិច្ចការអ្វី ៗ ដោយកាយក្តី ដោយវាចាក្តី ក៏ព្រោះចិត្តរិះគិតផ្តើមឡើងជាមុនទើបធ្វើបាន, កាលបើចិត្តរិះគិតត្រូវហើយ កិច្ចការនោះក៏បានលទ្ធផលល្អ ថែមទាំងមានសេចក្តីចំរើនដល់ខ្លួនផង, បើចិត្តរិះគិតខុសហើយ កិច្ចការនោះក៏មិនសម្រេចលទ្ធផលល្អ ថែមទាំងមានសេចក្តីទុក្ខដល់ខ្លួនផង ។ ចិត្តនេះជាធម្មជាតដឹកនាំលោកគឺសត្វឲ្យប្រព្រឹត្តអាក្រក់ ឬឲ្យប្រព្រឹត្តល្អបាន សមដូចសុភាសិតថា:

ចិត្តេន និយតិ លោកោ ចិត្តេន បរិកស្សតិ
ចិត្តស្ស ឯកធម្មស្ស សព្វេវ វសមន្វគូ

សេចក្តីថា: "សត្វលោកគឺចិត្តដឹកនាំទៅបាន ចិត្តបំពេញសត្វលោកទៅបាន លោកទាំងអស់នៅក្នុងអំណាចនៃធម៌ ១ គឺចិត្ត" ។

ព្រោះហេតុនោះ បណ្ឌិតជនគប្បីធ្វើចិត្តឲ្យមានសមាធិ គឺបង្ខាំងចិត្តឲ្យនឹងធឹងកុំឲ្យស្ទុះទៅកាន់អារម្មណ៍ដ៏អាក្រក់ ឲ្យឃើញថាសង្ខារទាំងឡាយសុទ្ធតែមិនទៀង ជាទុក្ខជាអនត្តា ឲ្យកើតសេចក្តីនឿយណាយចាកសេចក្តីសៅហ្មង, ដ្បិតថាចិត្តនេះមិនមែននឹងធឹងឯងបានទេ លុះតែខំពត់ខ្លួនទើបនឹងធឹងបាន ។ សមដូចពុទ្ធភាសិតថា:

សុទុទ្ទសំ សុនិបុណំ យត្ថកាមនិបាតិនំ
ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ

សេចក្ដីថាៈ "មេធាវីជនគួរខំបីបាច់រក្សាចិត្ត ដែលឃើញបានដោយកម្រ ដែលល្អិតពន់ពេក ដែលលង់ទៅក្នុងអារម្មណ៍ឯណាមួយហើយ មិនងាយនឹងទាញឲ្យងាកចេញមកវិញបាន, ចិត្តដែលអ្នកមានប្រាជ្ញាបានថែរក្សាហើយ តែងនាំសុខមកឲ្យ" ។

កម្ពស់អំពើល្អនឹងអាក្រក់គ្រប់យ៉ាង ដែលជំរុញសត្វឲ្យបានសុគតិនឹងទុគ្គតិក៏ដោយសារចិត្ត, ព្រោះចិត្តជាធំក្នុងរូបកងកាយទាំងអស់ ដូចជាព្រះបាទអសោកមហារាជទ្រង់ធ្វើបុណ្យកុសលច្រើនជាអនេក គ្មានអ្នកណាធ្វើប្រៀបផ្ទឹមនឹងព្រះអង្គទេ គ្រាន់តែខ្ចិលព្រះទ័យបន្តិចក៏នាំឲ្យទៅកើតក្នុងទុគ្គតិ, សូមនាំយករឿងនោះមកសំដែងដោយសេចក្ដីសង្ខេបដូចតទៅនេះ ៖

សម័យមួយនោះក្នុងក្រុងបាតលិបុត្រ គឺប្រទេសឥណ្ឌាសព្វថ្ងៃនេះ មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមវិន្ទុសារ មានអំណាចគ្របដណ្ដប់លើខែត្រតូចធំជាច្រើន ទ្រង់មានព្រះរាជឱរសច្រើនព្រះអង្គ តែទ្រង់សព្វព្រះទ័យនឹងព្រះរាជឱរសមួយព្រះអង្គ ទ្រង់ព្រះនាមអសោកៈ ដែលមានសេចក្ដីអង់អាចជាងព្រះរាជឱរសឯទៀត ក៏ទ្រង់តាំងដំណែងងារឲ្យជាឧបរាជ, ដំបូងទ្រង់ឲ្យទៅគ្រប់គ្រងក្រុងតក្កសិលា តែខាងក្រោយមកទ្រង់ឲ្យទៅគ្រប់គ្រងស្រុកមាលវៈ ។ គ្រាកាលព្រះវររាជបិតាទ្រង់ទិវង្គតហើយ ព្រះអសោកជារាជឱរសក៏បានជាស្ដេចសោយរាជ្យស្នងព្រះអង្គឡើង ក្នុងពុទ្ធសករាជ ២៧៤ ឆ្នាំ គឺ ៤ ឆ្នាំខាងក្រោយព្រះបាទវិន្ទុសារទិវង្គត ។ ព្រះបាទអសោកនោះ តាំងពីបានសោយរាជ្យឡើង

កាលណាទ្រង់ធ្វើសង្គ្រាមជាច្រើនផង ផ្សាយអំណាចតេជានុភាពរបស់ព្រះអង្គចេញទៅ ព្រះអង្គជាស្ដេចមានបុណ្យធំបំផុតតែលែងជាងស្ដេចឯទៀត ៗ ទ្រង់ផ្សាយអំណាចចេញទៅគ្រប់ប្រទេសក្នុងឥណ្ឌាទាំងមូលរហូតដល់ទន្លេគោធាវរី ។

ព្រះបាទអសោកៈ មិនគ្រាន់តែផ្សាយអាណាចក្រទៅលើអាណា-ខេត្រប៉ុណ្ណោះទេ ថែមទាំងបានផ្សាយព្រះពុទ្ធសាសនាដោយសេចក្ដីជ្រះថ្លា ដែលជាកិត្តិគុណដល់ទ្វីបអាស៊ីទាំងមូលទៀតផង ។

ក្នុងគម្ពីរមហាវង្ស សំដែងថា ព្រះបាទអសោក កាលដែលព្រះអង្គបានរាជាភិសេកជាស្ដេចក្នុងក្រុងបាតលិបុត្រហើយ ទ្រង់មានបុណ្យានុ-ភាពផ្សាយទៅលើមួយយោជន៍, ទៅក្រោមមួយយោជន៍ មានពួកទេវតា, នាគ, យក្ស, មនុស្ស, សត្វចតុប្បាទនឹងទ្វេបាទចូលគាល់បំរើទ្រង់ជានិច្ច ទ្រង់បានសោយរាជ្យ ជាស្ដេចចក្រពត្តិសម្បូណ៌សេចក្ដីសុខ ដោយរាជបរិស័ទទាំងអស់ទំនុកបំរុងមិនឲ្យធ្ងន់ព្រះហ្ឫទ័យ ។

ព្រះបាទអសោកនោះទ្រង់បានបរិច្ចាគនិច្ចភត្តដល់ព្រះភិក្ខុសង្ឃទាំងឡាយ ទ្រង់បរិច្ចាគព្រះរាជទ្រព្យ ៩៦ កោដិសាងព្រះវិហារ ៨៤.០០០, ទ្រង់បានអញ្ជើញកាឡនាគរាជឲ្យនិម្មិតខ្លួនធ្វើជាព្រះពុទ្ធឡើង មានរូបភាពដូចជាព្រះពុទ្ធសុទ្ធសាធ ហើយទ្រង់ទតសំឡឹងឆ្ពោះទៅព្រះពុទ្ធនិម្មិតនោះមិនប៉ព្រិចព្រះនេត្រ ហាក់ដូចជានឹងដកព្រះនេត្រពីព្រះអង្គទៅជាប់នឹងព្រះពុទ្ធនិម្មិតនោះ ដោយទ្រង់មិនសោយព្រះក្រយាស្ងោយរហូត

ដល់ ៧ ថ្ងៃ, មិនតែប៉ុណ្ណោះ ទ្រង់មានព្រះរាជសទ្ធាបានបំពេញកុសលក្នុងព្រះពុទ្ធសាសនាដោយកិច្ចឯទៀតច្រើនជាអនេក ៗ

ព្រះបាទអសោកនោះទ្រង់មានព្រះរាជសទ្ធា ទោះបីទ្រង់ធ្វើព្រះរាជកុសលជាច្រើន ក៏ទ្រង់មិនស្កប់ព្រះហឫទ័យសោះ, កាលទៀបទ្រង់ព្រះទិវង្គត ទ្រង់បង្គាប់ឲ្យពួកសេវកាមាត្យយកព្រះរាជទ្រព្យទៅប្រគេនព្រះសង្ឃឯវត្តកុក្កុដារាម ៗ ពួករាជសេវកាមាត្យមិនព្រមប្រគេនតាមព្រះរាជហឫទ័យ, ព្រះរាជាក៏ទ្រង់ព្រះករនៀងស្រក់ទឹកព្រះនេត្រដោកព្រះកត្រ ទ្រង់ព្រះពិរោធជាពន្លឹក, កំពុងតែព្រះពិរោធដូច្នោះក៏ទ្រង់ព្រះទិវង្គតទៅកើតក្នុងទុគ្គតិភព សមគួរតាមយថាកម្ម ៗ ទាំងនេះក៏ព្រោះចិត្តក្រោធនឹងសេវកាមាត្យ ៗ

សេចក្ដីដែលសំដែងមកនេះ សឲ្យឃើញថា ការមិនធ្វើបាប បានសុខ, ការធ្វើបាបបានទុក្ខ ការដំកល់ចិត្តឲ្យនឹងធឹងបានសុខ, ការដំកល់ចិត្តខុសបានទុក្ខ, សេចក្ដីសុខនឹងទុក្ខរមែងជាប់តាមបុគ្គលអ្នកប្រព្រឹត្តសមដូចបុរាណសុភាសិតថា

រីបុណ្យនឹងបាប អំពើសុភាព នោះរាំតែងតាម
បីដូចស្រមោល អន្ទោលតាមប្រាណ ពុំដែលចៀសបាន
នឹងក្ដីទុក្ខសុខ ៗ

ចប់

# ផ្នែកអក្សរសាស្ត្រ

## អក្សរសាស្ត្រខ្មែរសង្ខេប

## លោក រ៉ាយ-ប៊ុក ក្រមការដើមខ្សែរៀបរៀង

(តមក)

---

៥— រឿងល្ខោនខ្មែរ.— ល្ខោនខ្មែរមានបួនបែប:

ក) ល្ខោនព្រះរាជទ្រព្យ ច្រើននិយមយកសិល្បៈបុរាណ មកជាមូលដ្ឋាន, - សូម្បីតែគ្រឿងប្រដាប់ក៏ជាលំនាំបុរាណ; ឯរឿងគេច្រើនយករឿងបុរាណមកលេងដែរ ដូចជាឥណាវ, ខ្យងស័ង្ខ, ព្រះលក្ស្មណវង្ស, រឿងនោះ ៗ ល ៗ;

ខ) ល្ខោនបាសាក់ស្លៀកពាក់របៀបចិន ហើយច្រៀងលាយខ្មែរ-ចិន ៗ

គ) ល្ខោនសាម័ញ្ញ ស្លៀកពាក់បែបសាម័ញ្ញឬទៅតាមប្រពៃណីជាតិនីមួយ ៗ, ច្រើនលេងរឿងសាម័ញ្ញ;

ឃ) ល្ខោនជាតិ ជាល្ខោនពួកកូនសិស្ស នឹងនិស្សិតសាលា, ច្រើនលេងរឿងសម័យ មានស្លាប់ព្រោះជាតិជាដើម ៗ

ក្នុងរឿងល្ខោននេះមានរបាំ ១ ភ្លេង ១ ចម្រៀង ១ ៗ

៦— រឿងប្រលោមលោក.— រឿងនេះ មានច្រើនបែប ៗ មានរឿងខ្លះ គេយករឿងក្នុងសៀវភៅបារាំងមករចនាជារឿងខ្មែរក៏មាន យករឿងបុរាណខ្មែរ ឬរឿងប្រឌិតឡើងទៅតាមសម័យនិយមក៏មាន ៗ

រឿងប្រលោមលោកខ្មែរបើតាមសភាពទូទៅ, ច្រើនវែងណាស់, ជួនកាលជាពាក្យកាព្យ, ជួនកាលជាពាក្យពាយ ។ រឿងនោះជាអក្សរសាស្ត្រផង ជាអារ្យធម៌ផង ជារឿងប្រពៃណីទំនៀមទម្លាប់ខ្មែរផង ។ មានរឿងប្រលោមលោកខាងការដើរទេសឬផ្សងព្រេង ។ ដោយអំណាចនៃស្នេហាយកទៅបញ្ចូលក្នុងក្របខ័ណ្ឌប្រវត្តិសាស្ត្រ ឬរឿងព្រេងដែលដកស្រង់យកពីរឿងរាមាយណៈខ្លះ, ជាតកខ្លះ ។

ប៉ុន្តែទុកជារឿងប្រលោមលោកនោះ គេតុបតែងឡើងឲ្យមានសេចក្ដីប្លែកអស្ចារ្យយ៉ាងណាក៏ដោយ ក៏គង់ធ្លាក់ក្នុងគន្លងនៃកម្មគឺការប្រព្រឹត្តកុសលឬអកុសលពីអតីតជាតិ ដែលអាចឲ្យផលល្អឬអាក្រក់ក្នុងបច្ចុប្បន្នជាតិ; ការប្រព្រឹត្តបុណ្យបាបក្នុងបច្ចុប្បន្នជាតិ នឹងឲ្យផលល្អឬអាក្រក់ក្នុងអនាគតជាតិជាមិនខាន ។ ក្នុងផ្លូវនៃរឿងទាំងនេះ, មានតែកម្មមួយទេជាខ្សែបន្ទាត់ ។ រឿងរ៉ាវទាំងអស់អាចនឹងមានមក ឬត្រូវតែមានខានមិនបាន, ព្រោះជីវភាពពីអតីតជាតិបានកំណត់ទុកជាស្រេច ដូចពាក្យបុរាណខ្មែរពោលថា: "ផ្លែកម្មទុំហើយ" ។ ក្នុងចំណោមនៃការតយុទ្ធ, ការចាប់យកព្រះអង្គម្ចាស់ក្សត្រី, មហន្តរាយ, យុទ្ធោបករណ៍ដែលប្រតិស្ឋានដោយមន្តអាគម, ការចម្បាំង, ការធ្វើសច្ចាប្រណិធាន, ការស្វែងរកព្រះនាងដែលយក្សចាប់ទៅ, ព្រះអង្គម្ចាស់ស្ដេចទៅសិក្សារៀនសូត្រឯខ្ទមតាបសឬសី,..។ល។..ច្រើនមានអកម្មភាព ឬការទទួលទៅតាមផលកម្មឥតមានរញ្ញាក ដែលជាហេតុឲ្យរឿងនោះមានលំនាំគួរឲ្យចង់អាន តែសរុបរឿងនោះមកបានន័យថា: "ស្ត្រីឲ្យទុក្ខ

ទោសច្រើនប្រការដល់បុរស ” ។ ស្ត្រីខ្លះបានមកជាភរិយាហើយ, មានយក្សបាប់យកទៅ ។ ស្វាមីចំដើរស្វែងរកក្នុងព្រៃជ្រៅ ទៅជួបពលយក្សច្បាំងជាច្រើនលើក-គ្រា ជាហេតុឲ្យលំបាកវេទនាជាខ្លាំង ។ សញ្ញាណអរូបី នៃការបែងចែកធាតុ, ចំពោះរឿងប្រលោមលោកប្រកបដោយមនោសញ្ចេតនា, មានសូរប៉ិកអស្ចារ្យ ហើយធ្វើឲ្យសេចក្ដីស្នេហានោះធ្លាក់ទៅក្នុងអន្លង់ជ្រៅនៃរាគាទិកិលេស... ជ្រៅក្រៃលែង ។ រាគាទិកិលេសនេះជាមូលដ្ឋាននៃទិដ្ឋាន ហើយជាហេតុឲ្យរឿងនោះឧប្បត្តិឡើងដោយជាក់ស្ដែង ។

រឿងប្រលោមលោកខ្មែរបុរាណគឺ ឥតិហាសៈឥណ្ឌាលាយចម្រុះនឹងរស្មីពុទ្ធសាសនា ព្រមទាំងប្រពៃណីទំនៀមទម្លាប់ ។ ក្នុងចំណោមរឿងនេះ មានរឿងវេរង្ស សូរវង្ស, ព្រះលក្ខណវង្ស, ខ្យងសង្ខ, ដោះ, ព្រះចន្ទគោរពកជ, ព្រះរតនាវង្ស, សុទតាបេក, ព្រាហ្មណ៍កេសរ, លិនថោង, ... ។ ល ។

រឿងប្រលោមលោក ដែលគេតែងក្នុងសម័យបច្ចុប្បន្ននេះច្រើនតែផ្ដុំរឿងមានប្រភពផ្សេងៗគ្នា ខ្លះយកពីប្រវត្តិសាស្ត្រចិន, ខ្លះដកស្រង់ពីប្រវត្តិសាស្ត្រឥណ្ឌា, ពង្សាវតារខ្មែរ, ខ្លះដកស្រង់ពីសៀវភៅជាតិអឺរ៉ុប ឬសៀវភៅសៀម ។ ល ។

៣— **រឿងព្រេង** .— រឿងព្រេងបើពិនិត្យទៅតាមផ្ដុំនៃរឿង ឬតាមជីវភាព ជារឿងមានតម្លៃពន់ពេក ព្រមទាំងធ្វើឲ្យមនុស្សពេញចិត្តអានតាំងពីអ្នកជាន់ខ្ពស់រហូតដល់អ្នកជាន់ទាប ។ រឿងព្រេងបានឲ្យ

ន័យចំពោះនិមិត្តរូបនឹងមនោសញ្ចេតនា ដែលមនុស្សជាតិទាំងអស់បានឃើញគ្រប់ៗគ្នា ដោយប្រើនូវមធ្យោបាយតាមធម្មតា ។

រឿងព្រេងខ្មែរយើង, មានរឿងព្រេងខ្លះបានដកស្រង់យកពីរឿងព្រេងឥណ្ឌា, ព្រះពុទ្ធសាសនា, ប្រពៃណីទំនៀមទម្លាប់, ប្រវត្តិសាស្ត្រខ្មែរសម័យបុរាណ, ព្រហ្មញ្ញសាសនា . . . . ល . . . . ។ រឿងព្រេងនោះមានពណ៌នាអំពីអ្នកក្សេត្រករខ្មែរ, ជីវភាពរាល់ថ្ងៃ, ការរស់នៅក្នុងវត្តអារាម, ការដែលព្រះសង្ឃឲ្យឱវាទ, អាកប្បកិរិយានៃប្តីជឿទៅតាមភរិយា, កិច្ចការរបររកស៊ី, ជំនឿផ្សេងៗ, ការប្រស្រ័យនឹងអារក្ស, អ្នកតា, បិសាច, អមនុស្ស ទេវតា, ការកាន់ខន្តីចំពោះសេចក្តីទុក្ខលំបាកគ្រប់យ៉ាង, ការធ្វើចិត្តល្អឬអាក្រក់ចំពោះអ្នកដទៃ, ការមិនយល់នូវលក្ខណៈមនុស្សឬបរិយាបុគ្គលត្រង់បំណងនឹងបោកប្រាស់ខ្លួន, ការទទួលផលកម្មនឹងលាភសក្ការៈជារឿងប្លែកៗ ។ នៅក្នុងរឿងព្រេងតែងមានចៅក្រម ព្រះមហាក្សត្រិយ៍, ព្រះរាជិនី, ហោរា, មេធ្មប់, មេអាប, គ្រូមន្តអាគម, មេមត់, តាបសា ស្រីបណ្ឌិត, ប្រជារាស្ត្រ ភូមិស្រុក, នគរ, ជនបទ ។ ក្រៅពីនេះ, មានការរាប់ឈ្មោះរុក្ខជាតិ ។ នៅក្របខ័ណ្ឌនៃរឿងព្រេង គេច្រើនពណ៌នាអំពីខ្ទម, គេហដ្ឋានមានជណ្តើរឡើង, មានចោរពួននៅក្រោមជណ្តើរនោះ ឬស្វាមីលបចាំស្តាប់ប្រពន្ធមានសហាយស្មន់, គេបានឃើញក្នុងគេហដ្ឋាន, មានពាងពេញទៅដោយទឹកត្រី ហើយពាងនោះធំល្មមឲ្យស្ត្រីដែលមានសហាយស្មន់ យកសហាយនោះទៅដាក់លាក់បំពួនក្នុងពាងបាន ។ មាន

អ្នកនេសាទយកសំណាញ់ទៅបង់ត្រី, គំឡង់ព្រាំពីរសន្ទាន, តាចាស់ធ្វើបាបកូនប្រសាឲ្យទៅភ្ជួរស្រែ, តាចាស់បានទន្សាយមួយយកអង្រែតគ្រប, អាទំពែកទាំងបួន, អាចាក់ស្រុតជាប់នៅលើចុងត្នោតជាដើម ។

កង់ដែនសាសនា, មិនមានពណ៌នាអំពីលទ្ធិ ឬ ធម៌អ្វីឡើយ គ្រាន់តែមានអ្នកបួងសួងដល់ព្រះពុទ្ធ ឬ ទេវតា ។ ព្រះឥន្ទ្រាធិរាជតែងបើកទិព្វចក្ខុគមកស្ថានមនុស្សលោក, មានការកម្រើកដល់អាសនាព្រះឥន្ទ្រាធិរាជ, ជួនកាលព្រះអង្គចុះមកជួយស្រោចស្រង់បុគ្គលណា ដែលមានបុណ្យហើយកំពុងវេទនាក្ដលំបាក, ស្រីទំលក្រតែមានបរិយាសម្គាល់ថាជាបញ្ចពិធកល្យាណី តែងទៅជាស្រី អ្នកមានគោត្រទេព្យ សក្កសម្បាន ។

ជីវភាពនៅវត្តអាពមបានបញ្ជាក់ឲ្យយើងឃើញថា ព្រះភិក្ខុសង្ឃជាអ្នកទស្សាហ៍រៀនសូត្រព្រះត្រៃបិដក, ពិតមែនតែមានព្រះភិក្ខុសង្ឃខ្លះមានគេរះគន់ ក៏គង់យល់បានថាព្រះសង្ឃជាទីគោរពនៃជនទាំងឡាយទាំងបុរសស្ត្រី, ពិធីបុណ្យនៃព្រះពុទ្ធសាសនាមានគ្រប់បែបគ្រប់យ៉ាង.

អាកប្បអ្នកតាបញ្ចេញឲ្យឃើញរូបភាព ស្ថិតនៅតាមខ្ទមនៅកណ្ដាលស្រែ ស្ត្រីចិត្តមិនត្រង់នឹងស្វាមីបានទៅបន់អ្នកតា ឲ្យធ្វើស្វាមីខ្លួនឲ្យអន់ប្រកម្មទៅ ខ្លួននឹងថ្វាយជ្រូកខ្វៃមួយ ។ អ្នកតាខ្លះធ្វើកែ្តកខ្ទាក់ឲ្យទៅជាក្ដី ដូចជាមានរឿងក្មេងកំសត់ម្នាក់ដែលសហជីវិនខ្លួនធ្វើបាប ។ អារុក្ខទេវតាបម្រុងដាក់ទណ្ឌកម្មអ្នកណាកាប់រំលំព្រឹក្សជាតិ ដែលជាវិមានរបស់លោក,

ក្នុងរឿងទាំងអស់នោះ, គេសង្កេតឃើញព្រះពុទ្ធសាសនា, ព្រហ្មញ្ញ-សាសនា, លទ្ធិភូតបិសាច បានលាយប្រឡូកប្រឡល់គ្នា ។

បើមានការដណ្តឹងប្រពន្ធឬរៀបការអាពាហ៍ពិពាហ៍ បុរសដែលចង់បានប្រពន្ធត្រូវមកនៅគេហដ្ឋានបិតាមាតាក្មេក ដើម្បីនឹងឲ្យគាត់ពិសោធកូនប្រសាមើល ។ វិវាហមង្គលការនីមួយ ៗ ត្រូវមានហោរាកំណត់ថ្ងៃពិធី, ទើបធ្វើបានមានការចងដៃជាអំបោះពិសិដ្ឋដើម្បីជ័យមង្គលសិរីសួស្តី ព្រមទាំងករណីយកិច្ចរាល់ថ្ងៃ ដែលភរិយាត្រូវធ្វើចំពោះស្វាមី ។ ពិធីបុណ្យបូជាសព មានពណ៌នានៅក្នុងផ្ទៃរឿងនោះដែរដូចជាពិធីឈាបនកិច្ច ។

ពួកមេធ្មប់, មេអាបសុទ្ធតែមានមន្តអាគមសូត្រ ព្រមទាំងមានកូនកន្សែងយ័ន្តមានរូបផ្សេង ៗ ។ មានមេធ្មប់ខ្លះដឹងថាមានគង្គាពិសិដ្ឋមួយបែបដែលតាទំពែកទាំងបួនត្រូវជ្រមុជក្បាលគាត់ទៅក្នុងនោះដើម្បីឲ្យសក់ដុះឡើងវិញ ។ តែមេធ្មប់នេះច្រើនមានមុខការខាងទាយទៅអនាគតទាយគូព្រេង, គ្រោះថ្នាក់ផ្សេង ៗ ; កិច្ចការក្នុងគ្រួសារ គឺការបរិភោគអាហារ, ការអាស្រ័យទឹក, ដកថ្នាំ, បោសសំអាតគេហដ្ឋានក៏មានពណ៌-នាខ្លះដែរ, មានអ្នកស្រែខ្លះជាអ្នកត្បាញកញ្ជើ, ខ្លះជាជាងធ្វើនង្គ័ល, ខ្លះជាអ្នកនេសាទ, ខ្លះចាំចាបកុំឲ្យស៊ីស្រូវទុំ, ខ្លះដេញចាប៉ីឬបន់ទេវតាឬបររទេះគោ ។ បើរឿងព្រេងនោះមានជនជាតិចិន, ប្រាកដជាមានតៀមនៃពាណិជ្ជចិនមិនខាន ។ បើមានថ្វា គឺថ្វាជាអ្នកចិញ្ចឹមមាន់ជល់ឬអ្នកប្រមាញ់ ។

សេនាបតី, នាយទាហាន, ព្រះរាជសេវកាមាត្យ, សុទ្ធតែមុខ-ស៊ីតស៊ាំងជាអ្នកមិនសូវមានគំនិតទេ ។ ពួកមន្ត្រីនេះជាក្អែករបស់ស្តេច, តែងយកសេចក្តីក្រាបបង្គំទូលព្រះអង្គនូវដំណឹងផ្សេង ៗ ។ ព្រោះមហាក្សត្រិយ៍, ដូនកាល ទ្រង់ជាចៅក្រមកាត់ក្តី ចំពោះក្តីណាដែលចៅក្រមសម្រេចមិនទាន់ដាច់ស្រេច ។ ទ្រង់ប្រកបដោយព្រះប្រាជ្ញាដ៏ជ្រាលជ្រៅអាចរកឃើញចំណោទក្បិទមុខ, ឬវត្ថុដែលលាក់កំបាំងដោយចោរ មនុស្សពាលទុច្ចរិតលួច, រឿងលែងតែប្រាជ្ញាជនញ្ញ័យទើបបោកបញ្ឆោតព្រះអង្គបាន ។ ការកើតក្តីទំនងសត្វព្រមទាំងរបស់ក៏មានខ្លះដែរ ដូចជាក្នុងរឿងចៅកាំបិតបន្ទោះ រឿងក្តីអំពីដណ្តើរដែលគេអួសយកមកជាកស្តាងហើយគេយកដណ្តើរនោះទៅដាក់ឃ្នង, ក្អែកដែលពាំដំបូកត្រី ហើរទៅទំលើដំបូលផ្ទះគេះផ្ទះគេ, មេមាន់ទៅប្តឹងខ្លាថាសត្វស្កាស៊ីកូនមាន់ ... ល ... ។

មានបុគ្គលិកលក្ខណៈជាច្រើនបែប ដែលមាននៅក្នុងរឿងព្រេងគឺព្រះមហារាជ, រាជនី, ចៅក្រៃ, ព្រះសង្ឃ, ចៅហ្វាយខេត្រ, ភរិយាត្រូវពិនិត្យទៅតាមលក្ខណៈថានាងជាភរិយាទុគិតបុរស ឬភរិយាសេដ្ឋី, កុដុម្ពីក៍, គហបតី, ឬភរិយានាហ៊ឺនធំ-តូច, អ្នកសហាយស្មន់, ចោរ, គ្រូធ្មប់ឬគ្រូទាយតាមហោរាសាស្ត្រ, គ្រូទាយតាមតារាសាស្ត្រ, អ្នកក្រ, នឹងអ្នកមាន, បងប្អូនប្រុសកំព្រាពីរនាក់, តាចាស់, ប្រជារាស្ត្រនៅក្នុងភូមិ, ញាតិសន្តានព្រេងណាន ... ល ... ។ ក្នុងបុគ្គលនីមួយ ៗ មានលក្ខណៈរូប, លក្ខណៈសម្បត្តិ, គុណវុឌ្ឍិ, គុណវិបត្តិតាមប្រភេទ

ផ្សេងៗ ; ជួនកាលបុគ្គលម្នាក់ មានគុណសម្បត្តិនិងគុណវិបត្តិចម្រុះគ្នា តែក្នុងបរិយាមួយ ៗ

បុគ្គលជាអមនុស្ស គឺមិនមែនគ្រាន់តែមានត្រឹមតែទេវបុត្រ, ទេវតា, នាងទេវធីតា, ព្រះឥន្ទ្រ, ព្រះព្រហ្ម, យក្ខ គន្ធព្វ, នាគ, ឬពួកអាទិទេពដែលជាប្រពៃណីនៃប្រទេសភារត (ឥណ្ឌា) បានត្រូវទុកមកជាកេរ្តិ៍មតិកស្រាប់នោះទេ, ថែមទាំងមានអ្នកតា, អារក្ស, ភូត, បិសាច ផង.,.ល. .ៗ មានអ្នកតាខ្លះមានសត្វជាអ្នកបម្រើជាប្រក្រតីផង ដូចជាក្រពើក្នុងរឿងអាសុក្រស្បូតអាសុក្រកាច ៗ ក្រៅពីនេះនៅមានរឿងខ្មោច ដូចជារឿងគ្រប៉ន់ទិងនាងទ្រី នាងកញ្ញាខ្មោច ដែលបាននាំស្វាមីទៅកាន់ស្រុកសារឯស្រុកខ្មោច នឹងរឿងនាងយុវតីប្រកបដោយរូបឆោមលោមពណ៌ស្រស់ប្រិមប្រិយ លាក់បំពួនខ្លួននៅក្នុងស្នែង ឬ ក្នុងកុយស្តេចមាស ឬក្នុងក្អកស្តេចហង្ស ក្នុងរឿងបងប្អូនប្រុសពីរនាក់និងមាន់ប្រមាញ់ ៗ ឯលក្ខណៈមាន់ប្រមាញ់នោះ មានពិសិដ្ឋប្លែកពីធម្មតា ព្រោះថាកាលណាមាន់នោះរងាវបីដង ប្រាកដជាស្ត្រីនៅក្នុងព្រះរាជអាណាចក្រទាំងមូល សូម្បីតែព្រះអគ្គមហេសីក៏មិនអាចស្ថិតនៅនឹងខ្លួនបាន ត្រូវតែដើរតាមមិនបាន តម្រង់មកកាន់ទីដែលមាន់ពិសិដ្ឋនោះរងាវ ដោយសំឡេងមាន់នោះ មានអានុភាពអស្ចារ្យណាស់ ប្រៀបដូចជាមេដែកដែលទាញដែកទាំងអស់ ឲ្យចូលមកជិតខ្លួនដូច្នោះ ៗ ក្នុងរឿងស័ង្ខសិល្បជ័យ ឬ ឡឹងស័ង្ខ, សិង្គូចនិងស័ង្ខ ដែលជាមគ្គុទ្ទេសក៍ព្រះបាទស័ង្ខសិល្បជ័យក៏មានសភាពប្លែកពីធម្មតាដែរ ៗ

ចំណែកខាងសត្វតិរច្ឆាន, ត្រូវតែពិនិត្យឲ្យជាក់លាក់ ។ សត្វតិរច្ឆានខ្លះមាននិយមព្រះពុទ្ធសាសនា ឬព្រាហ្មណ៍សាសនា ហើយសត្វនេះជាបងប្អូនសាច់ញាតិនឹងមនុស្សជិតស្និទ្ធ ដូចជាកូនរឿងទៅក្តាំងបាយដែលក្អែនឹងឆ្មា ដែលទៅអវិសានបទ ទៅជាតែងតាំងជាសេនាបតីវិញ ។ សត្វទាំងនោះមានមនោ អធ្យាស្រ័យគួរឲ្យចង់ពិនិត្យដូចរឿងលោកសត្វនៃឡាហ្វុងតែនបាកំងដូព្រោះ ។

រឿងជាតកបានបញ្ចេញប្រាជ្ញាដ៏ជ្រាលជ្រៅ ។ រឿងព្រេងធម្មតាបានបង្ហាញនូវទិដ្ឋភាពនៃធម្មជាតិខ្មែរ និងធម្មជាតិមនុស្សទាំងអស់ហើយមានលក្ខណៈសត្វតិរច្ឆានខ្លះ ដែលបញ្ជាក់ឲ្យយើងឃើញថាមានបុគ្គលអ្នកចេះវិជ្ជាពិនិត្យកិរិយា, ចរិតអធ្យាស្រ័យរបស់សត្វ; មានរឿងព្រេងខ្លះបានពណ៌នាអំពីភាគភោគដែលមានរវាងសត្វនោះ និងអ្នកស្រុកខ្មែរ ។ គំនិតអធ្យាស្រ័យរបស់សត្វនោះ មិនមែនអ្នកណាចេះតែយល់បាននោះទេ លុះត្រាតែអ្នកនោះប្រកបដោយប្រាជ្ញាដ៏មោះមុតទើបបានស្គាល់គំនិតអធ្យាស្រ័យសត្វនោះបាន ។ គេអាចយល់បានថា កូនរឿងទាំងអម្បាលម៉ានសេចក្តីជិតស្និទ្ធតែងមានរវាងមនុស្សនឹងសត្វតិរច្ឆាន ព្រោះថាមនុស្សនឹងសត្វតិរច្ឆានមានសភាពមិនខុសគ្នាគឺ កើត, ស្លាប់, កើតទៀត, ដូចគ្នា ចំណែកឯចរិតនិស្ស័យដូចជាសត្វទន្សាយជាបឋម, ក្អែ, ឆ្មា, ខ្លាឃ្មុំ, ដំរី, អណ្តើក, ក្រពើជាលំដាប់ត ៗ មក សុទ្ធតែមានខុស ៗ គ្នា ។

នេះជាលំនាំផ្សេង ៗ នៃរឿងព្រេងនោះ ។ មានរឿងព្រេងខ្លះជាសេចក្តីរិះគន់ចំពោះសង្គម, ជាលក្ខណសត្វ, ឬជាអច្ឆរិយភាពបង្ហាញ

ទូវបុគ្គលិកលក្ខណៈប្លែកពីធម្មតា, ហើយបានយកវត្ថុធាតុនៃអក្សរសាស្ត្រទិពានសាកល ឬជាវត្ថុធាតុប្រជាមានិតជាមូលដ្ឋាននៃរឿងនោះ ៗ

បើគេចង់ញែករឿងព្រេងនោះ តាមក្រមមានជាច្រើនយ៉ាង គឺ:

១ – រឿងព្រេងតុលាការ ដូចសេចក្ដីដកស្រង់នៃសាស្ត្រាកឹងកន្ត្រៃ ដែលមានសេចក្ដីប្រែទៅប្រទេសភូមា, លាវនិងសៀម, ឬដូចរឿងសភាទន្សាយ;

២ – រឿងព្រេងហាស្យរតិ ដូចជារឿងទំពែកទាំងបួនដែលដើរស្វែងរកករិយា ឬទឹកអម្រឹតធ្វើឲ្យផុះសក់វិញបាន, រឿងធនញ្ជ័យជារឿងកំប្លែងសើច ដែលមានរឿងដូចគ្នាតែនាមខុសគ្នា. រឿងស៊ាងមៀងនៅប្រទេសថៃ និងរឿងធ្នង់ចៃនៅប្រទេសលាវ;

៣ – រឿងព្រេងដែលស្វែងរកបុព្វហេតុ ឬពន្យល់អំពីបុព្វហេតុផ្សេងៗ ដូចជារឿងដើមកំណើតសត្វខ្លា, សត្វមូស, ឬរឿងមិត្តសំឡាញ់ពីរនាក់ដែលចង់បាចទឹកសមុទ្រឲ្យរីង;

៤ – រឿងព្រេងប្រកបដោយអច្ឆរិយភាព ដូចជារឿងនាងកាកី ដែលពណ៌នាអំពីព្រះអគ្គម្ចាស់ក្សត្រី ដែលគ្រុឌបានឆាបយកទៅ ឬរឿងអាធុងអាសាញ់ ឬរឿងកង្កែបយំសុំភ្លៀង, រឿងនាងកែវមនោភ, រឿងព្រះពុទ្ធសេននិងនាងកង្រី, រឿងរាជកុលនិងនាងរំសាយសក់, រឿងនាងសក់ក្រអូបជា . . . . . . . ;

៥ – រឿងព្រេងអ្នកស្រែចម្ការ ដូចជារឿងតាចាស់យាយចាស់ដែលទៅបរបាញ់ . . . . . . . . . ;

៦ - រឿងព្រេងប្រកបដោយប្រាជ្ញា ដូចជារឿងទន្សាយនឹងខ្យង ដែលទន្សាយចាញ់ប្រាជ្ញាខ្យង, រឿងកុកចង់បោកក្តាមស៊ីស្លាប់ខ្លួនឯង, រឿងអាចិលអាខូប, រឿងគង់ហ៊ាន . . . . ល . . . ។

៧ – រឿងព្រេងក្នុងគ្រួសារ ដូចជារឿងអាពុកក្មេកធ្វើបាបកូនប្រសា, រឿងកូនប្រសាបោកអាពុកក្មេក . . . . ល . . . ។

ក្រៅពីនេះនៅមានរឿងដទៃទៀតច្រើនជាអនេកប្បការ ។

(មានត).

## អក្សរសាស្ត្រខ្មែរ ជាជីវិតរបស់ខ្មែរ

អក្សរសាស្ត្រខ្មែរ នាំជាតិខ្មែរឲ្យថ្លាថ្លៃ
ឲ្យថ្កើងថ្កានពេកក្រៃ ឲ្យស៊ីវិល្យៃនៅក្នុងលោក!

ហប-ពិន.

ពេជ្រព្រះភជា

លោក ស៊ុន-ហ៊ាន ប្រែរៀបរៀង

លោក យូរ-អ៊ុន ពិនិត្យកែសម្រួល

(តមក)

ខណៈនេះ សុរពលហត់ជិតដាច់ខ្យល់ ទ្រេតខ្លួនទៅដល់ទីង លំពែង ១ ដែលសិស្សបោះមកឱ្យ ទើបឱនចុះចាប់លំពែងនោះភ្លាម ដោយមានសេចក្ដីសង្ឃឹមក្នុងខ្លួន ។ គោកាចស្ទុះចូលមកប៉ះទីង ដល់សុរពលទៀត លុះជិតដល់វាក៏ផ្អៀងក្បាលផល់សុរពល ។ ថយក្រោយ ២-៣ ជំហាន ល្មមបានការហើយ ក៏ពួយលំពែងទៅត្រូវក្បាលមុខរបស់វា គ្រាន់តែសុរពលទាញកន្ទ្រាក់លំពែងចេញមក គោក៏ដួលស្រិបទៅ សូម្បីរបួសនៅក្បាលរបស់វាមិនជាខ្លាំងប៉ុន្មាន ក៏វាអស់កម្លាំងលែងមានឫទ្ធិតទៅទៀត ។ សិស្សរបស់សុរពលក៏ស្រែកហ៊ោឡើងដោយសេចក្ដីត្រេកអរខ្លាំង ដែលឃើញអាចារ្យរបស់ខ្លួនមិនមានអន្តរាយ ។ នាងកាញ្ចនាដែលអង្គុយយំនៅជិតអមាត្យនទី មិនហ៊ានបែរសម្លឹងមើលទៅបងប្រុសដែលកំពុងតស៊ូគោឆ្កួតទេ លុះបានឮសម្លេងសិស្សហ៊ោនាងក៏បែរមើលទៅ ។ ខណៈនោះ សុរពលងើតមុខ ទើបប្រាប់ឱ្យសិស្សជួយទប់ខ្លួន កាញ្ចនាប្រញាប់ចុះពីផ្ទះរត់ទៅរកបងប្រុស ។ ឯយាយព្រាហ្មណីក៏អៀនខ្មាស ហើយដឹងខ្លួនថាដែលរួចផុតមកបាន ក៏ព្រោះសុរពលជួយ តែវិស័យពាលរបស់យាយព្រាហ្មណីនៅមិនទាន់អស់

ក្រោធខឹងប្តូចឯសាយាតទឹងគាត់ដោយប្រការណា ក៏កើតសេចក្តីប្លែកក្នុងចិត្តទឹកអៀនខ្មាសក្រៃពេក ។ សុរពលឃើញយាយព្រាហ្មណីឈប់គំនិតស្មានថា ប្រហែលយាយនេះមិនហ៊ានទៅ ទើបប្រាប់ថាៈ

– "យាយចង់ត្រឡប់ទៅផ្ទះវិញ ក៏ត្រឡប់ទៅចុះ កុំខ្លាចអ្វី គោះនោះអស់ងើបរួចហើយ" ។

យាយព្រាហ្មណីទ្រហោយំ ដោយទឹកតូចចិត្តនឹងខ្លួនឯង ដែលធ្វើអាក្រក់ផ្ដល់ទៅលើសុរពល ដែលជាមនុស្សល្អ មិនចេះក្រោធតបវិញ ព្រមទាំងបានជួយខ្លួនឲ្យរួចចាកសេចក្តីអន្តរាយជីវិតទៀតផង យំហើយនិយាយអង្វរសុំទោសសុរពលថាៈ

– "លោកចៅសូមលើកទោសឲ្យយាយផងចុះ លោកចៅបានជួយជីវិតមនុស្សអាក្រក់ ដូចយ៉ាងយាយដែលធ្លាប់ជេរលោកចៅ ៗ នឹងធ្វើទោសយាយដូចម្តេចក៏ចេះតែបាន តែសូមលោកចៅលើកទោសឲ្យយាយផងចុះ" ។

នាងកាញ្ចនាឃើញហើយអាណិតយាយព្រាហ្មណីពន់ពេក ទើបចូលទៅរកគាត់ហើយប្រាប់ថាៈ

– "យាយកុំតូចចិត្តឡើយ បងខ្ញុំនឹងមនុស្សក្នុងផ្ទះខ្ញុំគ្មានអ្នកណាខឹងនឹងយាយទេ តទៅបើយាយមានទុក្ខធុរៈអ្វីកើតឡើង សូមយាយមករកខ្ញុំចុះ បើខ្ញុំនឹងបងខ្ញុំអាចជួយយាយបានក៏នឹងជួយយាយ មនុស្សយើងដែលទុកជាមិត្តស្និទ្ធនឹងគ្នាបាន ក៏ដោយចេះជួយគ្នាក្នុងគ្រាកើតទុក្ខក្តៅ-

ក្រហាយ, ល្អហើយដែលយាយដឹងខ្លួនថាខ្លួនប្រព្រឹត្តខុសនេះ សូមយាយត្រឡប់ទៅផ្ទះចុះ" ។

យាយព្រាហ្មណី កាលស្តាប់ពាក្យនាងកាញ្ចនាក៏តែតែតូចចិត្តនឹងខ្លួនឯងខ្លាំងឡើង ទើបក្រាបសំពះពោលសរសើរគុណសុពេលនឹងនាងកាញ្ចនាហើយក៏លាត្រឡប់ទៅផ្ទះ ។

ខណៈដែលមនុស្សកំពុងហោមមើលយាយព្រាហ្មណីនោះ មានបុរសម្នាក់ជិះសេះមកដល់ កាលឃើញមនុស្សកំពុងហោមពេមមើលយាយនោះ គេក៏ចុះចាកខ្នងសេះអែបចូលមកមើល កាលបានឃើញហេតុការណ៍ប្លែកដូច្នោះ ក៏សាកសួរមនុស្សដែលនៅក្នុងបរិវេណនោះអំពីរឿងរ៉ាវដែលកើតឡើង ក៏បានដឹងសេចក្តីសព្វគ្រប់ គេក៏ទឹកប្លែកក្នុងចិត្តជាខ្លាំងនឹងមនុស្សដែលជាអ្នកប្រកបដោយគុណធម៌ខ្ពង់ខ្ពស់ ហើយមកនៅក្រៅពជធានី មានជីវិតរស់នៅក្នុងចំណោមមនុស្សដែលឃ្លាតឆ្ងាយពីសេចក្តីចំរើន តែត្រឡប់តាំងខ្លួនឲ្យមានអ្នកកប់អាន ហើយប្រៀនប្រដៅអ្នកកប់អានឲ្យតាំងខ្លួននៅក្នុងសេចក្តីល្អ សេចក្តីចំរើន ។ បុរសជិះសេះកាលទឹកអស្ចារ្យយ៉ាងនេះហើយ ក៏ចង់ស្គាល់ឈ្មោះគេ ទើបដឹកសេះទៅចងទុក ហើយដើរចូលទៅរកសុពេល ខណៈនោះយាយព្រាហ្មណីបានត្រឡប់ទៅហើយ សុពេលកំពុងឈរសម្រាកឲ្យបាត់ហត់ឲ្យបាត់អស់កម្លាំង អំពីការតស៊ូនឹងគោអម្បាញ់មិញ ។

សុពេលឃើញមនុស្សប្លែកមុខស្គាល់យាម ដើរត្រង់ចូលមករកខ្លួនផ្ទះប្រាកឡល់ក្នុងចិត្ត ទើបលើកដៃឡើងធ្វើសេចក្ដីគោរព ទាំងនាងកាញ្ចនាក៏លើកដៃសំពះបុរសនោះដែរ ។

បុរសនោះ ប្រញាប់លើកដៃគំនាប់សុពេលទាំងនាងកាញ្ចនាវិញ ហើយពោលថា:

– " សូមជំរាបលោក ខ្ញុំបាទជាអ្នកដើរផ្លូវឆ្ងាយបានមកឃើញលោកអម្បាញ់មិញនេះ ហើយដឹងច្បាស់នូវគុណធម៌របស់លោកអំពីអ្នកដែលនៅឈរជុំវិញ ទើបខ្ញុំចង់ស្គាល់ឈ្មោះលោក មួយទៀតខ្ញុំបាទសូមឈប់សម្រាកនៅទីនេះ១ស្របក់សិន តើលោកអាចប្រាប់ឈ្មោះទាំងអនុញ្ញាតឲ្យខ្ញុំឈប់សម្រាកបានឬទេ? " ។ អាការគោរពរបស់បុរសនេះធ្វើឲ្យសុពេលទុកសង្ស័យ សុពេលបានប្រាប់ឲ្យពួកសិស្សត្រឡប់ទៅផ្ទះរៀងៗខ្លួន ហើយអញ្ជើញបុរសនោះឲ្យឡើងលើផ្ទះ:

–"អញ្ជើញលោកឡើងទៅសម្រាកលើផ្ទះតាមសប្បាយចុះ ខ្ញុំនឹងប្រាប់ឈ្មោះខ្ញុំដល់លោកបាន តែចាំខ្ញុំទៅចងគោនោះសិន ព្រោះវាមិនទាន់ស្ងាប់ ក្រែងវាក្រោកឡើងជល់មនុស្សម្នានៅជិតខាងទៀត" ។

នាងកាញ្ចនាបាននាំបុរសនោះឡើងទៅលើផ្ទះ ហើយយកទឹកតែនឹងស្លាបារីមកជូនភ្ញៀវពិសា ។ បុរសនោះឡើងទៅអង្គុយលើផ្ទះ ឃើញលោកអមាត្យនន្ទអង្គុយ គេសង្កេតកិរិយាលោកក៏ដឹងថា ជាអ្នកល្អមានបុគ្គលទាំងទម្រង់ ទើបកើតសេចក្ដីសង្ស័យ នាំឲ្យរិតតែចង់ដឹងនូវកេរប្រព្រឹត្តិរបស់គ្រួសារនេះ គេសំពះលោកអមាត្យនន្ទហើយជំរាបថា:

"ខ្ញុំបាទចេញពីក្រុងពារាណសីមកអស់វេលាច្រើនខែហើយ កាលត្រឡប់ដើរមកតាមផ្លូវនេះ បានឃើញបុត្ររបស់លោកមានមនុស្សរាប់អានច្រើន ទើបខ្ញុំចង់ស្គាល់គ្រួសាររបស់លោក សូមលោកមេត្តានាំខ្លួនកូនរបស់លោកមកឲ្យខ្ញុំស្គាល់ផង" ។

អមាត្យនន្ទិ បានស្ដាប់ពាក្យរបស់បុរសនោះហើយ ក៏តបថា: "ខ្លួនខ្ញុំនេះឯងឈ្មោះនន្ទិ, បុត្រប្រុសដែលនៅខាងក្រោមឈ្មោះសុពល, នាងនេះជាកូនស្រីរបស់ខ្ញុំឈ្មោះកាញ្ចនា ចុះអ្នកឯងឈ្មោះអ្វី ម្ដេចមិនប្រាប់ឲ្យខ្ញុំស្គាល់ឈ្មោះផង លោកប្រហែលជាដើរផ្លូវមកឆ្ងាយណាស់ ទើបមើលទៅសម្បុរសាច់ឈាមត្រូវកំដៅថ្ងៃខ្មៅក្រៀមអស់ ទំនងជាអស់កម្លាំងណាស់ហើយ"! ។

"ត្រូវហើយ ខ្ញុំដើរផ្លូវមកឆ្ងាយណាស់ ចេញចាកក្រុងវេសាលីជាង៥ខែ ទាំងទៅទាំងមក ខ្ញុំបាទឈ្មោះបាលិត ជាអមាត្យរបស់ព្រះរាជានគរពារាណសី ខ្ញុំបាទត្រេកអរណាស់ ដែលលោកប្រាប់ឈ្មោះឲ្យស្គាល់ ខ្ញុំបាទចង់ស្គាល់លោកអស់វេលាច្រើនខែមកហើយ ព្រោះខ្ញុំបាទបានឮនាមនឹងកិត្តិគុណរបស់លោកអំពីបុរសម្នាក់ ហើយបុរសនោះបានតាមរកលោកដោយលំបាក តែមិនបានជួបនឹងលោកសោះ" ។

អមាត្យនន្ទិភិតភ័យស្ទើរសន្លប់ ព្រោះលោកមិនចង់ឲ្យអ្នកណាស្គាល់លោកថាជាអមាត្យ ដែលព្រះរាជានៃនគរពជគ្រិះទ្រង់ព្រះរាជបញ្ជាឲ្យធ្វើទណ្ឌកម្មមកហើយដូច្នេះទេ លុះបានឮថាអមាត្យបាលិតស្គាល់លោក

អំពីបុរសម្នាក់ ដែលតាមរកលោកដោយសេចក្ដីលំបាកក៏នឹកចង់ដឹងថា នរណាជាអ្នកតាមរក ទើបសួរថា:

— "នរណាដែលថាស្គាល់ខ្ញុំ ហើយតាមរកខ្ញុំ សូមលោកប្រាប់ឈ្មោះឲ្យខ្ញុំដឹងផង" ។

— "ឈ្មោះបុទ្ធិស័ត្យ, លោកគង់ស្គាល់ច្បាស់ហើយ ខ្ញុំបាននៅជួបនឹងបុទ្ធិស័ត្យនោះក្នុងនគរវេសាលី នៅខណៈដែលកើតអាគេទឡើងក្នុងនគរនោះ គេជាមនុស្សល្អណាស់ មានសេចក្ដីករុណាដល់សត្វដែលព្រះពជានឹងធ្វើការបូជាយញ្ញ ហើយបានទូលទាស់ព្រះពជាមិនឲ្យទ្រង់ធ្វើការបូជាយញ្ញដោយទារុណកម្មដ៏អាក្រក់, គេហ៊ានយកជីវិតទៅទទួលអាសាដល់ពួកអ្នកស្រុក" ។ (មានត)

## ប្រយោជន៍នៃការឧស្សាហ៍អាន

អ្នកណាសន្ទាត់ហាត់មើលអាន
នូវរឿងបុរាណល្អសោភា
ឬរឿងទំនើបផ្សេងនានា
អ្នកនោះមុខជាដឹងរឿងច្រើន !

ហាប-ពិន

# រឿងសាមកុក

## កណ្ឌទី ២៦

- ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ខណៈនោះគ្រូពេទ្យហ្វាតោមិននៅ ព្រោះមានកិច្ចរវល់ចូលទៅមើលជម្ងឺស្រុកក្រុង, បានតែសិស្សហ្វាតោម្នាក់មក ពេទ្យនោះមើលហើយក៏ជំរាបស៊ុនសេ៊កថា ឯរបួសដោយព្រួញនោះខ្ញុំបាទមើលឲ្យជាដាច់បាន តែរបួសដោយធ្នូនោះព្រួញមុតដល់ឆ្អឹង ហើយព្រួញនោះមានដាក់ថ្នាំពិសផង បើនឹងរក្សាសូមអញ្ជើញលោកទៅរកទីស្ងាត់នៅ កុំឲ្យមនុស្សចូលទៅមកអ៊ូអរ ហើយឲ្យលោករំលត់សេចក្ដីក្រោធខឹងឲ្យអស់ផង លុះគ្រប់កំណត់ ១០០ ថ្ងៃទើបជាដាច់ស្រឡះ . បើរំងាប់កំហឹងមិនបានទេ ថ្នាំពិសក៏រឹតតែកំរើកខ្លាំងឡើង ៗ ស៊ុនសេ៊កក៏ធ្វើតាម ខណៈនោះពេទ្យរក្សាបានប្រហែល ២០ ថ្ងៃ ស៊ុនសេ៊កនោះជាមនុស្សចិត្តរហ័សនឹងធ្វើអ្វីចង់ឲ្យបានទាន់ចិត្តភ្លាម ៗ

ទទួលពេលនោះ មានបំរើទៀវហៀនម្នាក់ដែលទៅនៅស្រុកក្រុងហ៊ូតោនោះឲ្យចូលមកជំរាបសេចក្ដី លុះស៊ុនស៊េកដឹងហើយក៏ឲ្យគេហៅអ្នកបំរើនោះចូលទៅហើយសួរថា: ទៀវហៀនប្រើអ្នកមកដោយហេតុដូចម្ដេច ? អ្នកបំរើប្រាប់ថា ទៀវហៀនប្រើខ្ញុំបាទឲ្យមកជំរាបលោកថា: ទៀវហៀនដែលបានទៅនៅក្នុងស្រុកក្រុងនោះ បានឃើញចូចូនឹងទីប្រឹក្សាព្រមទាំងសេនាទាហានទាំងពួងនោះ បើនឹងនិយាយគ្នាពីកិច្ចការរាជការអ៊ូក៏មានសេចក្ដីកោតញញើតថ្វីដៃលោកជាច្រើនដកប តែកុយកៃនោះបើនឹងពោលនិយាយពីកិច្ចការអ៊ូក៏ឥតគិតខ្លាចក្រែងលោកសោះ ៗ ស៊ុនស៊េកសួរថា ចុះដែលកុយកៃមើលងាយយើងនោះបាននិយាយថាម្ដេចខ្លះ អ្នកបំរើនោះនៅស្ងៀមមិនឆ្លើយ ស៊ុនស៊េកឃើញអ្នកបំរើនោះនៅស្ងៀមដូច្នោះក៏ខឹងណាស់ថា: ទៀវហៀនប្រើខ្លួនមកឲ្យប្រាប់ដំណឹងយើង ៗ សួរអ្វីទៅក៏នៅស្ងៀមដូច្នេះ ៗ ឯអ្នកបំរើនោះឃើញស៊ុនស៊េកខឹងខ្លាំងក៏នឹកខ្លាច ទើបឆ្លើយថា: កុយកៃបាននិយាយនឹងចូចូថា: ហេតុម្ដេចបានជាខ្លាចស៊ុនស៊េក ឯស៊ុនស៊េកនោះជាមនុស្សគ្មានប្រាជ្ញាសោះ បានតែចិត្តរហ័ស ទោះនឹងគិតការអ្វីក៏រមែងមើលងាយប្រមាថ គិតសង្វាតតែអួតបេះហើយតាំងខ្លួនធ្វើធំ យូរទៅគង់តែនឹងស្លាប់ដោយថ្វីដៃកូនទាហាន ៗ

ឯស៊ុនស៊េកបានស្ដាប់ដូច្នោះ ក៏រឹងរឹតតែក្រោធខឹងខ្លាំងពន់ប្រមាណណាស់ទៅទៀត និយាយថា "កុយកៃនោះវាមានសតិប្រាជ្ញាយ៉ាងណាខ្លះ ទើបបានអាចហាននិយាយមើលងាយប្រមាថយើងជាពាក្យអាក្រក់ដូច្នេះ ចាំយើងនឹងលើកទ័ពទៅវាយយកស្រុកហ៊ូតោឲ្យទាល់តែ

បាន ហើយនឹងចាប់យកទាំងខ្លួនកុយកែសម្លាប់ចោលចេញ រួចឲ្យជញ្ជ្រាំសាច់ឲ្យល្អិតខ្ទេចកុំឲ្យក្អែកចឹកស៊ីបាន" និយាយហើយក៏ឲ្យហៅទីប្រឹក្សាទាំងពួងមកប្រឹក្សាការថា "កុយកែនិយាយមើយងាយប្រមាថយើងដូច្នេះ ត្រូវតែយើងបង្ខំផ្ដុំសេនាទាហានឲ្យបានព្រមទុកជាស្រេចរួចយើងនឹងលើកកងទ័ពទៅវាយយកស្រុកហ៊ូគោ ចាប់យកទាំងកុយកែទៅសម្លាប់ចោលចេញឲ្យបានទើបបាត់ខឹង" ។ ទៀវចៀវថា: កាលពីថ្ងៃមុនគ្រូពេទ្យបានមកថែរក្សារបួសព្រួញនោះ ក៏បានហាមប្រាមលោកថាកុំឲ្យមានសេចក្ដីក្រោធខឹងលុះគ្រប់ ១០០ ថ្ងៃ ឥឡូវទើបនឹងបានតែ ២០ ថ្ងៃប្លាយ ហើយលោកមានទោសោបំរុងនឹងលើកកងទ័ពទៅច្បាំងប្រណាំងនឹងពាក្យកុយកែនោះឃើញថាមិនគួរទេ ។

ខណៈនោះទទួលមានបំរើសេះម្នាក់មកជំរាបស៊ុនស៊េកថា ឥឡូវគាន់ជិនទាហានអ៊ូនសៀវមានការចង់ចូលមករកលោក ។ ស៊ុនស៊េកក៏ឲ្យហៅខ្លួនចូលទៅ គាន់ជិនគំនាប់ហើយក៏ហុចសំបុត្រទៅឲ្យស៊ុនស៊េក ៗ ទទួលយកសំបុត្រអ៊ូនសៀវទៅមើលឃើញសេចក្ដីថា: ចុច្ចុជាសត្រូវរាជ-សម្បត្តិ សូមឲ្យស៊ុនស៊េកតាំងចិត្តជាមួយនឹងយើងលើកកងទ័ពទៅវាយខ្ទប់ស្រុកហ៊ូគោពីទិសខាងត្បូង ។ យើងនឹងលើកចូលទៅពីទិសខាងជើងនឹងកំចាត់ចុច្ចុចេញ ។ ស៊ុនស៊េកឃើញច្បាស់ក្នុងសំបុត្រដូច្នោះក៏មានអំណរណាស់ ទើបឲ្យរៀតុះលៀងគោជនាហារ អញ្ជើញគាន់ជិនឲ្យបរិភោគជាមួយនឹងសេនាទាហានទាំងពួងលើសើន ។

ខណៈកាលកៀរកំពុងសេពសុរានោះ សុនសេកឃើញទាហាន តាំងពួងដែលកំពុងបរិភោគនោះនិយាយខ្សឹបគ្នា ហើយយកដៃចង្អុលចុះ ពីលើសើនព្រមគ្នា ៗ សុនសេកមានសេចក្ដីសង្ស័យក៏សួរអ្នកបំរើថា ហេតុម្ដេចបានជានាម៉ឺនទីងទាហានតាំងពួងនិយាយខ្សឹបគ្នា ហើយចង្អុល ចុះទៅក្រោមសើនដូច្នោះ? ៗ អ្នកបំរើជំរាបថា: អ៊ីកៀតដែលអ្នកស្រុក តាំងអស់គ្នាធ្លាប់និយមរាប់អានថា ជាមនុស្សមានសេចក្ដីបេះដូងស័ក្ដិ សិទ្ធិនោះ ឥឡូវដើរមកតាមផ្លូវពីទិសខាងត្បូងចូលឈប់ក្រោមសើន ទាហានតាំងពួងឃើញហើយក៏មានសេចក្ដីត្រេកអរ ទើបបបួលគ្នាចុះទៅ គំនាប់ ៗ សុនសេកបានស្ដាប់ដូច្នោះក៏អើតមើលទៅតាមបង្អួចសើន ឃើញអ៊ីកៀតតែងខ្លួនពាក់អាវសម្បុរសដូចទេវតា ដៃកាន់ឈើច្រត់ដើរ ទៅតាមផ្លូវ អ្នកស្រុកតាំងពួងបបួលគ្នាកាន់ផ្កាភ្ញីទីងទៀនធូបចូលទៅ គំនាប់ដោយគោរពដល់អ៊ីកៀត សុនសេកខឹងណាស់ជេរអ៊ីកៀតថាអាធ្វើ ដូច្នេះជាការកុហកបញ្ឆោតឲ្យគេជឿ ហើយក៏បង្គាប់ឲ្យទាហានដេញ ចាប់ខ្លួនអ៊ីកៀតយកទៅសម្លាប់ ៗ

ទាហានតាំងពួងជំរាបថា: អ៊ីកៀតនេះនៅក្រៅស្រុកមកពីទិសឯ-កើត ធ្លាប់យកទឹកមន្តមកឲ្យអ្នកស្រុកដែលមានជម្ងឺឈឺថ្កាត់ បើផឹក ស្រោចង្ងូតទៅកាលណាហើយក៏ជាសះស្បើយរោគជារឿយ ៗ ហើយអ្នក ស្រុកនិយមរាប់អានថា អ៊ីកៀតជាមនុស្សទាល់ក្រមានចិត្តបុណ្យអាណិត អាសូរក្រៃណាស់ ដែលលោកនឹងបង្គាប់ឲ្យទាហានចាប់យកទៅសម្លាប់ ចេញនោះជាការមិនគួរទេ ៗ សុនសេកបានស្ដាប់ដូច្នោះរឹតតែខឹង

ខ្លាំងណាស់ឡើងទៀត កំបង្គាប់ឲ្យទាហានប្រញាប់ទៅចាប់ខ្លួនឲ្យទាន់ តែបានហើយពោលថា បើនរណាមួយរឹងទទឹង អញនឹងឲ្យកាត់ក្បាលអ្នកនោះវិញ ។ ទាហានទាំងពួងក៏ភិតភ័យខ្លាចមិនអាចរឹងទទឹងទំប្រឹង នាំគ្នាទៅរកចាប់ខ្លួនអាកៀតនាំទៅឲ្យស៊ីនសេកលើសើន ។ ស៊ីនសេកក៏ស្រែកគំរាមហើយសួរថា: ខ្លួនមកពីណា ? ហេតុម្តេចមកធ្វើកិរិយាកុហកបញ្ឆោតឲ្យគេជឿវង្វើងទាំងអស់គ្នាដូច្នេះ? ។

អាកៀតឆ្លើយតបថា: ខ្ញុំបាទនៅស្រុកឡុងសៀ, កាលព្រះចៅស៊ីនតេសោយរាជ្យនោះ ខ្ញុំបាទបានទៅស្វែងរកថ្នាំលើភ្នំខយ៉ុកយ៉េង បានតម្រាក្នុងរូងភ្នំប្រហែល ១០០ ច្បាប់សម្រាប់ធ្វើការសែកទឹកមន្តរក្សាជម្ងឺឈឺថ្កាត់ផ្សេង ៗ ខ្ញុំបាទប្រាថ្នាយកតែបុណ្យកុសលប៉ុណ្ណោះ ដែលនឹងបានធ្វើកលឧបាយល្បួងបញ្ឆោតគេឲ្យវង្វេងជឿស្តាប់ជាការពុំគប្បីក៏ទេសោះ ។ ស៊ីនសេកសួរថា: " បើខ្លួនមិនបានយកថ្លៃឈ្នួលពីឈ្មោះណាទេ ហេតុម្តេចខ្លួនក៏បានចំណីអាហារបរិភោគចិញ្ចឹមជីវិតតមក ហើយនឹងបានគ្រឿងឧបភោគប្រដាប់ស្លៀកពាក់ដូច្នេះ? ខ្លួនឯងនេះគឺជាពួកជាមួយនឹងទៀវកុក បើអញមិនសម្លាប់ឯងចេញទេ ឯងនឹងមានចិត្តកំរើបគិតប្រទូសរ៉ាយដល់អញវិញ " ថាហើយក៏បង្គាប់ទាហានឲ្យនាំខ្លួនអាកៀតយកទៅសម្លាប់ចោល ។

ទៀវបៀននិយាយយាត់ថា: តាំងពីអាកៀតមកនៅស្រុកកាំងតាំងនេះជាង ៣ ឆ្នាំហើយ មិនដែលឮថាអាកៀតទៅភូតកុហកបញ្ឆោតអ្នកណាមួយសោះ ដែលលោកឲ្យយកខ្លួនទៅសម្លាប់នោះឃើញថាមិន

គួរទេ ។ ស៊ិនសេ៊កនិយាយនឹងទៀវបៀវថា: អ្នកមកពប់អានអ៊ីកៀតថាជាមនុស្សប៊ិត្តបុណ្យនោះខុសសោះ អ៊ីកៀតនេះជាមនុស្សព្រោកកុហកបំផ្លិចសត្វតិរច្ឆាន ទាហានទាំងពួងប្ដូរនាំអ៊ីកៀតទៅសម្លាប់ចុះ ។ ប៉ុន្តែលុះនាម៉ឺនទាំងពួងនឹងតាន់ជិន នាំគ្នាចូលទៅអង្វរឃាត់ស៊ិនសេ៊កសុំជីវិតអ៊ីកៀតទុកបាន ។ ស៊ិនសេ៊កក៏ឲ្យយកខ្នងអ៊ីកៀតទៅឃុំដាក់គុកទុកវិញ ហើយស៊ិនសេ៊កត្រឡប់មកនៅក្នុងគេហដ្ឋាន ។ អ្នកបំរើស៊ិនសេ៊កក៏នាំយករឿងដែលធ្វើទោសអ៊ីកៀតនោះ ទៅជំរាបដល់នាងងឺហ៊ុយិន ជាមាតាស៊ិនសេ៊កសព្វគ្រប់ប្រការ ។

នាងងឺហ៊ុយិនបានស្ដាប់ដូច្នោះ ក៏ឲ្យហៅស៊ិនសេ៊កចូលទៅនិយាយថា: អ៊ីកៀតនោះជាមនុស្សប៊ិត្តបុណ្យ អាណិតអាសូរដល់បណ្ដាស្ត្រីណាស់ ហេតុម្ដេចក៏កូនឲ្យយកអ៊ីកៀតមកធ្វើទោសដូច្នេះ ។ ស៊ិនសេ៊កឆ្លើយថា: "អ៊ីកៀតនោះជាមនុស្សព្រោកកុហក បើនឹងទុកឲ្យយូរទៅគង់នឹងមានចិត្តកំរើបធំឡើងទៀត បើនឹងទុកវាគង់នឹងមានភ័យអន្តរាយដល់ខ្លួនខ្ញុំបាទ មាតាកុំគប្បីជឿស្ដាប់ពាក្យដែលគេមកជំរាបនោះឡើយ មាតាជ្រាបស្រេចហើយកុំពប់អានកាន់អ៊ីកៀតនោះធ្វើអ្វី" ហើយស៊ិនសេ៊កក៏លាមាតាត្រឡប់ចេញមកវិញ ។

ខណៈនោះ ទៀវបៀវនឹងនាម៉ឺន ១១-១២ នាក់ នាំគ្នាចុះឈ្មោះធ្វើរឿងរ៉ាវចូលមកប្ដឹងស៊ិនសេ៊ក ជាសេចក្ដីថា: សូមឲ្យលោកដោះលែងអ៊ីកៀតចេញទៅ បើដំណាតទៅមុខអ៊ីកៀតមានចិត្តកំរើបគិតប្រទូសរ៉ាយដល់លោកយ៉ាងណា សូមឲ្យលោកកាត់ក្បាលយើងខ្ញុំទាំងអស់គ្នាចេញ

ចុះ ៗ ស៊ុនសេិកឃើញពាក្យបណ្ដឹងជាក់ច្បាស់ដូច្នោះ ក៏និយាយថាអ្នកទាំងអស់គ្នាមិនដឹងទេឬ? កាលគ្រាទៀវកុកនឹងពួកកៀនធ្វើជាចោរនោះ ខាងទៀវជិនបៅហ្វាយស្រុកកៅជីវ រាប់អានថាជាហ្វាថាវបញ្ចូលខ្មោចស័ក្ដិសិទ្ធ បើទៀវជិននឹងលើកទ័ពទៅទីណាក៏យកព្រៃក្រហម ឲ្យហ្វាថាវចុះលេខយន្ដមន្ដគាថាឲ្យ ហើយឲ្យទាហានទាំងពួងជូតក្បាល ធ្វើការសង្គ្រាមក៏កាន់យកអាវុធមិនបាន, ទៀវជិននឹងទាហានទាំងពួងធ្វើសង្គ្រាមក៏បរាជ័យចាញ់ក្នុងទីចម្បាំង, ឯអ្នករាល់គ្នាមករាប់អានអ៊ីកៀតដែលជាមនុស្សបោកកុហក ជឿកាន់ខ្មោចបិសាចនោះមិនសមគួរសោះ យើងនឹងឲ្យសម្លាប់អ៊ីកៀតចេញ ស្រុកយើងក៏នឹងបានសេចក្ដីសុខក្សេមក្សាន្តតទៅ ៗ

លីហ្វុយហោនិយាយនឹងស៊ុនសេិកថា: ខ្ញុំបាទបានឮកិត្តិស័ព្ទថា អ៊ីកៀតមានការចេះដឹងហៅខ្យល់ហៅភ្លៀងបាន ឥឡូវស្រុកយើងរាំងភ្លៀង បណ្ដារាស្ដ្រធ្វើស្រែមិនបានសោះ សូមលោកឲ្យអ៊ីកៀតហៅភ្លៀង បើអ៊ីកៀតហៅភ្លៀងឲ្យធ្លាក់ចុះមកបានហើយ ឲ្យលោកបើកលែងអ៊ីកៀតចេញចុះ ៗ ស៊ុនសេិកយល់ឃើញត្រូវក៏ឲ្យទាហានសង់រោងពិធីសុំទឹកភ្លៀងខ្ពស់ប្រហែល ១០ ព្យាម (២០ម) ទើបឲ្យទៅយកខ្លួនអ៊ីកៀតចេញមកហើយប្រាប់ថា: ខ្លួនមានសេចក្ដីចេះដឹងទាំងមានចិត្តអាណិតអាសូររាស្ដ្រទាំងពួង ឥឡូវស្រុកយើងរាំងភ្លៀង រាស្ដ្រធ្វើស្រែមិនបាន ខ្លួនចូរហៅទឹកភ្លៀងឲ្យធ្លាក់មកចុះ យើងនឹងដោះខ្លួនចេញ ៗ

(មានត)

# រឿងបល្ល័ង្កទិព្យ សាមសិបពីររឿង

### រឿងព្រេងតំណាល

## លោកសម៉ិន មូត្យឥដម: តែង

## លោក វ៉ាយ-ប៊ុក ក្រមការដើមខ្មែរ ប្រែរៀបរៀង

(តមក)

---

ក្នុងពេលនោះ ស្វាមីនាងគឺបុរសដែលគេឃើញមានជើងជាប់ធ្លាក់មកក្នុងសមរភូមិ ស្រាប់តែបញ្ចេញរូបកាយដែលប្រឡាក់ដោយលោហិតមកនៅចំពោះមុខក្រុមប្រឹក្សាអមព្រះអង្គ ។ ព្រះមហាក្សត្រិយ៍និងព្រះរាជទីប្រឹក្សាមានសេចក្ដីឆ្ងល់សង្ស័យជាខ្លាំង ។ បុរសនោះក្រាបបង្គំទូលថា: "បពិត្រព្រះបរក្សត្រាធិរាជ, ទូលព្រះបង្គំបានបំពេញករណីយកិច្ចសព្វគ្រប់ហើយ, ឥឡូវនេះ សូមព្រះអង្គមានព្រះរាជបញ្ជាឲ្យគេយកប្រពន្ធទូលព្រះបង្គំមកប្រគល់ឲ្យទូលព្រះបង្គំ ទូលព្រះបង្គំនឹងវិលទៅប្រទេសវិញ" ។

ព្រះនរបតី, ក្រោយដែលទ្រង់បានព្រះសណ្ដាប់នូវពាក្យបុរសនោះ, ទ្រង់ក៏មានព្រះតម្រិះរកឧបាយនឹងឆ្លើយតបទៅបុរសនោះវិញ, តែមិនឃើញពាក្យអ្វីល្មមពោលឲ្យសមនឹងព្រះរាជហឫទ័យសោះឡើយ ។ ដោយទ្រង់មានព្រះរាជហឫទ័យខ្វល់ពន់ពេក, ទ្រង់ក៏ឈ្វៀងព្រះនេត្រទៅចំព្រះរាជទីប្រឹក្សា ។ យល់នូវព្រះរាជហឫទ័យព្រះអង្គ ក៏ដំរាបបុរសនោះថា: "ឱអ្នកជាវីរបុរស! ក្រោយដែលអ្នកអញ្ជើញទៅបាត់ ស្រាប់

តែឃើញក្បាលមួយដូចជាក្បាលអ្នក ធ្លាក់មកនៅចំមុខយើង ។ ដោយបានឃើញក្បាលនោះធ្លាក់មក, ភរិយាអ្នកឯងក៏ស្រែកទ្រហោយំរៀបរាប់ច្រើនយ៉ាង, ហើយនាងមិនព្រមស្តាប់ព្រះរាជឱវាទដែលទ្រង់ខំដាស់តឿននាង ៗ ក៏ទទួលមរណភាពក្នុងមួយរំពេច គឺមរណភាពជាមួយនឹងស្វាមីនាង ។

កាលណាព្រះរាជទីប្រឹក្សាបានឲ្យដំណឹង ទៅបុរសដែលជាស្វាមីនាងសព្វគ្រប់ប្រការ, បុរសនោះក៏ស្ងិតនៅស្ងៀមមួយស្របក់, ហើយដកដង្ហើមធំថ្វែង ហើយក៏ក្រាបបង្គំទូលព្រះអង្គថា "បពិត្រព្រះមហារាជ, ប្រជាជនក្នុងលោកសន្និវាសនេះបានសរសើរព្រះអង្គ ចំពោះព្រះរាជហឫទ័យស្មោះស្ម័គ្រក្នុងការប្រព្រឹត្តិព្រះរាជករណីយកិច្ច ព្រមទាំងព្រះរាជគុណសម្បត្តិជាច្រើនរបស់ព្រះអង្គ ។ ហេតុដូចម្តេច ក៏ព្រះរាជគុណសម្បត្តិនោះជាវត្តឥតអំពើចំពោះទូលព្រះបង្គំ ដោយទូលព្រះបង្គំគ្មានប្រព្រឹត្តខុស ចំពោះព្រះអង្គសោះឡើយ? បពិត្រព្រះមហារាជ, សូមទ្រង់ជ្រាបថា ព្រះអង្គជ្រាបស្រាប់នូវចំណុចដ៏ខ្លាំងដែលទូលព្រះបង្គំមានចិត្តស្នេហាចំពោះប្រពន្ធ, ប្រហែលជាទ្រង់សព្វព្រះរាជហឫទ័យចំពោះនាងដែរ តែទ្រង់មិនត្រូវបណ្តោយតាមព្រះរាជហឫទ័យសោះឡើយ ។ ទូលព្រះបង្គំមិនបានឃើញនាង, ទូលព្រះបង្គំមានទុក្ខពន់ពេក ។ ព្រះនរបតីទ្រង់ព្រះសណ្តាប់នូវវាចានៃបុរសនោះទ្រង់ក៏មានព្រះបន្ទូលថា: "យើងមិនមានចិត្តប្រតិព័ទ្ធនឹងភរិយាអ្នកឯងទេ" ។ បុរសនោះក្រាបបង្គំទូលថា: "បពិត្រព្រះមហារាជ, ទូលព្រះបង្គំបានឃើញនូវព្រះ

រាជហ្ឫទ័យដ៏ស្មោះស្ម័គ្រ ចំពោះការប្រព្រឹត្តនូវព្រះរាជករណីយកិច្ច ។ ឥឡូវនេះសូមទ្រង់ប្រគល់ភរិយាទូលព្រះបង្គំមកឲ្យទូលព្រះបង្គំវិញៈ ឬព្រះរាជទានព្រះអគ្គមហេសីទ្រង់មកឲ្យទូលព្រះបង្គំក៏បាន ។

មហារាជទ្រង់ព្រះសណ្តាប់នូវកថាបុរសនោះ ដោយទ្រង់ខ្វាបក្សត់ព្រះរាជករណីយកិច្ចរបស់ព្រះអង្គ, ទ្រង់ស្តេចយាងទៅកាន់ប្រាសាទខាងក្នុងព្រះបរមរាជវាំងទ្រង់បានចាប់ព្រះហស្តព្រះអគ្គមហេសី, ដឹកនាំចូលទៅក្នុងទីក្រុមប្រឹក្សាអមព្រះអង្គ ហើយទ្រង់ទតទៅចំបុរសៗ នោះក៏បាត់ខ្លួនពីទីនោះទៅ ។

ក្នុងវេលានោះវេតាលិកបានចូលមកក្រាបបង្គំគាល់ព្រះមហារាជហើយក្រាបបង្គំទូលថាៈ បពិត្រព្រះបមភព, ដោយអានុភាពនៃវិទ្យាសាស្ត្រ "ឥន្ទ្រជាល" (Indrajàla) ទូលព្រះបង្គំបានប្រសិទ្ធិនូវមន្តសាស្ត្រ ឬ មាយាវិទ្យា (Màyàvidya) ដែលព្រះអង្គទ្រង់បានទតយល់អម្បាញ់មិញនេះ, ទាំងអស់នេះជាការមិនពិតសោះឡើយ ។ ព្រះមហាបពិត្រ, ទ្រង់កុំព្រួយព្រះរាជហ្ឫទ័យ សូមទ្រង់គង់នៅជាសុខក្នុងសិរីរាជសម្បត្តិចុះ ។

ព្រះមហាក្សត្រិយ៍, ក្រោយដែលទ្រង់ព្រះសណ្តាប់នូវកថារបស់វេតាលិក, ទ្រង់មានព្រះរាជហ្ឫទ័យសោមនស្សឥតឧបមា, ទ្រង់បាននាំព្រះអគ្គមហេសីទៅកាន់ប្រាសាទខាងក្នុងព្រះបរមរាជវាំង, ហើយទ្រង់វិលត្រឡប់មកកាន់ទីប្រជុំក្រុមប្រឹក្សាអមព្រះអង្គវិញ ។ ក្នុងវេលានោះព្រះមហាក្សត្រិយ៍នៃប្រទេសបន្ទិយ (pandya), បាននាំសួយសាអាករ

ជាច្រើន គឺព្រះទ័នាំនគជាមួយរយ, អស្សតមួយរយ ទីនព្រះរាជសារវត្តឯទៀតមកថ្វាយព្រះអង្គ ។ ព្រះបាទវិក្រមាទិត្យទ្រង់បានយកវត្ថុទាំងអស់នោះប្រទានទៅវេតាលិក ។ បេញពីព្រះបរមរាជវាំងទៅបាត់ទៅ ។

រូបទេពនិម្មិតទី ២៩ ទូលបន្ទមថា: "បពិត្រព្រះបាទភោជ:, ព្រះបាទវិក្រមាទិត្យដែលទ្រង់បានប្រព្រឹត្តព្រះរាជករណីយកិច្ចជាសុក្រិតដូច្នេះ ទើបទ្រង់អាចគង់លើបល្ល័ង្កទិព្យនេះបាន ។

ក្រោយដែលទ្រង់ព្រះសណ្ដាប់នូវរឿងនេះ, ព្រះបាទភោជ:ទ្រង់លែងផ្ដើមព្រាកិសេកក្នុងពេលនោះ ។

*

* *

# និទាននៃរូបទេពនិម្មិត ទី ៣០

មានកាលមួយថ្ងៃ, រូបទេពនិម្មិតទី ៣០ បានក្រាបបង្គំទូលព្រះបាទភោជ:ថា "បពិត្រព្រះបាទភោជ: មានតែព្រះមហាក្សត្រិយ៍វិក្រមាទិត្យ ទើបអាចគង់នៅលើបល្ល័ង្កទិព្យនេះបាន; សូមទ្រង់ព្រះសណ្ដាប់អំពីព្រះរាជចរិយា ជាព្រះមហាសប្បុរសនៃព្រះមហាក្សត្រិយ៍នោះដូចតទៅនេះ ៖

នៅនគរអវន្ដី, មានមន្ត្រីធំមួយនាក់ឈ្មោះស្រីទត្ត (Cridatta) ជាអ្នកមានទ្រព្យសម្បត្តិច្រើនឥតគណនា ទាល់តែខ្លួនលោកមិនអាចដឹងនូវចំនួនទ្រព្យនោះបាន ។ មន្ត្រីធំនោះមានបុត្រម្នាក់ឈ្មោះសោមទត្ត (Somadatta) ។ មានកាលមួយថ្ងៃ, បុត្រនោះមានបំណងចង់សង់

ប្រាសាទមួយ ក៏ទៅប្រឹក្សាជាមួយនឹងបិតាអំពីរឿងនេះ ។ បិតាយល់ព្រមតាមបំណងបុត្រ ។ ក៏ប្រុងប្រៀបសាងប្រាសាទនោះក្នុងពេលគាក់បុស (Pusha) ធ្វើដំណើរមកជួបគ្នានឹងព្រះសុរិយា ។ ដល់ថ្ងៃកំណត់, សោមទត្តក៏តាំងផ្ដើមសាងប្រាសាទ, ថ្ងៃស្អែក, ប្រាសាទនោះក៏ហើយស្រេច ។ សោមទត្តក៏បានជ្រើសរកថ្ងៃពិសិដ្ឋដែលល្មមសមនឹងចូលទៅនៅក្នុងប្រាសាទនោះ ។ លុះពេលយប់, សោមទត្តទ្រានៅលើគ្រែស្នែងក្នុងប្រាសាទនោះ ក៏បានឮសូរសំឡេងខ្លាំងថា: បតិ, បតិ, (ប្រែថាធ្លាក់, ធ្លាក់) ។ ដល់បានឮសំឡេងដូច្នេះ, សោមទត្ត, ក៏សង្ស័យភិតភ័យ និទ្រាមិនលក់សោប់សល់ជាខ្លាំង ។

ថ្ងៃស្អែកឡើងដោយមានចិត្តឆ្ងល់ពន់ពេក, សោមទត្តក៏ចូលទៅក្រាបបង្គំទូលព្រះបាទវិក្រមាទិត្យអំពីរឿងនេះ ។

ព្រះនរបតី, គ្រាយដែលទ្រង់ព្រះសណ្ដាប់នូវពាក្យបុរសនោះ ទ្រង់បានទិញប្រាសាទនោះពីសោមទត្ត, រួចដល់ពេលយប់ទ្រង់យាងទៅកណ្ដាលប្រាសាទនោះ ស្រាប់តែមានសំឡេងមួយឮចេញមកពីក្នុងប្រាសាទថា "បតិ, បតិ" ។ ដល់ទ្រង់ព្រះសណ្ដាប់នូវសំឡេងនោះ, ហោកដទ្រង់មានបន្ទូលតបទៅវិញថា "បតតុ" "ចូរធ្លាក់មកចុះ" ។ ងមួយរំពេចនោះ, ស្រាប់តែភ្លៀងមាសធ្លាក់មកក្នុងប្រាសាទតាំងពីព្រប់រហូតដល់ភ្លឺ ។ នៅគ្រប់ក្រឡាព្រះបន្ទំព្រះអង្គមានភ្លៀងផ្កាធ្លាក់មក ។

ដល់ពេលបច្ចូសសម័យ, ព្រះមហាក្សត្រិយ៍ទ្រង់បានព្រះរាជទានទៅសោមទត្តវិញនូវប្រាសាទទឹងមាស ដែលផ្លាក់ពេញប្រាសាទទាំងអស់ ។ រួចទ្រង់ក៏ស្តេចយាងទៅកាន់មហាសន្និបាតនៃក្រុមប្រឹក្សាអមព្រះអង្គ ។

រូបទេពនិម្មិតទីសាមសិបក្រាបទូលបន្ថែមថា: "បពិត្រព្រះបាទកោជៈ, បើទ្រង់មានព្រះតេជានុភាពព្រមទាំងមហាសប្បុរសធម៌បែបនេះ, ទ្រង់អាចគង់លើបល្ល័ង្កទិព្វនេះបាន, បើមិនដូច្នោះទេ, ទ្រង់មិនអាចគង់លើបល្ល័ង្កទិព្វនេះបានឡើយ ។ ព្រះបាទកោជៈ, ក្រោយដែលទ្រង់ព្រះសណ្តាប់នូវរឿងខាងលើនេះ ទ្រង់ក៏លែងធ្វើរាជាភិសេកក្នុងពេលនោះទៅ ។

(មានត)

## ប្រយោជន៍របស់រឿង

រឿងបល្ល័ង្កទិព្វនេះកល្យាណ ជារឿងដ៏បានគតិពិត
ខាងអប់រំមនុស្សឲ្យប្រព្រឹត្ត នូវធម៌សុចរិតជាសប្បុរស ។
មានគុណប្រយោជន៍ដ៏ប្រសើរ ដល់លោកអ្នកមើលយល់សម្ផស្ស
ចាំរឿងសព្វគ្រប់ចប់ទាំងអស់ ឲ្យធ្វើសប្បុរសតាមយ៉ាងល្អ !

បាប - ពិន

# សាស្ត្រាចចក

ជាគតិដំបូន្មានមិនឲ្យលោភ

## លោក បាប-ពិន ពិនិត្យកែសម្រួល

ចំពោះពាក្យដែលភ្លាំងភ្លាត់ឲ្យត្រូវសេចក្តីនឹងក្បួនកាព្យឡើងវិញ

---

នេះបទកាកា - គតិបរបា តែងបងរៀងកាយ តាមពាក្យពីព្រេង តែងនិយាយ ដំណើរអតិព្រាយ ពីសត្វចចក ៗ យោនយកកំណើត កំណត់កាលកើត ពឹងពួនជ្រៀតជ្រក ក្នុងរូងថ្មកំ ជាវធំសៀតសឹក សព្វថ្ងៃចចក ស្វែងរកភោជនា ៗ ប្រែបន្ទោរគួរស្អឹង ត្រពាំងបួបឹង ជ្រោះជ្រោយបព្វតា លុះយប់ផ្លាល់ផ្លាប់ ចុះចាប់មច្ឆា តែងបរិភោគ្គា សព្វថ្ងៃប្រក្រតី ៗ រូបទាបក្រញឹញ បាទបួនតឿទេញ តឿតូចអប្រិយ តែងដើរលោកលះ ស្វែងស្វះរកស៊ី ព្រួយនៀយត់ទ្រួយ ស្គាំងស្គមអាត្មា ៗ ពីកាលក្មេងនៅ មេស្លាប់ចោលទៅ នៅតែនឹងបា នាំដើររកស៊ី ប្រែបទីជលសា លុះធំកាលណា បាស្លាប់បង់បាត់ ៗ ចចកនោះនៅ ទល់ទុក្ខកាត់ក្តៅ ក្នុងថ្ងៃម្របមាត់ ឥតមេឥតបា កំព្រាព្រាកព្រាត់ ស្ងប់ស្ងាត់ស្ងៀមស្ងាត់ ត្រមោចម្នាក់ឯង ៗ ចចកគន់គិត រំពឹងក្នុងចិត្ត រឹងរឹតចំបែង ដើររកភោជនា កោក្តាកណ្តាន កណ្តោចឯកឯង ឥតមានគ្នីគ្នា ៗ វេលាចូលដេក ក្នុងរូងដំណេក ត្របក្បៀងរង៉ា ខ្យល់បក់ស្ងប់ស្ងាត់ ថ្ងៃមស្ងួតគ្រាំគ្រា ក្រំក្រៀមកំព្រា កំព្រានពេកពន់ ៗ ចចករិះគិត បានឃើញគំនិត មួយនោះជាល់ទ ថាអញត្រូវរក ត្រូវយកប្រពន្ធ ទើបបាននឹងស្រន្ត នឹងស្រាលទុក្ខា ៗ គ្រាន់ជាគូផៅ ស្នេហានៃបនៅ

កូនរូងបព្វតា បបកគិតហោះ ក្រោកស្ទុះយាត្រា ត្រាច់កូនព្រឹក្សា
ស្រងូតស្រងាត់ ៗ ដើរត្រាច់តែឯង កណ្ដាបកណ្ដែន កំព្រាព្រាកព្រាត់
ត្រមោចត្រមង់ នៅក្នុងព្រៃស្ងាត់ ប្រទះហ្វូងសត្វ គោតគោមហិង្សា ៗ
ទន្សោងទន្សាយ ដំរីប្រើសព្រាយ ឈ្លូសក្ដាន់សូកព រមាសរមាំង
ខ្ទីងខ្លាំងខ្លោងខ្លា ដើររកគោក្ដា សឹងសត្វយង់យួង ៗ បបកឃើញសត្វ
សាហាវវង្គាត់ ប្រែនក្រែកកន្ទួង កៀងកាល់គូប ខ្សៀវខ្សាអឹងកង
ភិតភ័យកន្ទួង ស្ទើរបាត់ស្មារតី ៗ ខំដើររំលង ជៀសសត្វយង់យួង
បានដល់នទី ស្ទឹងមួយថ្លាជ្រះ ត្រពះយល់ដី បបកចាប់ត្រី
ចំអែតកាយា ៗ ហើយហែលឆ្លាស់ឆ្លង ស្ទឹងនោះរំលង ដល់ត្រើយគង្គា
ត្រាច់កូនរបោះ បន្ទោះអត្លា មានរូងគូហា ជិតជើងគិរី ៗ
បបកចូលជិត ប្រុងប្រាណមូលមិត្ត មៀងមើលរកញី ខុនចុះងើបងើក
ចំអើតមើលទី ក្បែណានោះមានញី បបកមួយណា ៗ នៅក្នុងរូងថ្ម
សិលាដំល្អ ក្បាលសមកាយា បបកឈ្ងោលគិត ក្នុងចិត្តថៃថា
គួរអញសួរសា បន្តិចទើបបាន ៗ ទើបឈ្ងោលហៅរក ថាប្អូនពន្ទក
មិត្តម៉ុមកល្យាណ នៅក្នុងរូងថ្ម ល្អះល្អថ្កើងថ្កាន សព្វថ្ងៃតើមាន
ប្ដីជាគូគ្រង ៗ ឬនៅឯកឯង ប្អូនអើយចូរថ្លែង ប្រាយប្រាប់បងផង
ឲ្យបងរសាយ កូនកាយនេះហោង បើឥតគូគ្រង បងសុំស្នេហា ៗ
បបកញីស្ដាប់ ឆាកហើយថ្លែងប្រាប់ ថាអ្នកសោភា ប្អូននៅសព្វថ្ងៃ
អាស្រ័យគូហា មិនមាននរណា ជាគូឡើយនៃ ៗ កាលដើមមានមេ
មានបាបំពេ ខុបក្រុងសព្វថ្ងៃ ឥឡូវមេបា មរណាក្សិណក្ស័យ

ប្អូននៅសព្វថ្ងៃ កំព្រាពេកពន់ ៗ ឈ្មោលឮដូច្នោះ ព្រឺព្រួចពង់ពោះ ហឫទ័យអោរទន់ ទើបឆ្លើយតបវិញ ថាប្អូនក្សាស្ងួនតន់ ប្អូនអើយបងគន់ បងគិតអនិច្ចា ៗ អាសូរប្អូនស្ងួន មាសមិត្តខ្ញុំខ្លួន កំព្រាឯកា ដូចកល់ខ្លួនបង សៅហ្មងចិន្តា សព្វថ្ងៃបងមហា ព្រួយណាស់ប្អូន អើយ ៗ បងកញ្ញាស្តាប់ ពាក្យឈ្មោលថ្លែងប្រាប់ ឆ្លើយថាអ្នកអើយ ប្អូនស្តាប់ពាក្យអ្នក ដៀងផាក់ទៅហើយ ក្នុងចិត្តឥតស្បើយ កើតទុក្ខ ទៀតថ្មី ៗ ប្អូនចង់សូមសួរ ហៅមហាមិនគួរ ដ្បិតខ្លួនជាស្រី អ្នកថាព្រួយចិត្ត ព្រោះគិតរឿងអ្វី ប្រុសប្រាជ្ញប្រឹមប្រិយ ប្រាយ-ប្រាប់ប្អូនក៏ ៗ ឈ្មោលថាមាសមិត្ត បងព្រួយព្រោះគិត ដល់គូស្នេហា គ្មានគ្នាជាតារ បំណោរអនា- គតបងហៅមហា ថប់ណាស់មាសបង ៗ ញីថាប្រុសអើយ កុំថប់អ្វីឡើយ ប្អូនជានារី រះរកជួយគិត តាមចិត្ត-អ្នកបង ត្រង់តាមបំណង ចិត្តអ្នកប្រាថ្នា ៗ ឈ្មោលថាមាសមិត្ត បងប៉ងផ្ចិតចិត្ត ផ្ញើដួងជីវ៉ា នៅលើប្អូនស្ងួន សូមទួនមេត្តា បងមិនប្រាថ្នា ដទៃពីពៅ ៗ ញីឆ្លើយថាអ្នក ចិត្តចង់រួមរ័ក្ស មួលមួយលំនៅ ផ្ញើដួងចិន្តា ស្នេហាតទៅ ទឹងប្អូននេះគួរ ពេញ មហាអរពេក ៗ ប៉ុន្តែប្អូនយល់ ប្អូនគិតទៅដល់ ធ្លល់ធ្លាយបំបែក ស្ថានអ្នកឯនាយ សប្បាយអនេក មានញីយ៉ាងឯក គួរគូស្នេហា ៗ មេត្តអ្នកមិនមាន ចិត្តចាប់ចង់បាន ជាគូជីវ៉ា ហើយប្រែលាក់លះ ស្វែងស្វះពុះពា ត្រាច់ព្រៃអាធ្វា មកដល់ស្ថានអាយ ៗ ឈ្មោល ស្តាប់ឆ្លើយធ្លាស់ ថាហៃប្អូនមាស មានរូបឆោមឆាយ ឆោមឆើតទន្ទ្រង

ស្ថានបងឯងនាយ មែនហើយសប្បាយ ដូចពាក្យប្អូនថា ។ គឺមោះ
បងរក គូគាប់ទឹងយក ជាតិជាពន្ធុគា ទឹងផ្ចិតខ្លួន ដូចស្ងួនទេះណា
គ្មានសោះបងមហា ចប់ពេកនាងអាយ ។ ហេតុនោះបងស្ងួះ
បងស្វែងលាកលះ មកដល់ស្ថានអាយ បងប៉ងផ្ញើខ្លួន លើប្អូន
ធោមធាយ ព្រួយទៀយអង្គកាយ ម្តេចៗមិនគិត ។ លែង
តែប្អូនស្រី មាសមាទមេត្រី មេត្តាមូលមិត្ត មូលមួយពិត្ត
ស្នេហាដួចដិត ដួបចាប់ប្រេត្ត ជាគូរសនា ។ ញីស្តាប់ឆ្លើយ
ឆ្លៀត ឆ្លើយឆ្លងវិញទៀត ថាប្រុសស្នេហា ពាក្យក្រៅល្អល្អះ គួរ
សះសង្កា លួងលោមចិន្តា បានហើយហោះបង់ ។ ឈ្មោលឆ្លើយថា
ហៃ ប្អូនមាសថ្លើមថ្លៃ បណ្តាលសាច់ស- ង្ហាសេមសោភា កាយា-
វរវង្ស វរពាសអស់អង្គ អស់ឥតសង្ស័យ ។ បងមហាស្រឡាញ់
ប្អូនមាសឈ្លួយឆ្លាញ់ ចិត្តចាប់អាល័យ អាលោះលើសលន់ ពេកពន់
ក្រាស់ក្រៃ ពុំបានបងក្សយ ជីវិតជាម្ជង ។ ឈ្មោលថាតែម្ញោះ
ចូលជិតចំពោះ ផ្ទឹមផ្ទាប់ហើយហោង ថើបថ្ពាល់ព្នខ្សែត ចំកឹតផ្អឹងខ្នង
ថាហៃមាសបង នាងកុំខេវខឹង ។ បំណាច់បងមក រកប្អូនពឆ្លក ឆ្លង
អួរឆ្លងស្ទឹង មិនស្តាយជីវិត ព្រោះចិត្តរំពឹង ទុកប្អូនព្រលឹង ជាដួង
ស្នេហា ។ ញីអៀនអន់អាក់ ទនមុខទុកក្រ្ត ចូលចិត្តចិន្តា
សេពសុខក្សេមក្សាន្ត ក្នុងស្ថានគូហា ទើបឈ្មោលលោមថា
ព្រលឹងបងអាយ ។ បងចង់នាំទៅ វិលវិលចរទៅ ស្ថានបងឯនាយ
តើនាងនឹងថា ម្តេចម្តាប្អូនអាយ ញីឆ្លើយប្រាប់ប្រាយ ថាតាមចិន្តា ៗ

អ្នកនាំប្អូនទៅ ទីស្ថានលំនៅ ម្តេចៗមិនថា ឈ្មោលពុដូប្នោះ
នាំស្មោះយាត្រា បណ្តើរពន្ទីតា បវត្កានស្ថានស្ថិត ៗ លុះបានដល់ទី
លំនៅនាំញី បរបួលមូលមិត្ត មូលមួយក្នុងស្ថាន ក្សេមក្សាន្តនៃបទិត្យ
ឥតមានភ័យភិត បៀតបៀនឡើយណា ៗ លុះនៅយូរទៅ ចចកញីត្រូវ
គាប់កើតគភ៌ ទំម្ងន់ពេញពោះ ចិត្តស្មោះប្រាថ្នា ចង់បរិភោគ្គា
ត្រីក្នុងសមុទ្រ ៗ ញីលោមឈ្មោលថា អ្នកប្រុសស្នេហា ថ្លាថ្លៃវិសុទ្ធ
វិសេសវិសាល ស្នេហ៍ស្នាលបំផុត ដ្បិតប្អូនមានបុត្រ ពេញ
ផ្ទៃហើយណា៎ ៗ ឥឡូវប្អូនចង់ បរិភោគបំណង សមុទ្រមច្ឆា សូម
អ្នកប្រោសប្រាណ ស្មោះស្មានចិន្តា រកឲ្យប្អូនក៏ បរិភោគសោះចង់ ៗ
ឈ្មោលពុដូប្នោះ ញីប្រើចំពោះ ក្រោកក្រសួសត្រេចត្រង់ ទៅរកមច្ឆា
ដោយនាបំណង វេលាថ្ងៃត្រង់ ថែងចាំងរេហាស៍ ៗ ត្រូវក្រួស
ខ្សាច់ក្តៅ លុះដើរតិចទៅ សង្កៀវបាទា ពុះពងរងឈាម រអាម
រអា លុះលាន់មាត់ថា យីក្តៅម្តេចម៉្លេះ ៗ បើជាខ្លួនអញ
ចង់ស៊ីឲ្យឆ្ងាញ់ មាត់តាមសំណោះ អញមិនព្រួយប្រាណ រុក
រានដល់ម៉្លេះ ព្រោះតែវានេះ វាប្រើអញបាន ៗ លុះដើរទៀតទៅ
រងឹរងក្តាត់ក្តៅ រន្ធត់ក្នុងប្រាណ បែកញើសហូរហត់ ខំអត់ធ្វើក្សាន្ត
ទឹងវិលក្រោយខាន ខ្លាចញីបន្ទោស ៗ ម៉្លោះហើយប្រឹងមិត ប្រឹង
បោលរងឹរត ក្តៅដល់ដួលស្រួស ប្រឹងក្រសក្រោកឡើង ស្រមើង
ប្រឡូស មើលមុខស្រមូស ស្រមូញមាត់ស្ងួញ ៗ ខំបោលទៀតទៅ
រងឹរងកាត់ក្តៅ ក្នុងថ្ងើមអម្នេញ អន្ទាស់អន្ទួង ខំខែងបោលខ្លាញ់

វិលក្រោយក្រែងចាញ់ ប្រាជ្ញាញីនោះ ៗ ម៉្លោះខំលោលោត ប្រាស់
ផ្ទិចភ្នាមផ្អោត មួងទៅទៀតស្លុះ រឹងក្តៅបាទជើង ដូចភ្លើងពោរពុះ
ផ្លូវទៀតនៅនោះ បម្រាស់ប្រាស់ប្រាណ ៗ ក្តៅអស់ឥន្ទ្រិយ ដូច
កល់អគ្គី ដុតពេលពុំក្សាន្ត ញាំអង្គរន្ធត់ ប្រឹងអត់ពុំក្សាន្ត ក្រោក
ទ្បើងឈរឈាន បែរបោលទៀតទៅ ៗ រិតរឹងក្តៅណាស់ លាន់
មាត់ថាអះ ទុះទុះពេញក្តៅ អញបង់តែអត់ សង្កត់ខ្យល់នៅ ឲ្យ
ស្លាប់ផាប់ទៅ កុំឲ្យវេទនា ៗ ដល់គិតវែងទៅ ក្រែងកើតហ្មងសៅ
កើតក្តៅទិន្នា ថាទុចបក កំព្រាកមោហា ក្សិណក្ស័យជន្មា ព្រោះ
ញីបញ្ឆោត ៗ បើទឹងស្លាប់រស់ ឲ្យព្រុកក្តៅយស គេមានកំណោត
មាំនពាក្យសរសើរ ថាអើអញកោត បចកនេះសោត ពេញហោ
ហានក្លា ៗ គិតហើយបោលទៅ ជិតទឹករណ្តៅ ថាយើនរណា
បង្កើតជាក្តៅ ហ្មងសៅចិន្តា ងើយមើលមេឃថា យើក្តៅព្រោះថ្ងៃ ៗ
អើអញជាតិនេះ លំបាកទាំងម៉្លេះ ព្រោះតៀទាបក្រៃ កើតជាបចក
កំព្រាកបង្រៃ ជាតិក្រោយអញឆ្នៃ អញសូមសច្ចា ៗ ទោះបីកបកើត
យោនយកកំណើត ជាតិណាកតណា អញសូមសម្រេច សេចក្តី
ប្រាថ្នា កើតជាសុរិយា រុងរឿងរង្សី ៗ

កាលនោះមានយក្ស ប្រេតមួយសំណាក់ ស្ថិតស្ថានប្រក្រតី
នៅលើបព្វតា ទៀបនាវិថី យក្សព្រួសំដី បចកប្រាថ្នា ៗ យក្សគិតថា
អើ មហាលាភប្រសើរ ទឹងបានអាហារ ត្រកាលចំណី ល្អក្រៃថ្លៃថ្លា
ទឹងបរិភោគា ទូរសាចបចក ៗ គួរអញក្រឡា ជាអគ្គឥន្ទ្រា

ប្រាប់ឲ្យយក សាច់ឈាមជាទាន នឹងបាននិរោគ កំណើតបានមក
កើតជាសុរិយា ៗ យក្សគិតដូច្នោះ គាឡាចំពោះ ជាអង្គឥន្ទ្រា
រំពេចពោះហើរ ស្ថិតលើវេហាស៍ ហើយមានវាចា សាកសួរ
មេត្រី ៗ ថាហៃចចក អ្នកត្រេចដើរមក ពីណារកអ្វី ចចកក្រឡេក
ឈ្លៀងភ្នែករំពៃ ស្មានអង្គកោសី ទើបទូលទៅថា ៗ បពិត្រព្រះឥ-ន្ទ្រា
ទ្រើសនិទ្ទ ឥស្សូរសុជាតា ខ្ញុំមកស្មានស្មោះ ចំពោះប្រាថ្នា រកចាប់មច្ឆា
នៅក្នុងជលធី ៗ បើបានមច្ឆា ដូចប៉ងប្រាថ្នា យកទៅឲ្យញី ដ្បិតមាន
ផ្ទៃពោះ ចិត្តស្មោះចង់ស៊ី ត្រីក្នុងជលធី ទើបឆ្ងាញ់ណាស់ណា ៗ ហេតុ
នោះខ្ញុំមក រុករាននិរោគ សមុទ្រមច្ឆា ដើរដាច់ក្រសក្តៅ ហ្មងសៅចិន្តា
ពុំពេញបាទា រន្ធត់អង្គប្រាណ ៗ បែកញើសហូរហាត់ ក្តៅណាស់ប្រាកដ
អាចអត់ពុំបាន ព្រោះថ្ងៃចាំងចែង សូរ្យសែងថ្កើងថ្កាន ទើបខ្ញុំប្រណិធាន
អធិដ្ឋានថា ៗ បើខ្ញុំនឹងកើត យកជាតិកំណើត ក្រោយខ្ញុំប្រាថ្នា
តាំងចិត្តចង់បាន ដូចក្នុងចិន្តា កើតជាសុរិយា ប្រាកដដូចប៉ង ៗ
បពិត្រឥន្ទ្រា សូមស្តេចមេត្តា ជួយខ្លួនខ្ញុំផង ធ្វើម្តេចនឹងបាន ដូច
ក្នុងបំណង ប្រែតយក្សឆ្លើយឆ្លង ថាងាយណាស់ណា ៗ បើចៅ
ចង់បាន ដូចចិត្តបំណាន បំណងប្រាថ្នា ចូរទៅផ្តិលផ្តាច់ សំរេចជន្មា
យកសាច់ឲ្យជា ទានយក្សបិសាច ៗ ហេតុផលអានិសង្ស ជួយជូន
ទ្រទ្រង់ កើតមានអំណាច ជាសែងសូរ្យ រស្មីចិញ្ចាច ចិញ្ចែង
ត្រដាច ដូចចិត្តប្រាថ្នា ៗ ចចកស្តាប់គិត ជឿជាក់ចូលចិត្ត ទើបទូល
ទៅថា ខ្ញុំចង់ឲ្យទាន សាច់ប្រាណហើយណា ប្រែតយក្សឆ្លើយថា

សាធុពីរដង ៗ ប្រេតយក្សថាម្នោះ និមិត្តចំពោះ បាំងបាត់ទៅហោង
ចចករត់ចេញ ពោលខ្ញាញ់ជាម្តង គិតថាអញបង បានដូចសេចក្តី ៗ
ចចកគិតខ្មោះ ពោលដល់ទឹកចុះ លុយលបចាប់ត្រី លុះចាប់ត្រីបាន
ដូចភ្នានសេចក្តី ប្រាថ្នាតាំងត្រី ឲ្យញីគោក្តា ៗ ញីឃើញឈ្មោល
ដល់ បានត្រីខ្វាយខ្វល់ ទទួលមច្ឆា បរិភោគផ្សាយផ្សព្វ ស្កល់ស្កប់
ចិន្តា ទើបឈ្មោលប្រាប់ថា ហៃប្អូនពីសី ៗ កាលបងទៅយក
មច្ឆានាំមក ឲ្យប្អូនប្រឹមប្រិយ ហៅមហាព្រួយប្រាណ ពុំក្សាន្តណាស្រី
ស្មើរទានចុះត្រី មកផ្ញើប្អូនក្យ ៗ ប្អូនអើយថ្ងៃក្តៅ ដើងបងពង់នៅ
រអាមអគ្គិ ក្តៅដល់កង់ថ្មើម ដង្ហើមទំយា ដល់ដួលប្រើនគ្រា
ស្មើរិលក្រោយខាន ៗ បងខំពោលទៅ ប្អូនអើយរងក្តៅ រន្ធត់អគ្គិប្រាណ
បងពោលហើយគិត កង់ចិត្តថាស្មាន ប្រែបាលទាហាន ចង្រាំងសឹកមួយ
សោះ ៗ គេដះសំណាង សំណួមសួមសាង ពីមុនមកនោះ បានជួបស្ត្រី
យាត្រាចំពោះ ហើយស្តេចអនុគ្រោះ ស្មោះស្មានមេត្រី ៗ
ប្រដៅទូន្មាន នាំជានិទាន ឲ្យដឹងសេចក្តី បុណ្យបាបត្រូវខុស
ហើយហោះចេញខ្ចី បងចេញចាកទី រកចាប់មច្ឆា ៗ ចចកប្រាប់ញី
សុះសព្វសេចក្តី គ្មានខ្វះត្រង់ណា ហើយលោមថាប្អូន ខ្ញុំមខ្លួនស្នេហា
អញបងចង់លា ទៅក្ស័យជីវិត ៗ យកសាច់ជាទាន ប្រាថ្នាឲ្យបាន
ជាព្រះអាទិត្យ តើប្អូនទឹងថា ម្តេចម្តាមាសមិត្ត ញីស្តាប់ហើយគិត
ធុញថៃរថប់ថា ៗ អ្នកមាសប្អូនអើយ ប្អូនថាម្តេចអើយ ចិត្តអ្នកប្រាថ្នា
មិនហ៊ានទាំងឃាត់ ឲ្យភ្ញាត់សង្ហា ក្រែងកើតទោសា ដាបដិតដល់ប្រាណ ៗ

គឺមោះប្អូននៅ ក្រោយអ្នកប្រុសទៅ ពោះបង់ចោលស្ថាន ប្អូនកើតទុក្ខត្រូវ

តារព្រួតពុំក្សាន្ត ទុក្ខមួយព្រោះមាន ទម្ងន់ពេញពោះ ៗ

ទុក្ខមួយព្រោះព្រាត់ ព្រោះប្រាសសូន្យស្ងាត់ សូន្យស្ងៀមក្រៀមក្រោះ

ក្រៀមក្រំក្នុងចិត្ត ផ្អែតផ្អិតអាឡោះ អាល័យស្រណោះ

អ្នកប្រុសប្រាសទៅ ៗ សព្វថ្ងៃរំពឹង អ្នកមាសព្រលឹង ស្មានថាអ្នកនៅ

នៃបទិត្យនុក ស្នេហាតទៅ ប្អូនឥតញាតិផៅ សង្ឃឹមតែអ្នក ៗ

ជាគូស្នេហា ទុកស្មើបិតា មាតារួមរក្ស រួមរសស្នេហ៍ស្នង

ប្អូនប៉ងទុកដាក់ ផ្ញើខ្លួនលើអ្នក លុះអស់ជន្មា ៗ ហេតុនោះប្អូនស្ទះ

ប្អូនស្ទើរលាក់លះ ចោលទីគោហា ដិតដោយតាមអ្នក វិល័ក្ខណ៍សោភា

ម្តេចឡើយឃ្លាតឃ្លា ពីខ្លួនប្អូនពៅ ៗ · ញីថាតែម៉្លោះ នុនមុខទុក្ខចុះ

ទុកធ្លួលក្តៅ ហាក់ដូចអគ្គី ឆេះពីពោះទៅ ទល់ទុក្ខហ្មងសៅ

ដោរដល់នេត្រា ៗ ស្ងៀមស្ងួតស្ងាត់ស្ងប់ ពុំចេញសារសព្វ

សារសង់ពចា រំងក្តៅក្នុងថ្លើម ដង្ហើមទុក ទើបឈ្មោលឈោមថា

សំឡាញ់បងអើយ ៗ កុំនាំអាលោះ អាល័យសោកសោះ

សោកសោតត់ត្រើយ បើបងបានកើត កំណើតម៉្លោះហើយ

បងមិនគោះតើយ ទីទៃចោលពៅ ៗ សឹមបងមកយក ប្អូនស្ងួនពន្លក

បីបមថ្នមទៅ ដាក់លើពិមាន ទិព្វស្ថានផ្អិនផ្អៅ មូលមួយលំនៅ

នៃបទិត្យស្នេហា ៗ ចូរប្អូនស្រីស្រួល ស្រីស្រស់ទទួល អនុមោទនា

ព្រមព្រឹសទឹងបង ដូចប៉ងប្រាថ្នា កុំនាំរួញរា បើកបងតាមចិត្ត ៗ

ញីស្តាប់ឈ្មោលថា ហាក់ធូរទុក សោកាស្បើយស្បិត បន្ទោទុក្ខស្រាល

ស្រយាលក្នុងចិត្ត ទើបឆ្លើយប្រឌិត ថាតាមចិន្តា ។ អ្នកទឹងផ្តិលផ្តាច់ ជីវិតយកសាច់ ជាទានប្រាថ្នា យោនយកកំណើត កើតជាសុរិយា ប្អូនសោភគសទ្ធា សាធុនឹងអ្នក ។

ដំណើរចចក មោហាកំព្រក ឈប់ស្ទះដៀងជាក់ នេះនឹងចាប់នី-ទានពីប្រេតយក្ស ស្ថិតស្ថានសំណាក់ នៅលើបព្វតា ។ យក្សនិម្មិតមក លបមើលចចក យក្សស្តាប់ឮថា ចចកផ្តិលផ្តាច់ សម្រេចជន្មា យក្សអរ-ហើយថា បរមលាភពេក ។ ហើយយក្សនិម្មិត បញ្ចូលក្នុងចិត្ត ចចកឲ្យត្រេក កាត់ចិត្តឲ្យទាន សាច់គ្មានអល់ឯក ហើយប្រេតយក្សស្រែក ឲ្យសាធុការ ។ ចចកឈ្មោលញី លុះឮសំដី ប្រេតយក្សឲ្យសា-ធុការដូច្នោះ ស្រួលស្រុះចិន្តា លង់លុះសុរិយា អាប់អស្តង្គត ។ នាំញីចូលដេក ក្នុងរូងដំណេក ដូចដេមកំណត់ ទឹងថ្ងៃឯព្រៃ ធំក្រៃក្រាកដ ប្រែបន្ទេរសមុទ្រ គាប់កាលនោះណា ។ មានយក្ខ-ទី ប្រេតប្រាសឥតប្តី នៅក្នុងព្រឹក្សា យក្សត្រេចរកប្តី ឃ្លាតខ្វី យាត្រា បានដល់បព្វតា ដែលយក្សប្រុសនៅ ។ យក្សស្រីឃើញម្លប់ ត្រជាក់ចូលឈប់ បន្តិចបាត់ក្តៅ យក្សស្រីប៉ះអញ ឃ្លាតខ្វាញ់កល ក្រៅ ដើរហាលថ្ងៃក្តៅ សៅហ្មងក្ត្រា ។ យក្សស្រីគិតដូច្នោះ ដើររក ទឹកជ្រោះ ឆ្ងុះមើលមុខា ឃើញហើយផ្អៀងផ្អង ឈ្ងៀងឈ្ងងនេត្រា យក្សស៊ើបហើយថា នៅល្អដែរទេ ។ អញង្ងូតទឹកលាប លាង ក្អែលឆ្អេះឆ្អាប ឲ្យក្រាន់ជាងគេ ថាស្រស់យក្សស្រី ឃ្លាតខ្វីរាកពេ រកជ្រោះង្ងូតថៃ ដុសសព្វកាយា ។ ហើយយក្សឡើងយក សំពត់បាន

មក ស្លៀកហើយយាត្រា ដើរទៅហើយគិត ក្នុងចិត្តយក្សថា ចង់
បៀងសិនហ៎ ឲ្យបានស្បៀងទុក ។ យក្សស្រីគិតហ្នោះ ចាប់ក្បិនចង់
បុះ រេក្បាលងើយមុខ គន់មើលរូបរាង ដូចពានប្រហុក ម្ល៉ោះចំញុក-
ញ៉ក ញុំាញុីដើរលេង ។ រេករែកកំ បាទាទន្ទាំ ទន្ទើរទន្ទេង
អង្គុយក្វាមបុះ ដើងគោះជាភ្លេង ទះដៃបៀងលេង ងើកងោកសិរសា ។
ក្រឡេកស្តាំឆ្វេង ស្តាប់ទៅសំឡេង ដូចហ៊ុងសោកា គគ្រោកគគ្រាក់
រលាក់ញាក់ស្មា ពុងល់យក្សា ប្រែតស្ទិតលើភ្នំ ។ យក្សថាសំឡេង
នរណាបៀងលេង លាន់ពុរធំ ថាហើយយក្សប្រុស បរបុះ
ដើងភ្នំ ហើយយក្សសំងំ លបលួចមើលមៀង ។ មើលមិញស្គាល់
ជាក់ ថាអះនុយក្ស ស្រីទៅស្រកបៀង យក្សប្រុសចង់ស្និទ្ធ
បៀតជិតបញ្ចៀង ផ្ទឹមផ្ទាប់ផ្ទាល់ផ្ទៀង សាកសួរទៅថា ។
នាងស្រីក្រមុំ រូបរាងឧត្តម នាងមកពីណា យក្សស្រីថាខ្ញុំ ខិតខំ
យាត្រា ចេញពីព្រៃក្បា ដើររកចំណី ។ យក្សប្រុសថាអើ លោក
លន់លុះលើ បំណងសេចក្តី ប្រាថ្នាអញប៉ង ចង់ចងមេត្រី
ទឹងនាងប្អូនស្រី ជាគូស្នេហា ។ យក្សស្រីថាកុំ លេងស៊ុនពេកខំ
ហៅម៉ែអញណា យើងមិនជាស្រី អប្រិយទេណា យើងមានមេបា
ពូជពង្សគ្រាន់បើ ។ យក្សប្រុសថានុ អញពង់តែរក៏ ·ពុំទ្លាទេតើ
នរណាធ្វើអ្វី ប្អូនស្រីគ្រាន់បើ យក្សស្រីថាអើ គ្មានធ្វើអ្វីទេ ។
ប៉ុន្តែមាក់ងាយ ហ៊ានហានិយាយ ស្រដីចង់បែ ខំលេងពាក្យជ្រៅ
អញទៅប្រាប់ម៉ែ យក្សស្រីគិតតែ ការកើតចិត្តញួង ។ ប្រុសថា

ប៉ៃអញ ព្រោះបងស្រឡាញ់ ទើបបងហ៊ានលេង ចុះស្ត្រី
សេចក្តីចេះឯង មាសមិត្តមិនឈ្នង សង្ការសោះថ្វ ៗ យក្សស្រី
ថាស្អប់ ពាក្យប្រុសប្រសប់ ស្រដីពោលលើ ថ្មោងថ្មីស្រឡាញ់
អស់អញឥតស្មើ បានហើយធ្វេសធ្វើ គើយគោះបោះបង់ ៗ
ឯយក្សប្រុសនោះ បានព្រួយច្នោះ សោមនស្សអស់អគ្គិ អរឯងស្រួលសើច
សំណើចចំណង់ ថាប្អូនវរវង្ស កែវកុំសង្ស័យ ៗ ចិត្តបងស្រឡាញ់
ពិត ៗ ពេកពេញ ចិត្តដួបកិស្សម័យ បងផ្ញើរបខ្លួន លើខ្លួនថ្មើមថ្ងៃ
លង់លុះក្សណក្ស័យ មរណ៍មួយមូលមិត្ត ៗ ហើយយក្សប្រុសនោះ
ចរចូលផិតចុះ កៀកករត្តវិត ដៃដល់ថនា យួរយាទឹមផ្ទិត យក្ស
ស្រីកាំងកិត អៀនខ្មនក្រ្តា ៗ ព្រឺព្រួចព្រមប្រាណ រួមរសស្មោះ
ស្មោន ផិតផងបត្តា អស្ចារ្យកន្ទង់ ត្រេចត្រង់ត្រីបផ្កា រសាយ
បុប្ផា កេសរកេរុះ ៗ ព្យុះសង្ឃរា ពិរុណរាំលា ស្រក់ស្រោចចម្រុះ
នាគពជពេនពង់ ក្រញូអគ្គិត្រដុះ ខ្មនក្បាលលូនចុះ ចូលរូងបត្តា ៗ
ព្រួសពិសអង់អាច សំដែងអំណាច ឥតខ្លាចខ្សែរណា ក្អិពិសពោរ
ពាស ទឹសទាសត្រៀបត្រា ពេញរូងបត្តា ហើយសម្ងំជ្រក ៗ

ស្មេះរឿងយក្សទុក្ខ ថ្លែងតំទៅមុខ អំពីបបក ដេកក្នុងគោហា
ដូចពណ៌នាមក ភ្ញាក់ឡើងរិះរក គិតក្នុងចិត្តថា ៗ បើអញផាស់ញី
ប្រាយប្រាប់អំពី ដំណើរអញណា ក្រែងញីឃាត់ប្រាណ រំខានអាត្មា
នាំស្អុនយាត្រា មិនដូចបំណង ៗ គួរអញលបរត់ ចេញចាកប្រា-

កង សោះកើតសៅហ្មង ចចកគិតខ្លោះ លបស្ទុះចេញហោង ដើរស្រូតរំលង ដល់ជ្រោះបញ្ចា ។ ឃើញយក្ខិនី ប្រែប្រាណឥន្ទ្រីយ ជាខ្មោចមាយា គិតញ័ររំប្រប់ ស្បែងស្ងប់ពេមា ចចកម្នីម្នា ឡើងលើថ្មជា ៗ ផ្លោចក្អែកលោតចុះ ធ្លាក់ក្នុងបាតជ្រោះ បាក់កអាត្មា ក្សិណក្ស័យជីវី យកស្រីនោះណា ឃើញហើយជ្រះថ្លា ក្រោកឈរឡើងរាំ ៗ (មានត)

## រឿងនេះបានគតិដូចម្តេច?

រឿងព្រេងនេះឯងកំប្លែងមែន តែមានព្រំដែនល្អណាស់ណា
ហើយបានគតិគួរជ្រះថ្លា លោកអ្នកទស្សនាគួរកាន់យក ៗ
សម្រាប់កំចាត់សេចក្តីលោភ កុំឲ្យចិត្តល្មោភដូចចចក
ព្រោះអ្នកលោភលន់ឥតស្រុតស្រាក តែងខកខូចខ្លួនខានបានល្អ!

បាប-ពិន

## ក្អែសត្វឡូហៀន

រឿងព្រេងប្រទេសរោម៉ានី

# លោក ផេង-ជ្រើវ នៅក្រសួងឃោសនាការជាតិ

ប្រែចាកសៀវភៅ កុង អេ ឡេ សង់ដ៍ ដឺរោម៉ានី

(Contes et légendes de Romanie)

រឿងនេះជាជីវប្រវត្តិនៃបុរសកំសត់ម្នាក់ឈ្មោះ តូឡូហៀន ។

ក្នុងកាលកន្លងទៅហើយ គេដំណាលថា មានតាចាស់ម្នាក់មានតែកូនប្រុសមួយ ៗ ថ្ងៃមួយ តាចាស់និយាយនឹងកូនថា:

— នែកូន ! ឥឡូវត្រូវតែកូនរកគូស្រករឲ្យហើយ ៗ

ការណ៍ហ្នឹងពិតណាស់ ដ្បិតមាណពនោះមានអាយុកាន់តែច្រើនហើយ ៗ

កូនឆ្លើយថា :

— ឪ ! បើឪចង់រកប្រពន្ធឲ្យខ្ញុំ ក៏រកចុះ ប៉ុន្តែ ខ្ញុំនឹងទៅរកដណ្ដឹងនារីណាឲ្យសមគួរ ?

— រឿងហ្នឹង កុំព្រួយកូន? មានគេនិយាយប្រាប់ឪថា នៅភូមិឯណោះ មានកូនស្រីរបស់ត្រកូលមួយជាធីតាគោល ហើយមុខជាទីគាប់ចិត្តដល់កូនឯងជាប្រាកដ ៗ

— ប្រហែលមែនហើយឪ ! ប៉ុន្តែ ដែលនឹងទៅរកដណ្ដឹងនាងនោះ តើនឹងទៅតាមដោយដៃទទេឬ ?

— កូន ! ចូរឯងកុំបារម្ភ យើងទាំងពីរនាក់នឹងទៅដណ្ដឹងជាមួយគ្នា ។

ហើយតាចាស់នឹងកូននាំគ្នាទៅភូមិនោះ រួចចូលក្នុងផ្ទះនិយាយការ ។ ឪពុកម្ដាយខាងស្រីយល់ព្រមឲ្យ ។ មិនយូរប៉ុន្មានអាពាហមង្គលក៏មានធ្វើឡើង ។ ចំណែកកូនប្រសាស្រីមកនៅជាមួយតាចាស់ ។ ប៉ុន្តែ នាងកុមារិកានេះមិនមែនជាករិយាសុចរិតឡើយ គឺបានតែអាការខាងក្រៅ ត្រង់ចិត្តគំនិតជាស្រីក្បត់ ។

ចំណែកតាចាស់ជាអ្នកមានសម្បត្តិទ្រព្យ គឺមានសត្វពាហនៈក៏ច្រើន ប្រាក់ក៏ច្រើន ។ ថ្ងៃមួយ កូនប្រុសគាត់សំគាល់ឃើញរំពាត់ខ្សែត្រីមួយ ព្យួរនៅនឹងដែកគោលត្រង់ក្បាលដំណេកឪពុក ។ រំពាត់នេះទុកជាគ្រឿងលំអផងនឹងជាអាវុធផង ។ គឺជាវត្ថុមានប្រយោជន៍ដ៏សំខាន់ក្នុងផ្ទះ ។ ហើយរឿងរំពាត់នេះមិនមែនអស់តែត្រឹមប៉ុណ្ណោះទេ អ្នកអាននឹងឃើញនៅមានតទៅទៀត ។

កូនសួរឪពុកថា :

— លោកឪពុក ! ខ្ញុំបាទចង់ដឹង តើរំពាត់នេះទុកសម្រាប់ធ្វើអ្វី?

— ម្នាលកូនប្រុស ! រំពាត់នេះ ជារំពាត់មន្ត ។ ឪមិនបាននិយាយរឿងនេះប្រាប់កូនឯងតាំងពីនោះដល់នេះ ។ ឥឡូវឪនឹងប្រាប់ឲ្យកូនដឹង ព្រោះឪកាន់តែចាស់ណាស់ហើយ ឯអាយុសង្ខារក៏មិនទៀង ។

« នែកូន ! រំពាត់នេះ កូនគ្រាន់តែលើករលាស់ ៣ ដង កូនចង់ប្រាថ្នាយ៉ាងណា នឹងសម្រេចយ៉ាងនោះ ។ កូនចង់បានប្រាក់ កើតប្រាក់, ចង់បានសត្វពាហនៈ កើតសត្វពាហនៈមួយរំពេចនៅចំពោះមុខ

ហាក់ដូចជាវត្ថុតាំងនោះចេញមកពីផែនដី ។ កូនយករំពាត់រលាស់លើមនុស្សដោយមានគំនិតចង់ឲ្យក្លាយជាឆ្កែ មនុស្សក្លាយទៅជាឆ្កែភ្លាម ។ កូនចង់ឲ្យឆ្កែនោះក្លាយជាមនុស្សវិញ ? ចូររលាស់ភ្លាម · វានឹងសម្រេចដូចចិត្តចង់ ។

“ ឥឡូវ ឪត្រូវប្រាប់ចំណោះមួយទៀត តែកូនឯងកុំនិយាយរឿងនេះប្រាប់ប្រពន្ធឯងឲ្យដឹង ។ តែប្រាប់ ទោះបីប្រពន្ធកូនឯងជាស្រីមានអាការជាអ្នកសុចរិតក៏ដោយ វាគង់តែទោរទន់ទៅរកអំពើទុច្ចរិតបាន ហើយកុំសង្ស័យអំពីគ្រោះថ្នាក់ គឺមុខជាកូនឯងនឹងបានជួបប្រទះ . . . ។

“ នេះជាបណ្តាំទីបំផុត ហិបនេះពេញសុទ្ធតែមាសនឹងប្រាក់ ចូរកុំឲ្យកូនសោទៅប្រពន្ធកូនឯងឲ្យសោះ ” ។

មិនបានប៉ុន្មានថ្ងៃ តាចាស់ក៏បិទភ្នែក ហើយបែកស្ថានទៅកាន់បរលោក ។ កូនគាត់នឹងកូនប្រសាយកខ្មោចតាចាស់ទៅកប់ទុកដ៏ត្រឹមត្រូវតាមប្រពៃណី ។ រួចស្វាមីភរិយានៅគ្រប់គ្រងផ្ទះតែពីរនាក់ ។ ប្តីតែងទៅធ្វើការងារប្រកបដោយសកម្មភាពជានិច្ចកាល គឺទៅរកកាប់ឧសក្នុងព្រៃ មកឯផ្ទះកិនស្រូវបុកអង្ករ គឺថាគ្មាននៅនឹងមួយកន្លែងឡើយ ធ្វើការដូចទឹកកំពុងហូរ ។ ចំណែកប្រពន្ធក៏ធ្វើការនៅឯផ្ទះណាស់ដែរ ។ ប៉ុន្តែ ទោះបីដូច្នោះ ក៏គង់វានៅជាស្រីចំកួត តែងមានគំនិតអាក្រក់ក្នុងខួរក្បាល ។ វាតែងនឹកថាអាជីវកម្មរបស់វាតឹងរ៉ឹងពេក ហើយប្តីមិនដែលនឹកនានឹងនាំទៅកំសាន្តចិត្តកន្លែងណាបានម្តងសោះ ។

មានមួយថ្ងៃ នាងភរិយានិយាយត្អូញត្អែរប្រាប់អ្នកជិតខាងម្នាក់ដែល

ជាមនុស្សចិត្តអាក្រក់ ហើយឈ្លានពានដល់ទ្រព្យសម្បត្តិអ្នកដទៃ ៗ បានឮនាងនោះនិយាយដូច្នោះ មិនគិតពោលបង្រាបឲ្យផង ក៏គិតតែពាក់រុក ជួយដុតឲ្យកាន់តែឆេះច្រើនៗឡើង ៗ គ្រាន់តែប្ដីចាកចេញ អានោះមកដល់ភ្លាម ក៏ទាំងពីរនាក់នាំគ្នាគិតតែដេរប្រទេចនឹងប្រព្រឹត្តអំពើក្បត់ ៗ

ចំណែកប្ដីគិតតែពីធ្វើការងារ មានគំនិតសុចរិត មិនបានដឹងថា ប្រពន្ធអាត្មាបែកចិត្ត មិនរវល់នឹងខ្លួន ហើយធ្វើការក្នុងផ្ទះទាំងបង្ខំទេ ៗ

ថ្ងៃមួយ ប្ដីទៅចំការ អានោះក៏មក បានឃើញរំពាត់ខ្សែតីព្យួរនៅនឹងដែកគោល ៗ ក៏សួរថា:

— ចុះរំពាត់ហ្នឹង គេទុកសម្រាប់ធ្វើអ្វី ?

– អើ ! ខ្ញុំក៏មិនដឹង ៗ

– ចូរសួរប្ដីនាងមើល គាត់ទៀនតែដឹងរឿងជាពិតប្រាកដ ៗ ហើយប្រសិនបើគាត់មិនប្រាប់ នាងឯងធ្វើជាខឹងហើយរត់ទៅផ្ទះឪពុកម្ដាយនាង នោះនាងប្រាកដជានឹងបានដឹងរឿងអ្វីមួយជាមិនខាន ៗ

វេលាល្ងាចប្ដីត្រឡប់មកផ្ទះវិញ បានឃើញប្រពន្ធកំពុងធ្វើការរៀបចំឲ្យប្ដី ជាការដែលក៏មិនដែលធ្វើសោះពីដើម ព្រមទាំងនិយាយបួងលោមបំពេញទឹកចិត្តយ៉ាងអស្ចារ្យ ៗ ជាទីបំផុតប្រពន្ធសួរប្ដីថា:

– អ្នកបងសំឡាញ់ ! សូមស្ដាប់ប្អូនៗចង់សួរបន្តិច រំពាត់ព្យួរនៅនឹងដែកគោល សម្រាប់ប្រើការដូចម្ដេច ?

– ឱពុទ្ធាអើយ ! អីចឹងក៏ចាំសួរដែរ រំពាត់ជារំពាត់ទេតើ . . . ៗ

– ចុះហេតុអ្វីក៏អ្នកមិនចង់ប្រាប់ប្អូន ?

— នែនាង ! ចុះបង់ឲ្យបងប្រាប់អូនដូចម្តេច ? គឺជារំពាត់ដែលបងគ្រាន់តែរក្សាទុកប៉ុណ្ណោះទេតើ ព្រោះជារបស់កេរ្តិ៍ពីឪពុកបងមក ។

— បងប្រាកដជាមិនព្រមប្រាប់ខ្ញុំឬ ?

— ចុះឲ្យបងយកអ្វីប្រាប់អូន ? អូនឯងឆ្កួតទេឬ ?

មិនោរព្រាយ កាលបានដឹងថាវាមិនបានសម្រេចដូចសេចក្តីប្រាថ្នា ក៏ធ្វើជាខឹង ហើយរត់ទៅនៅឯផ្ទះឪពុកម្តាយរបស់វា ។ បីថ្ងៃកន្លងមក ដោយគ្មាននរណាជួយមើលស្លដណ្តាំ ជួយមើលកិច្ចការក្នុងផ្ទះ ប្រុសប្តីក៏ផ្លាស់គំនិតថ្មី ហើយទៅតាមអង្វរប្រពន្ធឲ្យត្រឡប់មកផ្ទះវិញ រួចនឹងនិយាយប្រាប់រឿងសព្វគ្រប់ ។ លុះស្វាមីករិយាត្រឡប់មកដល់ផ្ទះហើយ ប្រពន្ធសួរថា :

— អ្នកបងនិយាយប្រាប់មក ។

— នែនាង ! រឿងនោះដូច្នេះ រំពាត់នេះមានការណ៍សំងាត់មួយ ចូរនាងលើកឡើងហើយលោស់ នាងមានបំណងយ៉ាងណា នឹងបានសម្រេចយ៉ាងនោះ ។ បើនាងចង់ឲ្យបងក្លាយទៅជាឆ្កែ លើករំពាត់លោស់ឡើង បងទៅជាឆ្កែភ្លាម ។ ម្យ៉ាងទៀត ហឹបនេះពេញសុទ្ធតែមាស ។ នេះកូនសោ ! ចូរនាងចាក់យកបើតាមត្រូវការចុះ ។

ប្រពន្ធឥតមានវាចាថាអ្វីសោះ ហើយប្តីក៏គ្មានសង្ស័យអំពីបំណងអាក្រក់នៃករិយាខ្លួន ។ ព្រឹកឡើងគ្រាន់តែប្តីចេញទៅធ្វើការសឹងមិនទាន់ផុត អាសហាយមកដល់ក្នុងទីធ្លាភ្លាម ហើយសួរថា :

— ម៉េចទៅ អូន មានបានដឹងការណ៍អ្វីខ្លះដែរឬទេ ?

— បានដឹងស្រេចអស់ បង ! ចូរបងឯងគិតចុះ ។

អាប្រុសនិយាយថា :

— មុននេះ ចូរអ្នកឈប់ព្រួយ យើងនឹងផាត់ចេញឲ្យស្រឡះជាយ៉ាងដាច់ ដើម្បីកុំឲ្យមានឧបសគ្គដល់បំណងរបស់យើង ។

ជនទាំងពីរធ្វើការពិសោធន៍នឹងឆ្កែមួយ ហើយគេបានឃើញឆ្កែនោះ បានក្លាយមកជាមនុស្សដោយឥតពិបាក រួចគេធ្វើឲ្យក្លាយទៅជាឆ្កែវិញ ៗ ល្បួចបុរសប្ដីត្រឡប់មកផ្ទះវិញ ៗ ក្រោយដែលបានដោះគោចេញពីនឹម ទឹងបញ្ហូលរទេះទុកក្រោមផ្ទះ គាត់បានឃើញបច្ចាមិត្តឈរនៅមាត់ទ្វារកាន់ពោតនៅដៃហើយស្រែកថា :

— ឯងពីដើមមកដល់ពេលនេះជាមនុស្សយ៉ាងណា ពីថ្ងៃនេះតទៅឯងត្រូវទៅជាឆ្កែសម្ដយឈ្មោះតូឡូហៃទ្រយ៉ាងនោះ ៗ រួចលោសពោតផ្ដាច់ បុរសកំសត់ក៏ក្លាយទៅជាឆ្កែក្លាម ៗ

បុរសកំសត់គិតតែពីព្រួស ដោយមានគំនិតគិតថា : ធ្វើដូចេះ គេមិនបណ្ដេញខ្លួនចេញពីផ្ទះដែលជាកេរ្ដិ៍របស់ខ្លួន ៗ អាសហាយនៅក្នុងទីនោះធ្វើជាម្ចាស់កម្មសិទ្ធិធ្វើជាប្ដីជំនួស ហើយគិតធ្វើដូចម្ដេច ឲ្យតែដីរគាពឆ្កែនោះប្រព្រឹត្តទៅដោយសេចក្ដីទុក្ខវេទនា ៗ

នៅទីបំផុត មានមួយថ្ងៃ មេកាឡ្រកណ្ដីដាំទឹកមួយឆ្នាំងខ្ទះ ហើយទៅចាក់ផះលើឆ្កែតូឡូហៃទ្រកំសត់ដែលកំពុងដេកនៅមុខផ្ទះ ឲ្យបានដល់សេចក្ដីវេទនាស្ទើរនឹងស្លាប់ ៗ

គ្រានោះ សុនខកំសត់ស្ទុះឡើងគ្រវីញខ្លួន គ្រវីក្បាលដូចឆ្កែមែន ៗ ដែលត្រូវទឹក ហើយក៏រត់ចេញចាកផ្ទះអាត្មា ៗ

ប៉ុន្តែ តើនឹងទៅកន្លែងណា ? តូឡូហៀនដើរតាមចំការគេ ទៅត្រង់រហូតដល់កំពូលភ្នំមួយ ដែលជាកន្លែងកាលស្មៅរបស់ព្រះអង្គម្ចាស់មួយអង្គ ៗ ឆ្កែអស់កំឡាំង ឃ្លានបាយ ដើរស្ទើរតែមិនរួច ៗ វាមិនហ៊ានទៅជិតផ្ទះអ្នកស្រុក ខ្លាចគេវាយទៀត ប៉ុន្តែធ្វើដូចម្ដេច បើឃ្លានយ៉ាងនេះ ៗ

ខណៈពាល្ហួ សំឡេងនោះ គួរឲ្យស្រណេះស្រណោចស្ទើររលួយថ្លើមប្រមាត់ ៗ អ្នកគង្វាលចៀមម្នាក់ដែលនៅថែចៀមរបស់ព្រះអង្គម្ចាស់ក្សេរនោះ ឮហើយក៏មានចិត្តរំភើបជាពន់ពេក:

— ចុះហេតុដូចម្ដេច ក៏ឆ្កែនេះលូបែកពីគេដូច្នេះ ?

អ្នកគង្វាលចៀមដេញសត្វរបស់ខ្លួនទៅត្រង់ទីនោះ បានឃើញឆ្កែកំពុងលូ ហើយស្រែកសួរថា :

— នែ ! ឆ្កែស នែឆ្កែស !

ឮសំឡេងគេហៅ ឆ្កែសដើរចូលបន្តិច មិនហ៊ានស្ទុះចូលមកដល់ភ្លាមទេ ដើរចូលមួយជំហាន ថយប្រាំជំហាន ៗ អ្នកគង្វាលដឹងក៏ចេះតែហៅដោយសំដីលួងលោម :

— នែឆ្កែសកំសត់ ! នែឆ្កែសកំសត់ ! កុំភ័យ ចូរចូលមកអាយ មកនេះ ឆ្កែសល្អ មក ! មក ! . . . ៗ

ដឹងថា គេប្រាកដជាមិនបំរុងនឹងធ្វើបាបអាត្មាហើយ ឆ្កែសក៏ចូលមក ប៉ុន្តែលូនចូលដោយសន្សឹម ៗ ហើយបក់កន្ទុយរវិច ដូចជាឆ្កែទាំងពួងដែល

ខ្លាចគេវាយ ។ គ្រានោះអ្នកគង្វាលចៀម យកពោតបុកមួយដុំពីកន្ត្រក់ស្បៀងហើយបោះទៅឲ្យ ។ ពោតនោះធ្លាក់ទៅប្រឡាក់ដីបន្តិច តូឡូហ្វៃហ្សេទគ្រាន់តែហិត តែមិនស៊ី ដោយហេតុតែក្លែកមករកដូចជាចង់ប្រាប់ថាស៊ីមិនកើត ។ អ្នកគង្វាលឆ្លាតដែរ ក៏យល់សេចក្តីបំណងនៃសុនខ រួចលាតស្បៀងនៅដី ដាក់ពោតបុកមួយដុំនឹងប្រហុកមួយកង់ពីលើ (ប្រហុកបាកាំង) ។ ក្លែកំសត់ ដោយសារខ្លួនជាជាតិមនុស្ស ក៏ស៊ីដូចជាមនុស្សមួយរំពេច គឺស៊ីពោតបុកមួយមាត់នឹងប្រហុកមួយមាត់ជាមួយគ្នា រួចទើបទំពាលេបទៅ ។ អ្នកគង្វាលចៀមកាត់ពោតបុកនឹងប្រហុកជាកង់ ៗ រួចហុចឲ្យស៊ីនៅដៃទាល់តែឆ្អែត ។ រួចគេនាំក្លែទៅឲ្យផឹកទឹកឯទីជ្រោះ ប៉ុន្តែសុនខនេះមិនមែនលិទ្ធ ៗ ដូចក្លែធម្មតាឡើយ គឺផឹកដូចមនុស្ស ។ វេលាល្ងាច គេនាំទាំងចៀមទាំងក្លែសធំល្អមកផ្ទះ ។

គេជំណាលថា ព្រះអង្គម្ចាស់ដែលយើងពោលមកពីខាងលើនេះមានទ្រព្យសម្បត្តិច្រើនណាស់ ហើយហ្វូងចៀមក៏ច្រើន ។

ប៉ុន្តែតាំងពីប៉ុន្មានឆ្នាំមក ចចកតែងតែធ្វើទុក្ខរាល់ឆ្នាំនៅរដូវចៀមកើតកូន គឺវេលាយប់ វានាំគ្នាមកស៊ីកូនចៀមអស់ ។

រឿងដូច្នេះមានមកជាយូរឆ្នាំហើយ ។ ពួកអ្នកគង្វាលចៀមនាំគ្នាឃ្លាំចាំយាមជាមួយនឹងក្លែទាំងឡាយក៏ឥតអំពើ ម្ល៉ោះហើយគេមិនដែលមានកូនចៀមមួយនៅគង់ក្រោលម្ដងសោះ ។

ល្ងាចមួយ គឺជាវេនរបស់អ្នកគង្វាលចៀមដែលមានតូឡូហ្វៃហ្សេទ ត្រូវនាំចៀមឲ្យទៅស៊ីស្មៅយប់ ។ គេយកពោតបុករៀបមួយឆ្នាំងខ្ទះ យក

ប្រហុកពីរដុំដែលដាក់សំងួតនៅលើពន រួចហៅគូកនម្នាក់នឹងឆ្កែចេញទៅ ៗ បានដល់កន្ទ្រងពេលស្ងោហើយ គេយកស្បៀងចេញមកធ្វើជាចំណែកបី: ស៊ីមួយចំណែកម្នាក់ រួចទុកមួយចំណែកឲ្យឆ្កែ ៗ

ថ្ងៃលិចសឹងមិនទាន់ គេឮស្សូរសម្រែកលូពីចម្ងាយ គឺចចកធុំក្លិនកូនចៀម ៗ ស៊ុនខស បណ្ដាយឲ្យម្ចាស់នឹងហ្វូងចៀមនៅទីនោះ ហើយស្ទុះសំដៅបញ្ចាម៉ែត្រ ៗ

សូមអ្នកអានទាំងឡាយជ្រាប តែចចកណាមួយកើតក្បាលមកតួឡូហៀនខាំត្រង់កគ្រាត់ម្ដងប្ដីរដេងទម្នាក់ចោលទៅដីស្លាប់ ៗ វាខាំតែម្នាក់វាសម្លាប់អស់ចចករាប់រយរាប់ពាន់ ៗ

ក្នុងឱកាសនោះ កូនចៀមទាំងឡាយនាំគ្នាស៊ីស្មៅជាសុខ ចំណែកអ្នកគង្វាលដេកលក់ព្រងើយ ៗ លុះពេលសឹងកើត អ្នកគង្វាលភ្ញាក់ឡើងស្រាប់តែរកឆ្កែមិនឃើញ ។ ឆ្កែមានគ្រោះថ្នាក់ដូចម្ដេចទៅ? ប៉ុន្តែគ្មានអ្វីសោះ កូនចៀមនៅទាំងអស់ សូម្បីតែមួយក៏គ្មានបាត់ផង! ហើយអ្នកគង្វាលប្រឹក្សាគ្នា ពុំដឹងហេតុអ្វីក៏ដូច្នេះឆ្ងល់ពេក ៗ លុះថ្ងៃរះ គេឃើញអ្នកគង្វាលត្រូវតម់កដល់ហើយសួរថា:

– ដូចម្ដេចទៅ! ឯណាកូនចៀម? ចចកស៊ីអស់ទៀតទៅហើយមែនឬទេ ?

– គ្មានអ្វីទេ! សូមលោកមើលចុះ! វាកំពុងសម្រាកដេកទំពាអៀង ៗ ប៉ុន្តែ ខ្ញុំព្រួយពេកអំពីឆ្កែខ្ញុំ វាទៅបាត់តាំងពីល្ងាចម្សិលម៉្ងៃ៖ ហើយខ្ញុំចាំមើលមិនឃើញវាមកវិញសោះ ៗ

កំពុងតែនិយាយគ្នា អ្នកគង្វាលចៀមស្តាប់ឮសំរែកលូពីចម្ងាយ ៗ ខំផ្ទៀងស្តាប់ស្រួលបួល ម្ចាស់ស៊ុនរឆ្លើយថា:

– ហ្វឹងហើយឆ្កែរបស់ខ្ញុំ ៗ

រួចអ្នកទាំងពីរដើរឆ្ពោះទៅទីនោះ ៗ

តើគេបានឃើញអ្វី ? គួឲ្យហៀនឆ្កែសបានសម្លាប់ចចកចាប់គរលើគ្នា ហើយឡើងទំពាលើស្រែកហៅម្ចាស់ ៗ លុះឃើញដូច្នោះ អ្នកគង្វាលជាម្ចាស់មានចិត្តត្រេកអររកអ្វីប្រៀបគ្មាន ៗ

អ្នកគង្វាលដទៃក៏មានសេចក្តីស្រួលចិត្តដែរ ដោយឃើញថាតាំងពីពេលនេះទៅ មានឆ្កែឆ្នាំយ៉ាងពូកែ ដើម្បីការពារហ្វូងចៀមរបស់កគ្រប់គ្នា ហើយគេនាំឆ្កែសកំសត់នេះរហូតដល់ទីក្រោលធំ ៗ ម្ចាស់ឆ្កែនិយាយថា "ឆ្កែនេះមិនមែនដូចជាឆ្កែធំទាំងពួងលើផែនដីទេ" ហើយពោលថែមទៀតថា: ឆ្កែនេះមិនត្រូវចិញ្ចឹមដោយឲ្យស៊ីតែត្រីមប្រហុកទេ បើតាមសុចរិត ត្រូវចិញ្ចឹមវាដោយទឹកដោះខាប់ ៗ ចំណែកអ្នកគង្វាលទាំងប៉ុន្មានថែរក្សាឆ្កែនោះតែរៀង ៗ ខ្លួន ៗ

ចំណែកព្រះអង្គម្ចាស់ជានាយចៅហ្វាយនៃអ្នកគង្វាលទាំងឡាយ មានអាថ៌កំបាំងមួយក្នុងដំណាក់ជាធម្មតា ៗ រាល់ឆ្នាំការិយារបស់ទ្រង់តែងប្រសូតទារកមួយមានរូបឆោមយ៉ាងល្អ នៅវេលាកណ្តាលអធ្រាត្រ ៗ ប៉ុន្តែលុះព្រឹកឡើងទារកទៅណាបាត់ ព្រះនាងជាការិយានៃព្រះអង្គម្ចាស់មានព្រះហឫទ័យព្រួយរកទីបំផុតគ្មាន ៗ

## កំណត់ចងប្រវត្តិការណ៍

### ពិធីបុណ្យបូជាព្រះសព

សម្តេចព្រះសុធម្មាធិបតី អ៊ុង-ស្រី សង្ឃនាយកគណៈធម្មយុត្តិ

### លោក ឯង-ប៉ង់ រៀបរៀង

---

ពិធីបុណ្យនេះ មានកម្មវិធីច្រើនបែប តែយើងមិនបានរៀបរៀងទាំងអស់ទេ យើងរៀបរៀងជាសេចក្តីសង្ខេបដូចតទៅនេះ៖

ក្នុងថ្ងៃទី ៦ តុលា ១៩៥៦, នៅឯសាលាបិណ្ឌ ក្នុងវត្តបទុមវតី រាជវរារាម សង្កាត់លេខ ៤ ក្រុង មានធ្វើពិធីបុណ្យរំកិលព្រះសពសម្តេចព្រះសុធម្មាធិបតី សង្ឃនាយក គណៈធម្មយុត្តិ ព្រះនាម អ៊ុង-ស្រី ដើម្បីហែទៅបូជានៅព្រះមេរុ ឰដ៏ខាងជើងព្រះបរមរាជវាំង ។

ក្នុងឱកាសនោះ យើងសង្កេតឃើញការជួបជុំនៃឥស្សរជនជាន់ខ្ពស់ ដែលមានលោកប្រធានសភាទាំងពីរ, សមាជិករាជរដ្ឋាភិបាល, អនុរដ្ឋលេខាធិការជាដើម ព្រមទាំងឧបាសកឧបាសិកាក្នុងទីក្រុងនិងខេត្តក្រៅជាច្រើន ឈររង់ចាំដង្ហែព្រះសពសម្តេច ។

នៅម៉ោង ១៤ គត់ សម្តេចចៅហ្វាវាំងវរៈវៀងជ័យអធិបតីស្រឹង្គារ ប៉ែន-នុត ក្នុងឋានៈជាព្រះរាជតំណាងព្រះករុណាជាអម្ចាស់ជីវិតលើត្បូង អញ្ជើញមកដល់ ។ ឯកឧត្តមញ៉ឹក-ទូ បានហ្វាងពិធីការនៅក្នុងព្រះបរម-

រាជវាំង ក៏បានចាត់ចែងពិធីរំកិលព្រះសពចេញពីសាលាបិណ្ឌ មកដំកល់ទៅលើរថយន្តដ៏វិចិត្រ ហើយចាត់ក្បួនហែជាសង្កាត់ជាជួរយ៉ាងល្អឥតខ្ចោះ តាមលំដាប់លំដោយ ហើយដង្ហែទៅតាមវិថីបទុមវតី, មហាវិថីព្រះបាទសុរាម្រិត, មហាវិថីព្រះបាទនរោត្តម, វិថីព្រះអង្គមឃវ៉ន នឹងមហាវិថីសុធារស បត់ចូលមកកាន់ព្រះមេរុ ហើយលើកព្រះកោដ្ឋសែងដង្ហែប្រទក្សិណព្រះមេរុ ៣ ជុំ រួចនិមន្តព្រះសពទៅដំកល់លើបញ្ចា ៥ ជាន់ ។

ដល់ម៉ោង ១៦,៤០ នាទី សម្តេចក្រុមព្រះស៊ីសុវត្ថិ - មុនីរ៉េត ទេសរដ្ឋមន្ត្រីទទួលភារៈខាងក្រសួងការពារប្រទេស នឹងសំអាតរាជការទូទៅព្រមទាំងព្រះរាជវង្សានុវង្ស, គណៈរដ្ឋមន្ត្រី, អនុរដ្ឋលេខាធិការ, ប្រធានសភាទាំងពីរ នឹងនាម៉ឺនសព្វមុខមន្ត្រីខ្មែរ-បរទេស ស្តេចយាងនឹងអញ្ជើញមករង់ចាំទទួលព្រះសពនៅឯព្រះពន្លាខាងត្បូងព្រះមេរុ ។

លុះដល់ម៉ោង ១៦, ៥០ នាទី ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង នឹងសម្តេចព្រះឧបយុវរាជ ទ្រង់ស្តេចយាងមកដល់ ។ គណៈនោះពួកឥស្សរជនបានស្តេចយាងនឹងអញ្ជើញទៅទទួលព្រះអង្គ ។ រួចហើយទាហានក្រុមរក្សាព្រះអង្គនឹងកងខេមរកុមិន្ទឈរនៅគោរព ទាំងក្រុមភ្លេងក៏បន្លឺបទនគររាជគោរពថ្វាយជាព្រះកិត្តិយស ។ បន្ទាប់មកគេនិមន្តសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកធាក រួចនិមន្តព្រះសង្ឃវត្តឧណ្ណាលោម ៨៥ អង្គចំរើនសត្តប្បករណ៍ ។

តមក ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សមាជិកឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ, ប្រធានសភាទាំងពីរ, សមាជិករដ្ឋាភិបាល, អនុរដ្ឋ-

ធិការ, មន្ត្រីទាហាននិងមន្ត្រីស៊ីវិលខ្មែរ-បរទេសឯទៀតជាច្រើន បាន
ទ្រង់ស្តេចយាងនិងអញ្ជើញឡើងទៅលើព្រះមេរុ ដើម្បីគោរពព្រះសព ។
រួចកិច្ចសព្វគ្រប់តាមកម្មវិធីហើយទ្រង់ស្តេចយាងទៅកាន់ព្រះបរមរាជវាំង,
ព្រះរាជតំណាក់ និង អញ្ជើញៈទៅកាន់គេហដ្ឋានរៀងខ្លួនវិញ ។

ក្នុងថ្ងៃទី ៧ តុលា ១៩៥៦ ជាថ្ងៃទី ២ នៃពិធីបុណ្យព្រះសព មាន
ការនិមន្តព្រះសង្ឃបំរើនព្រះបរិត្ត ក្នុងវេលាយប់, និងព្រឹកឡើងវេរ-
ភត្តាហារប្រគេនព្រះសង្ឃ ។

ក្នុងថ្ងៃទី ៨ តុលា ១៩៥៦ នៅថ្ងៃទី ៣ នៃពិធីបុណ្យព្រះសព នៅ
វេលាយប់បាននិមន្តព្រះសង្ឃបំរើនព្រះបរិត្ត ព្រឹកឡើងវេរភត្តាហារដូច
ថ្ងៃទី ២, ប៉ុន្តែពេលព្រឹកនោះ មានធ្វើពិធីរំកិលព្រះសពចុះបោកទីបញ្ចា
ទៅដំកល់នៅថែវខាងលិច ហើយរៀបបញ្ចាសម្រាប់បូជាព្រះសព រួច
និមន្តឡ្យតកោដ្ឋដំកល់លើបញ្ចាព្រះមេរុវិញ ។

នៅម៉ោង ១៦, ៣០ នាទី មន្ត្រីព្រះសង្ឃទាំងពីរគណៈ, ព្រះរាជ-
វង្សានុវង្សដែលមានសម្តេចក្រុមព្រះមុនីរ៉េតជាដើម និងវរជនខ្មែរបរទេស
ព្រមទាំងឧបាសកឧបាសិកាជាច្រើនពាន់នាក់ បាននិមន្តបានស្តេចយាង
និងអញ្ជើញមកណែនណាន់តាន់តាប់ក្នុងមណ្ឌលព្រះមេរុ ។

ដល់ម៉ោង ១៧ គត់ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង, សម្តេច
ព្រះមហាក្សត្រិយានី និងសម្តេចព្រះឧបយុវរាជ បានទ្រង់ស្តេចយាងមក
ដល់ព្រះមេរុ ។ ឯកឧត្តម ញឹក-ទូវ ចាងហ្វាងព្រះរាជពិធីការព្រះបរម-
រាជវាំង បានថ្លែងសុន្ទរកថាមួយ តាងនាមនៃព្រះរាជរដ្ឋាភិបាល ស្តីអំពី

ប្រវត្តិរូបនៃសម្តេចព្រះសុមេធាធិបតី អ៊ុង-ស្រី, ពីស្នាព្រះហស្តកុងកិច្ចឧបត្ថម្ភព្រះពុទ្ធសាសនារបស់សម្តេច ។

លុះចប់សុន្ទរកថាហើយ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង, សម្តេចព្រះមហាក្សត្រិយានី, សម្តេចព្រះឧបយុវរាជ និងសម្តេចក្រុមព្រះមុនីរ៉េត បានទ្រង់ស្តេចយាងទៅកាន់បញ្ញាសម្រាប់បូជាព្រះសព ដើម្បីទ្រង់ស្តេចប្រគេនផ្កាខ្ទឹមចន្ទន៍ ។ ឯវរជនឯទៀតមានប្រធានសភាទាំងពីរជាដើម បានអញ្ជើញប្រគេនផ្កាខ្ទឹមចន្ទន៍ជាបន្តបន្ទាប់មក ។

ក្នុងថ្ងៃទី ៩ តុលា ១៩៥៦ ជាថ្ងៃទី ៤ នៃពិធីបុណ្យព្រះសព, វេលាម៉ោង ៦,៤០ នាទី មានការនិមន្តព្រះសង្ឃ ៤ អង្គចំរើនសត្តប្បករណ៍ ប្រែព្រះរូបប្រគេនពរទឹករើសព្រះអដ្ឋិ ដែលមានវរជនព្រះសង្ឃនិងគ្រហស្ថឯទៀតជាច្រើន បាននិមន្ត-ស្តេចយាងនិងអញ្ជើញទៅរើសព្រះអដ្ឋិដែរ ។ ក្នុងពេលចប់កិច្ចរើសព្រះអដ្ឋិតាមប្រពៃណីហើយ, វេលាម៉ោង ១០ មានការវេរភត្តាហារប្រគេនព្រះសង្ឃចំរើនព្រះបរិត្ត រួចនិមន្តធម្មថិកមួយអង្គសំដែងបឋមគ្រាស់ ទាំងនិមន្តព្រះសង្ឃ ២ អង្គសូត្រពុទ្ធាភិសេកវហូតដល់ភ្លឺ ។

ក្នុងថ្ងៃទី ១០ តុលា ១៩៥៦ ជាថ្ងៃទី ៥ នៃពិធីបុណ្យព្រះសព, មានធ្វើពិធីនិមន្តព្រះធាតុចុះពាកបញ្ញា ហើយដង្ហែរទោះទៅកាន់វត្តបទុមវតីដើម្បីបញ្ចុះក្នុងព្រះចេតិយធំ ដែលមានវរជនជាបព្វជិតនិងគ្រហស្ថទាំងឡាយបាននិមន្ត, ស្តេចយាង, អញ្ជើញទៅជួបជុំក្នុងពេលនោះផង ។

នៅម៉ោង ៨,៣០ នាទី ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និង

សម្តេចព្រះមហាក្សត្រិយានីបានស្តេចយាងមកដល់ ដោយមានសម្តេចព្រះឧបយុវរាជ, សម្តេចចៅហ៊្វាកំពង់វរៈវៀងជ័យ, ប៉ែន-នុត សមាជិកឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រជាដើមហែហមព្រះអង្គផង ។

ក្រោយដែលព្រះមហាក្សត្រ ទាំងពីរព្រះអង្គទ្រង់ស្តេចគោរពតេក្ខូនជាតិ, សម្តេចព្រះឧបយុវរាជលើកព្រះធាតុយកទៅបញ្ចុះក្នុងព្រះចេតិយធំហើយនិមន្តព្រះសង្ឃ ៨ អង្គធាក, ៨៥ អង្គទៀតបំរើនសត្តប្បករណ៍ ៗ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះមហាក្សត្រិយានី បានទ្រង់ស្តេចយាងឡើងទៅថ្វាយបង្គំព្រះធាតុ នៅក្នុងព្រះចេតិយតាមប្រពៃណីព្រះពុទ្ធសាសនា ។ លុះចប់កិច្ចសព្វគ្រប់ហើយ ព្រះមហាក្សត្រទាំងពីរព្រះអង្គបានស្តេចយាងចូលព្រះបរមរាជវាំងវិញ ។

ដល់វេលាម៉ោង ១០ គត់ មានការវេរគត្តប្រគេនព្រះសង្ឃ, វេលាម៉ោង ១៣ និមន្តធម្មឋិក ៣ អង្គសំដែងធម៌នៅក្នុងវិហារវត្តឧទុមវតី ជាកិច្ចបញ្ចប់ពិធីបុណ្យតែប៉ុណ្ណេះ ។

ពិធីបុណ្យព្រះសពនេះ ក្រោមព្រះរាជាធិបតីភាពនៃសម្តេចព្រះមហាក្សត្រទាំងពីរព្រះអង្គ មានសេចក្តីរុងរឿងសមរម្យតាមប្រពៃណព្រះពុទ្ធសាសនាយ៉ាងក្រៃលែង ។

ឯសុន្ទរកថានៃឯកឧត្តម ញ៉ុក-ធូ យើងបានដកស្រង់យកមកចុះក្នុងទីនេះ ដោយឥតមានកែប្រែទេ ដូចតទៅនេះ ៖

# សុន្ទរកថា ឯកឧត្តម ញឹក-ទ្យូ

## ចាងហ្វាងព្រះរាជពិធីការនៅព្រះបរមរាជវាំង

សូមព្រះតេជះដំកល់លើត្បូង !

សូមព្រះរាជទានក្រាបបង្គំទូល ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង !

— ដ — សម្តេចព្រះមហាក្សត្រិយានី !

— ដ — សម្តេចព្រះឧបយុវរាជ !

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

តាងនាមនៃព្រះរាជរដ្ឋាភិបាល ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលថ្វាយនូវអំណរដ៏ជ្រាលជ្រៅ ដែលទ្រង់ព្រះមេត្តាប្រោសស្តេចយាងមកជាព្រះរាជាធិបតីក្នុងពិធីបូជាព្រះសពនៃសម្តេចព្រះសុធម្មាធិបតីសង្ឃនាយកព្រះនាម អ៊ុង-ស្រី ក្នុងវេលានេះ ។

បន្ទាប់ពីនេះ ទូលព្រះបង្គំជាខ្ញុំសូមព្រះរាជទានព្រះបរមរាជវរោកាស ថ្វាយដោយសង្ខេបនូវប្រវត្តិរូបនៃសម្តេច អ៊ុង ស្រី ដូចមានសេចក្តីតទៅ៖

សម្តេចព្រះសុធម្មាធិបតិសង្ឃនាយកព្រះនាម អ៊ុង-ស្រី ប្រសូតនៅថ្ងៃព្រហស្បតិ៍ ១៣ កើត ខែមិគសិរ ឆ្នាំមមែ ត្រីស័ក ព. ស. ២៤១៤ ក្នុងភូមិស្វាយ ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល មាតានាម ណៃ បិតានាម អ៊ុង ។ កាលពីអាយុ ១៣ ឆ្នាំ កុមារ អ៊ុង-ស្រី បានទៅសិក្សាអក្សរសាស្ត្រនៅវត្តស្វាយ ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ក្នុងសំណាក់លោកគ្រូចៅអធិការព្រះនាម យួន លុះដល់អាយុ ១៩ ឆ្នាំបាន

បួសជាសាមណេរក្នុងសំណាក់លោកគ្រូចៅអធិការដដែលនេះ អស់រយៈកាល ១ ឆ្នាំ ។ ដល់អាយុ ២២ ឆ្នាំ បានបំពេញឧបសម្បទាជាភិក្ខុភាវៈនៅវត្តបទុមវតីរាជវរារាម ក្នុងសំណាក់សម្ដេចព្រះសុគន្ធាធិបតី ព្រះនាម ប៉ាន ។

លុះឧបសម្បទហើយ ភិក្ខុ អ៊ុង-ស្រី បាននិមន្តទៅគង់នៅវត្តស្វាយ ឃុំគោកត្រប់ ជាស្រុកកំណើតរបស់លោកវិញ គឺវត្តស្វាយនេះហើយដែលលោកបានចាប់ផ្ដើមជាបឋមនូវការសិក្សាព្រះត្រៃបិដក ក្នុងសំណាក់លោកអាចារ្យ ពៅ គេទ្រិហស្ថ ។ ក្រោយការសិក្សាអស់រយៈវេលា ៤ ឆ្នាំក្នុងវត្តស្វាយ ភិក្ខុ អ៊ុង-ស្រី បាននិមន្តមកគង់នៅវត្តបទុមវតីរាជវរារាមនេះវិញ ដើម្បីបន្តការសិក្សាព្រះត្រៃបិដកថែមទៀត ។

ក្នុងរយៈកំពុងសិក្សានេះ ភិក្ខុ អ៊ុង-ស្រី រមែងមានព្យាយាមដំមោះមុតបានខំឆ្លៀតឧកាសខ្លះ បង្រៀនព្រះត្រៃបិដកដល់សមណសិស្សទាំងឡាយជាច្រើនរូប រហូតដល់អស់កំណត់កាល ៣០ ឆ្នាំ ។ អាស្រ័យវីរិយសម្បត្តិនេះហើយ ទើបព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទាន នូវសមណសក្តិជាលំដាប់ដូចតទៅនេះ :

- ជាព្រះគ្រូវិន័យធម្ម ទីឋានា ក្នុង គ. ស. ១៩១០ ;
- ជាព្រះធម្មឧត្ដម ទីរាជាគណ: នៅថ្ងៃទី ១ មិថុនា ១៩៤០ ;
- ជាព្រះធម្មវិរិយត្រៃឡ ទីរាជាគណ: នៅថ្ងៃទី ១ វិច្ឆិកា ១៩៤០ ;
- ជាព្រះសង្ឃនាយកស្តីទី នៅថ្ងៃទី ៣០ មេសា ១៩៤២ ;

— ជាសម្តេចព្រះសុគន្ធាធិបតីសង្ឃនាយក នៅថ្ងៃទី ១៩ មិថុនា ឆ្នាំ១៩៥១ ។

ក្នុងជីវកាលនៃសម្តេច, សម្តេចបានស្ថាបនាឡើងនូវអសង្ហារិមវត្ថុទាំងឡាយជាច្រើន ដូចជា: ទីប៉ាធា, សាលាទទួលភ្ញៀវ ២ ខ្នងនៅជិតទីប៉ាធា នឹងធ្វើបញ្ចើមចូលមុខវត្ត, សាលាភេសជ្ជៈ ១ ខ្នងនៅជិតប៉ាធា, សាលាបរិយត្តិធម្មវិន័យ, សាលាបិណ្ឌ នឹងជាវត្ថុផ្សេងៗទៀត ដែលទូលព្រះបង្គំជាខ្ញុំ ពុំអាចនឹងរៀបរាប់ថ្វាយបានដោយសព្វគ្រប់នៅទីនេះ ។

ដោយទ្រង់ឈ្វេងយល់នូវឧត្តមប្រយោជន៍នេះហើយ ទើបសម្តេចព្រះឧបយុវរាជ កាលទ្រង់គង់នៅក្នុងសិរីរាជបល្ល័ង្កនៅឡើយ ទ្រង់សព្វព្រះរាជហឫទ័យប្រគេនចំពោះសម្តេចព្រះសង្ឃនាយក អ៊ុង-ស្រី នូវគ្រឿងឥស្សរិយយសទាំងឡាយ មានមេដាយធិបឌិន្ទនឹងមេដាយមាសរដ្ឋកាលជាដើម ជាភស្តុតាងដ៏វិសេស ។

សូមទ្រង់ព្រះមេត្តាប្រោស !

នៅថ្ងៃទី ២៣ វិច្ឆិកា ១៩៥៥ ជរាភាពបានចូលមកញាំញីព្រះអង្គនៃសម្តេច ធ្វើឲ្យគ្រាំគ្រាទ្រុឌទ្រោមទៅជាលំដាប់រាល់នាទី ។

បណ្តាបរិស័ទជាសិស្សានុសិស្សទាំងឡាយ ខំស្វះស្វែងរកពេទ្យហ្មដ៏វិសេសវិសាលយ៉ាងណា មកព្យាបាលគេក៏ពុំអាចជាសះស្បើយបានឡើយ ។ ជរាដ៏កំណាចនេះបានដឹកនាំព្យាធិនឹងមរណៈឲ្យចូលមកផ្តិលផ្តាច់ព្រះជន្មាយុសង្ខារនៃសម្តេចទៅ នៅថ្ងៃទី ៣០ មករា ១៩៥៦ ក្នុងព្រះជន្មាយុ ៨៥ ឆ្នាំ, វស្សា ៦២ ។

ទ ! មច្ចុរាជដ៏ឃោរឃៅ, ពុំគួរសោះឡើយអ្នកមកកាត់យកដួងវិញ្ញាណនៃសម្តេចទៅ ដោយឥតមេត្តាដល់តិចសោះ ធ្វើឲ្យយើងទាំង-អស់គ្នាជាសិស្សានុសិស្សបានទទួលនូវសេចក្តីទុក្ខដ៏ក្រៀមក្រំ និងសេចក្តីសោកស្តាយរកទីបំផុតគ្មានដូច្នេះឡើយ ។

ចរិយាសម្បត្តិដ៏ថ្លៃថ្លានិងឧត្តមប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ដែលសម្តេចបានបំពេញសព្វគ្រប់ដោយបរិបូណ៌ក្នុងព្រះពុទ្ធសាសនា ខ្ញុំព្រះករុណាសង្ឃឹមថា សម្តេចទទួលដោយសោមនស្សនូវផលបុញ្ញកម្មទាំងនោះពុំខាន គឺបានសួគ៌និព្វានជាអវសាន ។

យើងខ្ញុំព្រះករុណាទាំងអស់គ្នានេះ បានជូនដំណើរសម្តេចមកដល់ទីព្រះមេរុនេះហើយ ។ សូមក្រាបថ្វាយបង្គំលាសម្តេចជាបច្ឆិមកាលដោយគោរព ។

សូមសម្តេចទទួលឥដ្ឋមនុញ្ញផល ដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង, សម្តេចព្រះមហាក្សត្រិយានី, សម្តេចព្រះឧបយុវរាជ ព្រមទាំងព្រះរាជវង្សានុវង្ស នាហ្មឺនសព្វមុខមន្ត្រី សិស្សានុសិស្សទាំងព្រះសង្ឃនិងគ្រហស្ថ បានធ្វើបុណ្យឧទ្ទិសប្រគេនទៅ ។

ជាអវសានកថា, តាងនាមនៃព្រះរាជរដ្ឋាភិបាល, ខ្ញុំព្រះករុណាទូលព្រះបង្គំ ខ្ញុំបាទសូមអរគុណចំពោះព្រះថេរានុត្ថេរៈ ព្រះរាជវង្សានុវង្សនិងអស់លោកអ្នកដែលបានមេត្តាយាងអញ្ជើញមកកាន់ពិធីនេះ ។